សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សារណាបញ្ចប់ការសិក្សា**

# ការលើកទឹកចិត្តកសិករក្នុងការដាំដំណាំ បន្លែដើម្បីផ្សាភ្ជាប់ទៅនឹងទីផ្សារ

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ឆេង សុខលាភ**
ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី ៤

សាស្ត្រាចារ្យណែនាំ
លោក **ទួន ផល្លា**
ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ ឆេង សុខលាភ ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ក្រុមD4C1 ឆ្នាំសិក្សា ២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

សូមសំដែងនូវសេចក្តីគោរពដឹងគុណ និងកត្តញ្ញូតាធម៌យ៉ាងខ្ពង់ខ្ពស់ជូនចំពោះ៖

លោកអ្នកមានគុណដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មានប្រៀនប្រដៅព្រមទាំងទំនុកបំរុងគ្រប់បែបយ៉ាងទាំងកំលាំងកាយចិត្ត និងស្មារតីប្រកបដោយព្រហ្មវិហារធម៌។

សូមគោរពថ្លែងអំណរគុណយ៉ាងថ្លៃថ្លា ចំពោះការស្វាគមន៏យ៉ាងកក់ក្តៅបំផុតក្នុងការជួយទំនុកបំរុងខាងផ្នែកស្មារតី សីលធម៌ និងចំណេះដឹងនេះ

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យ ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ផ្តល់នូវបទពិសោធន៏ល្អៗសម្រាប់សិស្សនិស្សិតគ្រប់ជំនាន់។

លោកសាស្ត្រាចារ្យ ទូន ផល្លា ដែលបានខិតខំដឹកនាំបង្ហាត់បង្រៀន និងចំណាយពេលវេលាដ៏មានតំលៃក្នុងការផ្តល់នូវយោបល់ល្អៗក្នុងការកែតំរូវ និងតម្រង់ទិសសំរាប់សារណាបញ្ចប់ការសិក្សា ដើម្បីឱ្យការសិក្សាស្រាវជ្រាវ និងចងក្រងសារណាបញ្ចប់ការសិក្សានេះទទួលបានជោគជ័យ។

ជាចុងបញ្ចប់ នាងខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធក្នុងលោក សូមជួយថែរក្សា ការពារ ដល់អ្នកមានគុណរបស់នាងខ្ញុំ ព្រមទាំងលោកឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យប្រចាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាពិសេសលោកសាស្ត្រាចារ្យ ទូន ផល្លា និងមិត្តនិស្សិតទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខ សុភមង្គល ជោគជ័យគ្រប់ភារកិច្ចកុំបីអាក់ខានឡើយ។

# អារម្ភកថា

វិស័យកសិកម្មនៅកម្ពុជាត្រូវបានចាត់ទុកជាវិស័យអាទិភាពដើរតួនាទីយ៉ាងសំខាន់ ជាវាលបៃតងរបស់ប្រទេស ដែលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេស កាត់បន្ថយភាពក្រីក្រ ស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល និងស្របតាមផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។ វិស័យកសិកម្មបានរួមចំណែកប្រមាណ២០,៨%នៃផលិតផលជាតិសរុបឆ្នាំ២០១៩។ អនុវិស័យកសិកម្មដែលបានរួមចំណែកក្នុងវិស័យកសិកម្មមានចំនួន៤រួមមាន ផ្នែកដំណាំ ផ្នែកផលិតកម្មសត្វ ផ្នែកជលផល និងផ្នែកព្រៃឈើ ដែលក្នុងនោះអនុវិស័យចំនួន២ដែលបានរួមចំណែកច្រើនក្នុងការជំរុញវិស័យកសិកម្មឱ្យមានការរីកចម្រើន និងធ្វើឱ្យសេដ្ឋកិច្ចមានការអភិវឌ្ឍន៍នោះគឺ ផ្នែកដំណាំ និងផ្នែកជលផល។ ដោយមើលឃើញពីភាពសំខាន់នៃផ្នែកដំណាំ ពិសេសដំណាំបន្លែក្នុងវិស័យកសិកម្ម ព្រមទាំងក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងសេដ្ឋកិច្ចជាតិ ទើបនាងខ្ញុំលើកឡើងប្រធានបទ «ការលើកទឹកចិត្តកសិករក្នុងការដាំដំណាំបន្លែដើម្បីផ្សារភ្ជាប់ ទៅនឹងទីផ្សារ» នេះឡើង ដើម្បីធ្វើការសិក្សាស្រាវជ្រាវជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ឆ្នាំសិក្សា ២០១៩-២០២០។ ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដើម្បីសិក្សាពីទីផ្សារបន្លែនៅកម្ពុជា និងធ្វើការលើកទឹកចិត្តកសិករឱ្យងាកមកដាំដំណាំបន្លែ ដើម្បីលើកស្ទួយសេដ្ឋកិច្ចគ្រួសារក៏ដូចជាសេដ្ឋកិច្ចជាតិ រួមចំណែកក្នុងការកាត់បន្ថយហានិភ័យសុខភាពបណ្ដាលមកពីបន្លែនាំចូលមានផ្ទុកសារៈធាតុគីមី ព្រមទាំងកាត់បន្ថយការចំណាយរបស់រដ្ឋាភិបាលស្របតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

នាងខ្ញុំសង្ឃឹមថាខ្លឹមសារនៅក្នុងសារណាបញ្ចប់ការសិក្សានេះ អាចជួយលើកទឹកចិត្តកសិករឱ្យងាកមកធ្វើកសិកម្ម ដាំដំណាំបន្លែផ្គត់ផ្គង់ទីផ្សាដែលកំពុងខ្វះខាតជំនួសឱ្យការធ្វើចំណាក់ស្រុក។ ម្យ៉ាងទៀតនាងខ្ញុំសូមស្វាគមន៍នូវរាល់មតិកែលំអក៏ដូចជាគំនិតយោបល់ផ្សេងៗ ដើម្បីបំពេញនូវចំនុចខ្វះខាត ដែលមានក្នុងសារណាបញ្ចប់ការសិក្សានេះ។

ជាចុងក្រោយនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ មិត្តនិស្សិតទាំងអស់ដែលបានគាំទ្រ និងផ្ដល់នូវមតិកែលំអនានាសំរាប់សារណាមួយនេះ ឱ្យជួបប្រទះតែពុទ្ធពរ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


បញ្ជីតារាង ........ iv

បញ្ជីរូបភាព ........ iv

បញ្ជីឧបសម្ព័ន្ធ ........ v


## សេចក្តីផ្តើម


១. ស្ថានភាពទូទៅ ........ ១

២. ចំនោទបញ្ហា ........ ១

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ២

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ននៃការសិក្សាស្រាវជ្រាវ ........ ៤


## ជំពូកទី១៖ រំលឹកទ្រឹស្តី


១.១. និយមន័យ និងទ្រឹស្តីនៃការលើកទឹកចិត្ត ........ ៥

១.១.១. និយមន័យនៃការលើកទឹកចិត្ត ........ ៥

១.១.២. ទ្រឹស្តីនៃការលើកទឹកចិត្ត ........ ៥

១.១.៣. ប្រភេទនៃការលើកទឹកចិត្ត ........ ៦

១.១.៤. សារៈសំខាន់នៃការលើកទឹកចិត្ត ........ ៦

១.២. ទំនាក់ទំនងនៃការលើកទឹកចិត្ត និងទ្រឹស្តីនៃការលើកទឹកចិត្ត ........ ៧

១.៣. និយមន័យទីផ្សារ ........ ៧

១.៣.១. និយមន័យទីផ្សារ ........ ៨

១.៤. ច្បាប់តម្រូវការ និងច្បាប់ផ្គត់ផ្គង់ ........ ៨

១.៤.១. តម្រូវការ និងច្បាប់តម្រូវការ ........ ៨

១.៤.២. ផ្គត់ផ្គង់ និងច្បាប់ផ្គត់ផ្គង់ ........ ៩

១.៥. និយមន័យកសិកម្ម បន្លែ និងបច្ចេកទេសនៃការដាំដុះ ........ ១០

១.៥.១. និយមន័យកសិកម្ម ........ ១០

១.៥.២. និយមន័យបន្លែ ........ ១១
១.៥.៣. ប្រភេទបន្លែ ........ ១២
១.៥.៤. សារៈសំខាន់នៃបន្លែ ........ ១២
១.៥.៥. កត្តាសំខាន់ទាក់ទងនឹងការដាំដុះ ........ ១៥
១.៥.៦. បច្ចេកទេសដាំដុះបន្លែ ........ ១៨
១.៦. ការវិភាគSWOT ........ ១៨

## ជំពូកទី២៖ ទីផ្សារបន្លែនៅកម្ពុជា

២.១. តម្រូវការបន្លែនៅរាជធានីខេត្តទាំង៩ ........ ១៩
២.២. ប្រភេទបន្លែមានតម្រូវការខ្ពស់ និងទាបបំផុតនៅរាជធានីខេត្តទាំង៩ ........ ២០
២.៣. គម្លាតតម្លៃមធ្យមរបស់បន្លែផលិតក្នុងស្រុក និងបន្លែនាំចូល ........ ២១
២.៤. បរិមាណបន្លែផលិតក្នុងស្រុក និងបន្លែនាំចូល ........ ២២
២.៥. ប្រភេទបន្លែផលិតក្នុងស្រុក និងបន្លែនាំចូល ........ ២៤
២.៥.១. ប្រភេទបន្លែនាំមុខគេទាំង១០ដែលផលិតក្នុងស្រុកច្រើនជាងគេបំផុត ........ ២៥
២.៥.២. ប្រភេទបន្លែនាំមុខគេទាំង១០ដែលនាំចូលពីបរទេសច្រើនជាងគេបំផុត ........ ២៦
២.៦. តម្រូវការបន្លែបន្ថែមក្នុងរាជធានីខេត្តទាំង៩ ........ ២៧

## ជំពូកទី៣៖ វិធីសាស្ត្រដាំដុះបន្លែ និងបទពិសោធន៍ដាំដុះជាក់ស្តែង

៣.១ បន្លែសរីរាង្គ ........ ៣០
៣.១.១. ការដាំដុះបន្លែសរីរាង្គ ........ ៣០
៣.២ បន្លែសុវត្ថិភាព ........ ៣៤
៣.២.១. ការដាំដុះបន្លែសុវត្ថិភាព ........ ៣៤
៣.៣. ការអនុវត្តការដាំដុះជាក់ស្តែង ........ ៣៨
៣.៣.១. ស្ថានភាពទូទៅនៃខេត្តព្រៃវែង ........ ៣៨
៣.៣.២. ការអនុវត្តការដាំដុះបន្លែរបស់កសិករក្នុងឃុំគោកគង់លិច ........ ៣៩
៣.៣.៣.ការអនុវត្តបច្ចេកដាំដុះបន្លែរបស់កសិករក្នុងឃុំគោកគង់លិច ........ ៤៣

## ជំពូកទី៤៖ របកគំហើញ និងការវិភាគ

៤.១. ការវិភាគSWOTលើទីផ្សារបន្លែនៅកម្ពុជា ........ ៤៥

៤.២. ការវិភាគSWOTលើវិធីសាស្រ្តដាំដុះ និងការដាំដុះជាក់ស្តែង ........ ៤៦
៤.២.១. ការវិភាគSWOTលើវិធីសាស្រ្តដាំដុះបន្លែសរីរាង្គ ........ ៤៦
៤.២.២. ការវិភាគSWOTលើវិធីសាស្រ្តដាំដុះបន្លែសុវត្ថិភាព ........ ៤៨
៤.៣ វិភាគលើការដាំដុះបន្លែជាក់ស្តែងនៅឃុំគោកគង់លិច ........ ៤៩
៤.៣.១. វិភាគSWOTលើការដាំដុះបន្លែជាក់ស្តែង ........ ៤៩
៤.៤. ការវិភាគSWOTជារួម ........ ៥០

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ ៥៣
២. អនុសាសន៍ ........ ៥៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាងទី១ កម្រិតជីវជាតិនៅក្នុងបន្លែប្រភេទនីមួយៗ ........................................................................ ១៤

# បញ្ជីរូបភាព

រូបភាពទី១ បរិមាណបន្លែដែលផ្គត់ផ្គង់ពីក្នុងស្រុក និងបន្លែនាំចូលពីបរទេស (តោន/ថ្ងៃ) ........................២០
រូបភាពទី២ បន្លែ២០ប្រភេទដែលមានតម្រូវការខ្ពស់ជាងគេបំផុតនៅរាជធានីខេត្តទាំង៩ (តោន/ថ្ងៃ)..........២១
រូបភាពទី៣ គម្លាតខុសគ្នារវាងតម្លៃមធ្យមនៃបន្លែផលិតក្នុងស្រុក និងបន្លែនាំចូលពីបរទេស (រៀល/គ.ក) .. ២២
រូបភាពទី៤ បរិមាណបន្លែផ្គត់ផ្គង់ពីប្រភពនីមួយៗនៅក្នុងរាជធានីខេត្តទាំង៩ (តោន/ថ្ងៃ)...................... ២៣
រូបភាពទី៥ ប្រភេទបន្លែតាមប្រភពផ្គត់ផ្គង់នីមួយៗនៅក្នុងរាជធានីខេត្តទាំង៩ (គិតជាភាគរយ) ...............២៤
រូបភាពទី៦ ប្រភេទបន្លែនាំមុខគេទាំង១០មុខដែលផលិតក្នុងស្រុកច្រើនជាងគេបំផុត
ក្នុងរាជធានីខេត្តទាំង៩ ..........................................................................................២៥
រូបភាពទី៧ ប្រភេទបន្លែនាំមុខគេទាំង១០មុខដែលនាំចូលពីបរទេសច្រើនជាងគេបំផុត
ក្នុងរាជធានីខេត្តទាំង៩ ..........................................................................................២៦
រូបភាពទី៨ បរិមាណតម្រូវការបន្លែបន្ថែមរបស់អាជីវករលក់បន្លែនៅក្នុងរាជធានីខេត្តទាំង៩ (គ.ក/ថ្ងៃ) ...... ២៧

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ បរិមាណតម្រូវការបន្លែតាមប្រភពផ្គត់ផ្គង់នីមួយៗនៅរាជធានីខេត្តទាំង៩
ឧបសម្ព័ន្ធទី២ បរិមាណតម្រូវការបន្លែតាមប្រភេទ និងប្រភពផ្គត់ផ្គង់នីមួយៗនៅរាជធានីខេត្តទាំង៩ក្នុងមួយថ្ងៃ
ឧបសម្ព័ន្ធទី៣ តម្លៃបន្លែតាមប្រភពផ្គត់ផ្គង់នីមួយៗនៅរាជធានីខេត្តទាំង៩ (រៀល/គ.ក)
ឧបសម្ព័ន្ធទី៤ តំបន់សិក្សាស្រាវជ្រាវ
ឧបសម្ព័ន្ធទី៥ កម្រងរូបភាព

# សេចក្តីផ្តើម

## ១. ស្ថានភាពទូទៅ

ប្រទេសកម្ពុជាគឺជាប្រទេសមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានផ្ទៃដីសរុប១៨១០៣៥គីឡូម៉ែត្រការេ ផ្ទៃដីប្រមាណ២៥.០៦៩គីឡូម៉ែត្រការេជាដីទំនាប និងផ្ទៃដីប្រមាណ៦៧.៦៦៨គីឡូម៉ែត្រការេត្រូវបានហ៊ុំព័ទ្ធទៅដោយបឹងទន្លេសាប ដែលជាប្រភពទឹកដ៏សំខាន់បន្ទាប់ពីទន្លេមេគង្គដែលបានហូរនាំដីល្បាប់ដ៏មានជីជាតិសំរាប់ការធ្វើកសិកម្ម ដែលនាំឱ្យប្រទេសនេះជាប់ឈ្មោះជាប្រទេសកសិកម្មតាំងពីអតីតកាល។ វិស័យកសិកម្មនៅកម្ពុជាត្រូវបានចាត់ទុកជាវិស័យអាទិភាពដើរតួនាទីយ៉ាងសំខាន់ ជាវាលបៃតងរបស់ប្រទេសដែលបានរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេស ក៏ដូចជាកាត់បន្ថយភាពក្រីក្រស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។

ប្រទេសកម្ពុជាមានផ្ទៃដីល្អបំផុតសម្រាប់ការបង្កបង្កើនផល ឬការដាំដំណាំផ្សេងៗសម្រាប់ប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពលរដ្ឋ ហើយពលរដ្ឋភាគច្រើនរស់នៅដោយពឹងពាក់ទៅលើវិស័យនេះ។ ជាក់ស្តែងវិស័យកសិកម្មបានរួមចំណែកប្រមាណ២០,៨ភាគរយនៃផលិតផលជាតិសរុបឆ្នាំ២០១៩ ដែលនៅក្នុងនោះអនុវិស័យកសិកម្មចំនួន២ ដែលបានរួមចំណែកច្រើនក្នុងការជំរុញវិស័យកសិកម្មឱ្យមានការរីកចម្រើន និងធ្វើឱ្យសេដ្ឋកិច្ចមានការអភិវឌ្ឍន៍នោះគឺ ផ្នែកដំណាំ និងផ្នែកជលផល។ ថ្វីត្បិតតែផ្នែកដំណាំបានរួមចំណែកច្រើនហើយធ្វើអោយវិស័យកសិកម្មរីកចម្រើន និងសេដ្ឋកិច្ចជាតិមានការអភិវឌ្ឍន៍ក៏ពិតមែន ប៉ុន្តែបើក្រឡេកទៅមើលភាពជាក់ស្តែង ការដាំដុះបន្លែហាក់មានចំនួនតិចតួច ដែលធ្វើឲ្យផលបន្លែមិនអាចផ្គត់ផ្គង់ទៅតាមតម្រូវការនៅក្នុងប្រទេសកម្ពុជាបានឡើយ។ ការផ្គត់ផ្គង់បន្លែមិនគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារនេះហើយ ដែលជំរុញឲ្យប្រទេសកម្ពុជាចំណាយថវិកាប្រហែល២០០លានដុល្លារក្នុងមួយឆ្នាំៗ ក្នុងការនាំចូលបន្លែគ្រប់ប្រភេទប្រមាណ៥៥ភាគរយ ពីបរទេស រួមមាន ប្រទេសវៀតណាម ថៃ និង ចិន។ ខណៈ កសិករខ្មែរមានសមត្ថភាពផលិតបន្លែបានប្រហែល៤៥ភាគរយតែប៉ុណ្ណោះ ដែលជាហេតុនាំឲ្យរាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ២០១៦បានសម្រេចផ្តល់ឱ្យក្រសួងកសិកម្មនូវទឹកប្រាក់ចំនួន២០លានដុល្លារអាមេរិកក្នុងកម្មវិធីជំរុញផលិតកម្មស្បៀងឆ្នាំ២០១៦–២០១៨ ដំណាក់កាលទី១ ដែលក្នុងនោះថវិកាមួយចំនួនផ្តោតទៅលើការពង្រឹងផលិតកម្មបន្លែក្នុងប្រទេសកម្ពុជាតែម្តង បើយោងតាមមជ្ឈមណ្ឌលសិក្សាគោលនយោបាយ(CPS)។

## ២. ចំនោទបញ្ហា

បញ្ហាដែលប្រទេសកម្ពុជាត្រូវចំណាយទឹកប្រាក់រហូតដល់ប្រមាណ២០០លានដុល្លារ ក្នុងការនាំចូលបន្លែគ្រប់ប្រភេទប្រមាណ៥៥ភាគរយពីបរទេសជារៀងរាល់ឆ្នាំ ខណៈដែលកសិករខ្មែរមានសមត្ថភាពផលិតបន្លែ

បានត្រឹមតែប្រហែល៤៥ភាគរយនេះ ត្រូវបានគេមើលឃើញថា បានជះឥទ្ធិពលយ៉ាងខ្លាំងលើអ្នកប្រើប្រាស់ និងអ្នកបរិភោគនៅក្នុងប្រទេសកម្ពុជាក៏ដូចជាសេដ្ឋកិច្ចជាតិផងដែរ។ ប្រការនេះទាមទារឲ្យកសិករបង្កើនការដាំដុះបន្លែគ្រប់ប្រភេទដែលអាចដាំដុះបានក្នុងប្រទេស និងមានសក្តានុពលប្រកួតប្រជែងខ្ពស់នៅក្នុងស្រុក ដើម្បីបំពេញតម្រូវការបន្លែដែលកំពុងខ្វះខាត។ ដូច្នេះកសិករត្រូវដឹងថាមានបន្លែប្រភេទណាខ្លះ និងបរិមាណប៉ុន្មានដែលកំពុងខ្វះខាតមិនគ្រប់តាមតម្រូវការទីផ្សារបន្លែនៅកម្ពុជា បន្លែប្រភេទណាខ្លះដែលកំពុងមានសក្តានុពលដាំដុះ និងមានការប្រកួតប្រជែងខ្ពស់ក្នុងស្រុក បន្លែណាខ្លះដែលមិនអាចដាំដុះបានក្នុងស្រុក បន្លែប្រភេទណាខ្លះកំពុងត្រូវការបន្ថែម ហើយត្រូវការបន្ថែមក្នុងបរិមាណប៉ុន្មាន មូលហេតុអ្វីដែលធ្វើឱ្យបន្លែទាំងនោះខ្វះខាតមិនគ្រប់តម្រូវការទីផ្សារ មានដំណោះស្រាយអ្វីខ្លះ រួមទាំងកត្តានានាដែលលើកទឹកចិត្តកសិករឲ្យចូលរួមក្នុងការដាំដុះបន្លែឲ្យកាន់តែច្រើន។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាលើប្រធានបទ "ការលើកទឹកចិត្តកសិករក្នុងការដាំដំណាំបន្លែដើម្បីផ្សាភ្ជាប់ទៅនឹងទីផ្សារ" មានគោលបំណងធ្វើឱ្យមានការរីកចម្រើនផ្នែកដំណាំបន្លែនៅកម្ពុជា ដោយធ្វើការសិក្សាអំពីវិស័យកសិកម្មបន្លែនៅកម្ពុជា ស្វែងរកតម្រូវការទីផ្សារបន្លែក្នុងប្រទេស ហើយជំរុញទឹកចិត្តកសិករឱ្យងាកមកដាំដំណាំបន្លែ ដើម្បីផ្គត់ផ្គង់ទីផ្សារបន្លែក្នុងស្រុកដែលកំពុងខ្វះខាត លើកកម្ពស់កម្រិតជីវភាពគ្រួសារជួយជំរុញកំនើនសេដ្ឋកិច្ចជាតិ កាត់បន្ថយការចំណាយរបស់រដ្ឋក្នុងការនាំចូលបន្លែពីក្រៅប្រទេស កាត់បន្ថយហានិភ័យសុខភាពដោយសារការបរិភោគបន្លែនាំចូលដែលមានសារធាតុគីមី ដោយផ្តល់នូវជម្រើសបច្ចេកទេសដាំដុះបន្លែសុវត្ថិភាពនានាដល់កសិករ។

## ៤. ទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្តោតទៅលើការលើកទឹកចិត្តកសិករឱ្យងាកមកយកចិត្តទុកដាក់លើការដាំដុះដំណាំបន្លែតែប៉ុណ្ណោះ ដោយមិនរួមផ្សំដំណាំផ្សេងទៀតនោះទេ ហើយការលើកទឹកចិត្តកសិករឱ្យដាំដំណាំបន្លែនេះ ធ្វើការលើកទឹកចិត្តតែចំពោះបន្លែដែលអាចដាំដុះលើស្ថានភាពដី និងលក្ខខណ្ឌអាកាសធាតុនៅកម្ពុជាតែប៉ុណ្ណោះ ចំពោះដំណាំបន្លែដែលមិនអាចដាំដុះលើស្ថានភាពដី និងលក្ខខណ្ឌអាកាសធាតុប្រទេសកម្ពុជាទេ យើងនៅតែគាំទ្រចំពោះការនាំចូលដើម្បីបំពេញតម្រូវការក្នុងស្រុកដដែរ។ ចំពោះការស្រាវជ្រាវឯកសារ គឺនាងខ្ញុំធ្វើការសិក្សាស្រាវជ្រាវតែលើឯកសារដែលមានខ្លឹមសារពាក់ព័ន្ធនឹងកសិកម្មបន្លែនៅកម្ពុជា ទីផ្សារបន្លែ និងធ្វើការចុះទៅសម្ភាសន៍កសិករដោយផ្ទាល់ប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

- យល់ដឹងពីវិស័យកសិកម្មដំណាំបន្លែនៅកម្ពុជា
- យល់ដឹងពីទីផ្សារបន្លែនៅកម្ពុជានាពេលបច្ចុប្បន្ន
- យល់ដឹងពីវិធីសាស្ត្រដាំដុះបន្លែនានាដែលទទួលបានផលច្រើន សុវត្ថិភាព
- ទទួលបានចំនេះដឹង និងបទពិសោធន៍ក្នុងការសិក្សាស្រាវជ្រាវ ចងក្រងឯកសារ
- ទទួលបានបទពិសោធន៍ក្នុងការទំនាក់ទំនងសង្គម ដំណើរការឯកសាររដ្ឋបាលនានា
- បានជាឯកសារជំនួយក្នុងការសិក្សាស្វែងយល់ពីកសិកម្មដំណាំបន្លែនៅកម្ពុជានិងជាគម្រូសំរាប់ការងារស្រាវជ្រាវបន្ត។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ នាងខ្ញុំមានតម្រូវការព័ត៌មានដូចជា ស្ថានភាពវិស័យកសិកម្មដំណាំបន្លែនៅកម្ពុជា ស្ថានភាពទីផ្សាបន្លែនៅកម្ពុជា ស្ថិតិផលិតផលបន្លែដាំដុះក្នុងស្រុក ស្ថិតិបន្លែនាំចូល វិធីសាស្ត្រដាំដុះបន្លែ ការអនុវត្តការដាំដុះបន្លែសុវត្ថិភាព និងសរីរាង្គ គំរោងនានារបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យកសិកម្មដំណាំបន្លែនៅកម្ពុជា និងព័ត៌មានមួយចំនួនទៀត។

- ប្រភពទិន្នន័យចម្បង៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការសម្ភាសន៍កសិករ
- ប្រភពទិន្នន័យបន្ទាប់បន្សំ៖ បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាលសារព័ត៌មាននានា ឯកសារដែលបានមកពីគេហទំព័រនានានិងតាមរយៈប្រព័ន្ធអ៊ីនធើណែតជាដើម។

- ការប្រមូលព័ត៌មានចែកចេញជា២របៀប៖
- ទី១ គឺការចុះទៅស្រាវជ្រាវឯកសារនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងចុះសម្ភាសន៍កសិករ
- ទី២ គឺការប្រើប្រាស់បច្ចេកវិទ្យាដើម្បីទាញយកឯកសារ និងទិន្នន័យផ្សេងៗពីប្រព័ន្ធអ៊ីនធើណែត
- ដំណើរការនៃការជ្រើសរើសគំរូតាងគឺធ្វើការជ្រើសរើសកសិករដែលមានសក្តានុពលដាំដុះ និងមានចំណូលខ្ពស់នៅក្នុងឃុំមកធ្វើការសម្ភាសន៍ ប្រមូលបទពិសោធន៍ដែលធ្វើឲ្យកសិករនោះដាំដុះបន្លែបានជោគជ័យ បានផលច្រើន និងមានទីផ្សារ។

វិធីសាស្ត្រវិភាគទិន្នន័យគឺធ្វើការវិភាគតាមបែបពិពណ៌នា និងវិភាគតាមបែបវិភាគSWOTដោយសិក្សាពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងនៃទីផ្សារបន្លែនៅកម្ពុជា និងការដាំដុះបន្លែតាមបែបបន្លែសរីរាង្គនិងសុវត្ថិភាព។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ក្នុងការចងក្រង និងរៀបចំសារណាបទនេះចែកចេញជា ៤ ជំពូកដូចខាងក្រោម៖

**-ជំពូកទី១ រំលឹកទ្រឹស្តី:** យើងសិក្សាទៅលើនិយមន័យ និងទ្រឹស្តីផ្សេងៗ ដែលនឹងត្រូវលើកយកមកប្រើប្រាស់នៅក្នុងសារណាបញ្ចប់វគ្គសិក្សានេះ។

**-ជំពូកទី២ ទិដ្ឋភាពទូទៅជុំវិញទីផ្សារបន្លែនៅកម្ពុជា:** យើងនឹងធ្វើការសិក្សាទៅលើទីផ្សារបន្លែ ដែលមាននៅកម្ពុជាបច្ចុប្បន្ន ដែលក្នុងនោះយើងស្រាវជ្រាវទៅលើតម្រូវការបន្លែក្នុងស្រុក ការរែកញែករកផលដែលផលិតបានក្នុងពេលបច្ចុប្បន្ន និងទំហំទីផ្សារបន្លែដែលនៅសល់ ។

**-ជំពូកទី៣ វិធីសាស្ត្រដាំដុះបន្លែនៅកម្ពុជា:** យើងនឹងសិក្សាពីវិធីសាស្ត្រដាំដុះបន្លែតាមបែបសរីរាង្គ និងសុវត្ថិភាពដែលមានប្រសិទ្ធភាពខ្ពស់ រួមទាំងការអនុវត្តការដាំដុះបន្លែផ្ទាល់នៅឃុំគោកគង់លិច ស្រុកកញ្ជៀច ខេត្តព្រៃវែង។

**-ជំពូកទី៤ បកគំហើញ និងការវិភាគ:** យើងនឹងប្រៀបធៀប រែកញែករកផលប្រយោជន៍នៃការដាំដុះបន្លែ ធ្វើការវិភាគរកចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគម្រាមកំហែងនៃទីផ្សារបន្លែនៅកម្ពុជា និងការដាំដុះបន្លែសរីរាង្គនិងសុវត្ថិភាព រកកត្តាលើកទឹកចិត្តក៏ដូចជាកត្តាជម្រុញប្រជាពលរដ្ឋខ្មែរឱ្យមានទឹកចិត្តដាំដុះបន្លែដោយខ្លួនឯង ដើម្បីបំពេញតម្រូវការទីផ្សារជៀសវាងបន្លែនាំចូល។

**-សេចក្តីសន្និដ្ឋាន និងអនុសាសន៍:** ធ្វើការសន្និដ្ឋានរួមទៅលើការស្រាវជ្រាវ ព្រមទាំងផ្តល់អនុសាសន៍មួយចំនួនដើម្បីកែលំអ និងលើកទឹកចិត្តកសិករឱ្យដាំបន្លែបំពេញទីផ្សារជំនួសការនាំចូល។

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. និយមន័យ និងទ្រឹស្តីនៃការលើកទឹកចិត្ត

### ១.១.១ និយមន័យនៃការលើកទឹកចិត្ត

ការលើកទឹកចិត្ត គឺជាដំណើរការដែលធ្វើឱ្យមានថាមពលទៅលើឥរិយាបថ និងជាលក្ខណៈចិត្តសាស្ត្ររបស់មនុស្សទៅលើកម្រិតនៃការខិតខំប្រឹងប្រែងព្រមទាំងការប្តេជ្ញាចិត្តរបស់មនុស្ស។ គ្រប់គ្នាគឺសុទ្ធតែត្រូវការការលើកទឹកចិត្តទាំងក្នុងក្របខណ្ឌបំពេញការងារនិងក្នុងជីវភាពឯកជន។ ផ្អែកលើអាជីព ការលើកទឹកចិត្តជាកត្តាសំខាន់ជួយឲ្យការដឹកនាំ និងការអនុវត្តន៍ការងារទទួលបានជោគជ័យ។ ការលើកទឹកចិត្តបានជំរុញឲ្យបុគ្គលម្នាក់ៗមានឆន្ទៈ ក្នុងការបំពេញការងារប្រកបដោយ ការផ្តួចផ្តើម ការទទួលខុសត្រូវ និងការតស៊ូជម្នះដើម្បីសម្រេចបាននូវលទ្ធផលតាមគោលដៅដែលបានកំណត់ ហើយវាក៏ជាការចាប់អារម្មណ៍នៅក្នុងការងារនិងខិតខំប្រឹងប្រែងដើម្បីឱ្យការងារមានភាពជោគជ័យផងដែរ។

### ១.១.២ ទ្រឹស្តីនៃការលើកទឹកចិត្ត

ការលើកទឹកចិត្តពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការជំរុញឱ្យទទួលបានលទ្ធផលជោគជ័យ។ ការលើកទឹកចិត្តមានអត្ថន័យទូលំទូលាយនិងមានភាពខុសផ្លែកគ្នាទៅតាមសម័យកាលនិងការយល់ឃើញរបស់មនុស្សម្នាក់ៗ។ អ្នកប្រាជ្ញមួយចំនួនបានលើកឡើងនូវអត្ថន័យ ក៏ដូចជាទស្សនៈខុសៗគ្នាចំពោះការលើកទឹកចិត្តដូចខាងក្រោម៖

**ក. ទ្រឹស្តីរបស់លោក Gary P. Latham**

តាមលោក Gary P. Latham បានឱ្យទស្សនៈថា ការលើកទឹកចិត្តគឺជាការស្ម័គ្រចិត្តដាក់កម្រិតខ្ពស់នៃការខិតខំប្រឹងប្រែង ដើម្បីសម្រេចគោលបំណងផ្ទាល់ខ្លួន។[1]

**ខ. ទ្រឹស្តីរបស់លោក Craig C. Pinder**

លោក Craig C. Pinder មានទស្សនៈថា ការលើកទឹកចិត្តគឺជួយឱ្យមានចំណង់ចង់ដឹង ចង់ធ្វើ មានសេចក្តីពេញចិត្ត ហើយជាហេតុនាំឱ្យមានភាពជោគជ័យ។[2]

**គ. ទ្រឹស្តីរបស់លោក Norman Featherនិង លោក Atkinson John**

លោក Norman Feather និងលោក Atkinson John បានមានទស្សនៈថាការលើកទឹកចិត្តគឺជារឿងដ៏

[1] Latham P.G., (2012), *Work Motivation: History, Theory, Research, and Practice*. Los Angeles: Sage.

[2] Pinder, C. C. (1998). Work motivation in organizational behavior. Upper Saddle River NJ: Practice Hall.

សំខាន់មួយ ដែលធ្វើឱ្យបុគ្គលសម្តែងនូវព្រឹត្តិកម្ម ឬទង្វើដដែរៗ។ ព្រឹត្តិកម្មរបស់បុគ្គលភាគច្រើនជាការអនុវត្ត និងព្យាយាមដើម្បីទទួលបានការតបស្នងចំពោះការលើកទឹកចិត្តនោះ។[3]

**ឃ. ទ្រឹស្តីនៃការលើកទឹកចិត្ត របស់លោក David C. McClelland**[4]

ទ្រឹស្តីនៃការលើកទឹកចិត្តរបស់លោក David C. McClelland បានរកឃើញថា ការលើកទឹកចិត្តមិនមែនជារឿងសាមញ្ញធម្មតាៗទេ វាមានប្រសិទ្ធិភាពខ្ពស់ដល់ការបំពេញការងារដែលគេអាចនិយាយបានថាវាជាបាតុភូតមួយនឹកស្មានមិនដល់នៅពេលខ្លះទៀតផង។

សរុបមកវិញ អ្នកប្រាជ្ញនិងអ្នកស្រាវជ្រាវជាច្រើនបានបង្កើតទ្រឹស្តីផ្សេងៗគ្នា ដើម្បីពន្យល់អំពីការលើកទឹកចិត្ត។ បើពិនិត្យមើលគំនិតសំខាន់ៗនៅពីក្រោយទ្រឹស្តីនីមួយៗ អ្នកអាចទទួលបានការយល់ដឹងកាន់តែប្រសើរអំពីការលើកទឹកចិត្តទាំងមូល។ ការលើកទឹកចិត្តគឺជាកម្លាំងដែលផ្តួចផ្តើមណែនាំ និងធ្វើឱ្យអ្នករក្សាឥរិយាបថមិនបោះបង់ការប្រឹងប្រែង ដើម្បីសម្រេចគោលដៅ។

**១.១.៣ ប្រភេទនៃការលើកទឹកចិត្ត**

ការលើកទឹកចិត្តមានពីរប្រភេទគឺ៖ ការលើកទឹកចិត្តមានលក្ខណៈវិជ្ជមាន និងលក្ខណៈអវិជ្ជមាន។[5]

ការលើកទឹកចិត្តជាលក្ខណៈវិជ្ជមាន គឺការលើកទឹកចិត្តដោយសារតែការទទួលបាននូវផលប្រយោជន៍ និងការពេញចិត្តដោយអារម្មណ៍ ភាពជោគជ័យ ការលើកសរសើរ និងគោរពឱ្យតំលៃ ជាដើម។ ឯការលើកទឹកចិត្តមានលក្ខណៈអវិជ្ជមានក៏មានឥទ្ធិពលទៅលើអ្នកប្រព្រឹត្តផងដែរដូចជា ការភ័យខ្លាចចំពោះការដាក់ពិន័យ ការខាត់បង់ រឺការបាត់បង់អ្វីមួយនៅក្នុងការងាររបស់ខ្លួន។ ការលើកទឹកចិត្តក្នុងលក្ខណៈអវិជ្ជមានមួយចំនួនមានរាប់បញ្ចូលទាំងការពិន័យពីស្ថាប័នណាមួយទៀតផង។ ឧទាហរណ៍ថាបុរសឈ្មោះ «សុខ» បានខ្ចីប្រាក់ធនាគារមកប្រកបការងាររកស៊ី។ ដូច្នេះការលើកទឹកចិត្តអវិជ្ជមានរបស់គាត់គឺ គាត់មានការភ័យខ្លាចថា បើការងាររកស៊ីរបស់គាត់មានលក្ខណៈមិនសូវល្អ ឬខាត់បង់នោះគាត់មិនមានប្រាក់សម្រាប់បង់សងទៅធនាគារវិញទេ។ ដូចនេះគាត់នឹងខិតខំប្រឹងប្រែងប្រកបរបររកស៊ី និងធ្វើការរកប្រាក់។ ការលើកទឹកចិត្តទាំងពីរប្រភេទមិនថាការលើកទឹកចិត្តបែបវិជ្ជមានឬអវិជ្ជមានក្តី សុទ្ធតែជំរុញប្រសិទ្ធភាពការងារ និងការខិតខំប្រឹងប្រែងក្នុងការបំពេញការងារ មុខរបររកស៊ីឱ្យទទួលបានជោគជ័យជានិច្ច។

**១.១.៤. សារៈសំខាន់នៃការលើកទឹកចិត្ត**

---

[3] John A., Feather N., (1974), A Theory of Achievement Motivation (6 ed.), Krieger Pub Co.

[4] McClelland C.D., (1953), The Achievement Motive. New York: Appleton-Century-Crofts.

[5] khmerkhasikor. (2017). ប្រភេទនៃការលើកទឹកចិត្ត. Khmer Agriculture. Retrieved September 1, 2020, from https://khmerkhasikor.blogspot.com/2017/03/blog-post.html

ការលើកទឹកចិត្តពិតជាមានសារៈសំខាន់ណាស់សំរាប់ទង្វើ ឬសកម្មភាពការងារនានារបស់មនុស្សម្នាក់ៗ ពីព្រោះថាបើមានការលើកទឹកចិត្ត មនុស្សនឹងៈ

-មានលះបង់ខ្ពស់ទាំងកម្លាំងកាយ កម្លាំងចិត្តនិងពេលវេលា ដើម្បីឲ្យសម្រេចលទ្ធផលការងារ

-មានការពុះពារ និងខិតខំប្រឹងប្រែងរាល់កិច្ចការលំបាក និងបញ្ហានានា

-យកចិត្តទុកដាក់បំពេញការងារ និងយល់ព្រមប្រឈមរាល់គ្រប់បញ្ហាលំបាក។

ប៉ុន្តែបើខ្វះការលើកទឹកចិត្តវិញនោះនឹងធ្វើឲ្យមនុស្សៈ

-មិនមានទឹកចិត្តធ្វើការងារ ស្ពឹកស្រពន់និងព្រងើយកន្តើយក្នុងការបំពេញការងារ

-ងាយចុះចាញ់ និងបោះបង់នៅពេលជួបការលំបាកក្នុងការងារ

-មិនខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការបំពេញការងារ

-តែងតែរកលេស មិនតស៊ូ មិនព្យាយាម...។

## ១.២. ទំនាក់ទំនងនៃការលើកទឹកចិត្ត និងទ្រឹស្តីនៃការរំពឹងទុក

ការរំពឹងទុកគឺជាជំនឿមួយដែលមនុស្សម្នាក់ជឿថាមានលទ្ធភាពផលិតលទ្ធផល។

ទ្រឹស្តីនៃការរំពឹងទុកគឺជាដំណើរការដែលបុគ្គលនឹងសម្រេចចិត្តមានឥរិយាបថ ឬធ្វើសកម្មភាពនៅក្នុងវិធីជាក់លាក់មួយ ដោយសារតែពួកគេជឿថាលទ្ធផលនៃឥរិយាបថដែលបានជ្រើសរើសនឹងកើតមាន។[6]

ទំនាក់ទំនងរវាងទ្រឹស្តីនៃការរំពឹងទុក និងការលើកទឹកចិត្តបានបង្ហាញថា នៅពេលយើងគិតអំពីលទ្ធផលនាពេលអនាគត យើងនឹងបង្កើតការរំពឹងទុកខុសគ្នាៗអំពីអ្វីដែលយើងគិតថានឹងកើតឡើង។ នៅពេលយើងរំពឹងថានឹងមានលទ្ធផលវិជ្ជមាន យើងនឹងមានអារម្មណ៍ថាមានការជម្រុញចិត្ត ឬមានការលើកទឹកចិត្តក្នុងការបំពេញការងារ ដើម្បីសម្រេចលទ្ធផលដូចដែលបានរំពឹងទុកនោះ។

ប្រសិនបើមនុស្សមានអារម្មណ៍ថាពួកគេខ្វះជំនាញ ឬចំណេះដឹងគ្រប់គ្រាន់ ឬគ្មានជំនឿចិត្ត ដើម្បីសម្រេចបាននូវលទ្ធផលដែលចង់បាននោះទេ ពួកគេនឹងមិនសូវមានការព្យាយាមក្នុងការងារនោះទេ។ ប៉ុន្តែនៅពេលដែលមនុស្សនោះបានរំពឹងពីលទ្ធផលដែលគេនឹងទទួលបាន នាំឱ្យវាក្លាយជាការលើកទឹកចិត្តពីខាងក្នុងដែលធ្វើឱ្យមនុស្សនោះជឿជាក់ថាខ្លួនមានសមត្ថភាព ហើយព្យាយាមអស់ពីកម្លាំងកាយចិត្តដើម្បីធ្វើឱ្យបានសម្រេចជោគជ័យ។

## ១.៣. និយមន័យទីផ្សារ

[6] Oliver L. R., (1974). Expectancy Theory Predictions of Salesmen's Performance. Journal of Marketing Research 11(3), 243-253.

### ១.៣.១. និយមន័យទីផ្សារ

#### ក. ទីផ្សារក្នុងន័យធម្មតា

ទីផ្សារ គឺជាកន្លែងដោះដូរផលិតផលរវាងអ្នកទិញនិងអ្នកលក់ក្នុងក្របខ័ណ្ឌតំបន់ភូមិសាស្ត្រមួយក្នុងរយៈពេលកំណត់ និងតាមតម្លៃសមស្របមួយ។[7] តាមន័យផ្សេងមួយបែបទៀតទីផ្សារគឺជាក្រុមអតិថិជនដែលកំពុងមានកម្លាំងទិញ និងមានតម្រូវការដែលមិនទាន់បានបំពេញ។ ផលិតផលដែលត្រូវបានដោះដូរនៅលើទីផ្សារអាចជាទំនិញ សេវាកម្ម ឬអាចជាធនធាន។ និយមន័យទីផ្សារមានលក្ខណៈខុសគ្នាតាមសម័យកាលផងដែរ៖

-តាមបែបបុរាណ៖ ទីផ្សារ គឺជាកន្លែងដែលស្តែងចេញនូវដំណើរការទិញ លក់(ដោះដូរ) ជាកន្លែងដែលអ្នកទិញនិងអ្នកលក់ជួបគ្នាដើម្បីទិញលក់ផលិតផល។

-តាមបែបទំនើប៖ ទីផ្សារ គឺជាសមរភូមិអាជីវកម្ម ជាកន្លែងដែលអាជីវករ ឬក្រុមហ៊ុនប្រមើលមើលតម្រូវការរបស់សង្គមនិងវាយតម្លៃអាជីវកម្មរបស់ខ្លួន។[8]

#### ខ. ទីផ្សារក្នុងន័យសេដ្ឋកិច្ច

ទីផ្សារ គឺជាការដោះដូររវាងអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា និងអ្នកមានតម្រូវការនូវរាល់ទំនិញនិងសេវាកម្មជាមួយនឹងបរិមាណនិងតម្លៃសមរម្យក្រោមការប្រកួតប្រជែង បើទោះបីជាអ្នកផ្គត់ផ្គង់និងអ្នកមានតម្រូវការ បានជួបមុខគ្នា ឬពុំបានជួបមុខគ្នាក្នុងកន្លែងកំណត់ណាមួយក៏ដោយ។ ចំណែកពាក្យថា«ទីផ្សារ» គឺអនុវត្តចំពោះគ្រប់ទ្រព្យសកម្មសេដ្ឋកិច្ច ដែលជាកម្មវត្ថុនៃការធ្វើពាណិជ្ជកម្ម ផ្សារមូលធន ផ្សារចលនវត្ថុនិងអចលនវត្ថុ ព្រមទាំងផ្សារពលកម្មផងដែរ។ន័យម៉្យាងទៀត ទីផ្សារ គឺជាប្រភពរីកចម្រើននៃជីវភាពសេដ្ឋកិច្ចសង្គម ពោលគឺជាកន្លែងរៀបចំឡើងសម្រាប់ធ្វើការទំនាក់ទំនងរវាងអ្នកលក់ ផលិតករ ឬអ្នកផ្គត់ផ្គង់ និងអ្នកទិញ អតិថិជន ឬអ្នកមានតម្រូវការ អ្នកប្រើប្រាស់ ដើម្បីដោះដូរទំនិញនិងសេវាក្រោមតំលៃព្រមព្រៀងមួយ។[9]

## ១.៤. ច្បាប់តម្រូវការ និងច្បាប់ផ្គត់ផ្គង់

### ១.៤.១ តម្រូវការ និងច្បាប់តម្រូវការ[10]

តម្រូវការបង្ហាញពីបំណងចង់បានទំនិញ ឬសេវាកម្ម និងលទ្ធភាពក្នុងការទូទាត់ដើម្បីទទួលបានទំនិញ

---

[7] សីលធម៌. (2018). និយមន័យទីផ្សារ. KhSearch | ចែករំលែកចំណេះដឹង. Retrieved July 8, 2020, from https://www.khsearch.com/qna/11470

[8] សីលធម៌. (2018). និយមន័យទីផ្សារ. KhSearch | ចែករំលែកចំណេះដឹង. Retrieved July 8, 2020, from https://www.khsearch.com/qna/11470

[9] SarithKhem. (2018, May 16). និយមន័យទីផ្សារ. khemsaritheducation. https://khemsaritheducation.wordpress.com/2018/05/16/ចូរឲ្យនិយមន័យទីផ្សារ/

[10] ម៉ម ចរិយាវុធ និងងួន ហេង, "សេដ្ឋកិច្ចនយោបាយ", បោះពុម្ពលើកទី៥, ឆ្នាំ២០១៦, ទំព័រទី៦៨

ឬសេវាកម្មនោះ។ អ្នកសេដ្ឋវិទូនិយាយថា អ្នកគ្មានតម្រូវការជាក់ស្តែងនោះទេ បើអ្នកចង់បានរបស់អ្វីមួយ តែមិនមានលទ្ធភាពដើម្បីទិញវា។ ផ្ទុយទៅវិញ បើសិនអ្នកចង់បានរបស់អ្វីមួយ ហើយអ្នកមានលទ្ធភាពក្នុងការទិញវា នោះន័យថាអ្នកមានតម្រូវការលើវាពិតប្រាកដ។

ថ្លៃ ឬ តម្លៃគឺជាកត្តាដ៏សំខាន់មួយដែលមានឥទ្ធិពលទៅលើតម្រូវការ។ តាមច្បាប់តម្រូវការបានអះអាងថាបើកត្តាឥទ្ធិពលផ្សេងៗទៀតមិនប្រែប្រួល ហើយថ្លៃទំនិញប្រែប្រួល នោះតម្រូវការក៏ប្រែប្រួលតាមនោះដែរ។ បើថ្លៃទំនិញកាន់តែធ្លាក់ចុះ មានន័យថាបរិមាណតម្រូវការទំនិញកាន់តែកើនឡើង។ ផ្ទុយមកវិញ កាលណាថ្លៃទំនិញកើនឡើង នាំឱ្យបរិមាណតម្រូវការទំនិញនោះថយចុះមកវិញ។

ក្រៅពីកត្តាថ្លៃ កត្តាផ្សេងៗទៀតក៏មានឥទ្ធិពលលើតម្រូវការដែរ។ កត្តាផ្សេងៗទៀតដែលមានឥទ្ធិពលលើតម្រូវការរួមមាន៖

- ចំណូល៖ កាលណាចំណូលកើនឡើង បរិមាណតម្រូវការនឹងកើនឡើងដែរ កាលណាចំណូលថយចុះ បរិមាណតម្រូវការក៏ថយចុះតាមនោះដែរ។
- ទំហំទីផ្សារ៖ ប្រសិនបើចំនួនអ្នកប្រើប្រាស់កើនឡើងឬថយចុះ នោះទំហំទីផ្សារក៏ប្រែប្រួលតាមដែរ។ ការប្រែប្រួលនេះធ្វើឱ្យមានឥទ្ធិពលដល់តម្រូវការទិញផលិតផលលើទីផ្សារ។
- ចំណូលចិត្តរបស់អ្នកប្រើប្រាស់៖ ការពេញចិត្តរបស់អ្នកប្រើប្រាស់ ឬការធ្វើឱ្យអតិថិជនជាប់ចិត្តទៅលើទំនិញរបស់ខ្លួន ក៏ធ្វើឱ្យមានការប្រែប្រួលតម្រូវការទំនិញនៅថ្លៃណាមួយផងដែរ។
- ការសង្ឃឹមរបស់អ្នកប្រើប្រាស់៖ ក្តីសង្ឃឹមរបស់អ្នកប្រើប្រាស់ទៅលើទំនិញក្នុងពេលបច្ចុប្បន្ន ក៏មានឥទ្ធិពលលើការទិញទំនិញផងដែរ។
- ទំនិញជំនួស៖ គឺជាទ្រព្យ ឬសេវាកម្មដែលអាចប្រើប្រាស់ជំនួសឱ្យទ្រព្យនិងសេវាដទៃទៀត ដើម្បីបំពេញចំណង់របស់អ្នកប្រើប្រាស់។
- ទំនិញបំពេញគ្នា៖ នៅពេលការប្រើប្រាស់ទំនិញមួយ ធ្វើឱ្យមានការកើនការប្រើប្រាស់ទំនិញមួយទៀត ទំនិញទាំងពីរនេះត្រូវបានគេហៅថាទំនិញបំពេញគ្នា។

ក្រៅពីកត្តាថ្លៃដែលមានឥទ្ធិពលទៅលើតម្រូវការទំនិញ តម្រូវការអាចមានប្រែប្រួលបណ្តាលមកពីកត្តាខាងលើទាំង៦យ៉ាងនេះ។

### ១.៤.២ ផ្គត់ផ្គង់ និងច្បាប់ផ្គត់ផ្គង់

ការផ្គត់ផ្គង់ គឺជាលទ្ធភាពដែលអាចផ្តល់ជូន ឬបំពេញនូវរាល់តម្រូវការរបស់អ្នកទិញទៅតាមតម្រូវការទីផ្សារ ដែលការផ្គត់ផ្គង់នោះអាចជាទំនិញ ឬសេវាកម្ម។ អ្នកដែលធ្វើការផ្គត់ផ្គង់គឺជាអ្នកផលិត ឬជាអ្នកលក់។

តាមច្បាប់ផ្គត់ផ្គង់ កាលណាតម្រូវការកាន់តែច្រើននាំឱ្យការផ្គត់ផ្គង់កើនឡើង។ តាមច្បាប់ផ្គត់ផ្គង់ដដែរ អ្នកផ្គត់ផ្គង់មានបំណងផ្គត់ផ្គង់កាន់តែច្រើន នៅពេលទំនិញមានតំលៃថ្លៃ ហើយមានបំណងផ្គត់ផ្គង់តិចនៅពេលដែលទំនិញមានតំលៃថោក។គេអាចនិយាយបានថាថ្លៃនិងបរិមាណផ្គត់ផ្គង់មានទំនាក់ទំនងស្របគ្នា។[11]

ក្រៅពីកត្តាថ្លៃ កត្តាផ្សេងទៀតដែលមានឥទ្ធិពលទៅលើការផ្គត់ផ្គង់រួមមានដូចជា[12]៖

- ថ្លៃដើមអ៊ីនភុត៖ គឺជាថ្លៃធនធានដែលត្រូវការដើម្បីយកមកផលិតទ្រព្យ និងសេវា។ វាមានឥទ្ធិពលផ្ទាល់ទៅលើការផ្គត់ផ្គង់។
- ផលិតភាពពលកម្ម៖ គឺជាបរិមាណទ្រព្យ និងសេវា ដែលមនុស្សម្នាក់អាចផលិតក្នុងរយៈពេលមួយ។ ការហ្វឹកហាត់បានល្អ ឬកាន់តែមានជំនាញ ធ្វើឱ្យការធ្វើការកាន់តែមានប្រសិទ្ធភាព ធ្វើឱ្យថ្លៃដើមធ្លាក់ចុះ និងការផ្គត់ផ្គង់កើនឡើង។
- បច្ចេកវិជ្ជា៖ ដោយសារការបញ្ចូលវិទ្យាសាស្ត្រទំនើបក្នុងដំណើរការផលិត ធ្វើឱ្យផលិតករអាចផលិតទ្រព្យ និងសេវាមានប្រសិទ្ធភាពជាងមុន។
- សកម្មភាពរបស់រដ្ឋាភិបាល៖ សកម្មភាពរបស់រដ្ឋាភិបាលរួមមានដូចជា ការយកពន្ធ និងការធ្វើឧបត្ថម្ភធន។ វាអាចមានឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានទៅលើថ្លៃដើមផលិតកម្ម។
- ថ្លៃសង្ឃឹមទុកនៅពេលអនាគត៖ បើផលិតករគិតថានៅពេលអនាគត ថ្លៃផលិតផលរបស់គាត់នឹងកើនឡើង នោះពួកគាត់នឹងផលិតកាន់តែច្រើន ផ្ទុយមកវិញ បើផលិតករគិតថានៅពេលអនាគត ថ្លៃផលិតផលរបស់គាត់នឹងថយចុះ ពួកគាត់នឹងផលិតកាន់តែតិច។
- ចំនួនផលិតករ៖ ផលិតផល ឬសេវាកម្មថ្មីដែលទទួលបានជោគជ័យ ជានិច្ចកាលធ្វើឱ្យមានការប្រកួតប្រជែងកាន់តែខ្លាំង ដែលធ្វើឱ្យការផ្គត់ផ្គង់កើនឡើង។

## ១.៥. និយមន័យកសិកម្ម បន្លែ និងបច្ចេកទេសនៃការដាំដុះ

### ១.៥.១ និយមន័យកសិកម្ម

កសិកម្ម គឺជាពាក្យមួយដែលមានអត្ថន័យខុសៗគ្នា ទៅតាមការយល់ឃើញរបស់មនុស្សម្នាក់ៗ។ តាមការស្រាវជ្រាវទៅលើនិយមន័យនៃពាក្យកសិកម្ម ឃើញថាពាក្យ "កសិកម្ម" ត្រូវបានគេលើកមកឱ្យអត្ថន័យប្រហាក់ប្រហែលគ្នា ដូចខាងក្រោម៖

-កសិកម្មសំដៅទៅលើការធ្វើស្រែចំការ រឺដាំដុះដំណាំផ្សេងៗ។[13]

[11] ម៉ម ចរិយាវុធ និងងួន ហេង, "សេដ្ឋកិច្ចនយោបាយ", បោះពុម្ពលើកទី៥, ឆ្នាំ២០១៦, ទំព័រទី៨១

[12] ម៉ម ចរិយាវុធ និងងួន ហេង, "សេដ្ឋកិច្ចនយោបាយ", បោះពុម្ពលើកទី៥, ឆ្នាំ២០១៦, ទំព័រទី៩០

-កសិកម្ម គឺជាវិទ្យាសាស្ត្រ ឬការអនុវត្តការថែទាំដីសម្រាប់ការលូតលាស់នៃដំណាំ ការដាំដំណាំ ការធ្វើស្រែ និងការចិញ្ចឹមសត្វដើម្បីផ្តល់ជាអាហារ និងផ្តល់ជាផលិតផលផ្សេងទៀត។[14]

-កសិកម្មត្រូវបានពិពណ៌នាថាជាសិល្បៈ និងវិទ្យាសាស្ត្រមួយ ដែលរួមបញ្ចូលទាំងជំនាញ។ ពាក្យថា "រីកលូតលាស់" និង "ការចិញ្ចឹម" គឺជាការពិពណ៌នារបស់សកម្មភាព ឬការអនុវត្តកសិកម្ម។ វាមានពីរផ្នែកធំៗ គឺផលិតកម្មរុក្ខជាតិ និងផលិតកម្មសត្វ ក្នុងគោលបំណងផលិតចំណីអាហារបំពេញតម្រូវការរបស់មនុស្ស ក្រៅពីតម្រូវការផ្សេងៗទៀតដែលមានដូចជា សម្លៀកបំពាក់ ថ្នាំសង្កូវ សំភារៈ ឧបករណ៍សិល្បៈ ការតាំងទីលំនៅ និង ជម្រក។ល។

កសិកម្មគឺជាសកម្មភាពផ្សេងៗរបស់មនុស្សទៅលើធម្មជាតិ ដើម្បីទទួលបានមកវិញនូវផលិតផលដែលគេអាចប្រើប្រាស់បានដូចជា ម្ហូបអាហារ សំលៀកបំពាក់ លំនៅដ្ឋាន ថ្នាំសង្កូវ និងរបស់របរប្រើប្រាស់ជាច្រើនទៀត។ កសិកម្មមានរបៀបរៀបចំផលិតផលិតផលទៅតាមបច្ចេកទេស ដែលក្នុងនោះមានកសិដ្ឋានចម្រុះ ការបង្ករបង្កើនផលប្រចាំឆ្នាំ ការចិញ្ចឹមសត្វ និងការដាំដំណាំដែលអាចបានផលយូរឆ្នាំជាដើម។[15]

### **១.៥.២ និយមន័យបន្លែ**

បន្លែមាននិយមន័យផ្សេងៗគ្នាតាមការយល់ឃើញរបស់មនុស្សម្នាក់ៗ។ បន្លែ គឺជារុក្ខជាតិដែលមនុស្សយកទៅចំអិនធ្វើជាម្ហូបអាហារបរិភោគ។ តាមន័យផ្សេងទៀត បន្លែគឺជាផ្នែកមួយចំនួននៃរុក្ខជាតិដែលត្រូវបានប្រើប្រាស់ដោយមនុស្ស ឬសត្វដទៃទៀតជាអាហារ។ បន្លែអាចជាផ្នែកផ្កា ស្លឹក ផ្លែ ដើម ឬមើមនៃរុក្ខជាតិ។[16] បន្លែដែលរាប់ជាបន្លែយកផ្កា ស្លឹកមានដូចជា ខាត់ណាផ្កា ត្រកួន ផ្ទីដូង ផ្ទីក្រហម ផ្ទីស ផ្ទីបន្លា ស្ពៃតឿ ស្ពៃខៀវ ស្ពៃក្តោប ស្ពៃក្រញាញ់ ស្លឹកបាស ផ្កាល្ពៅ សាលាដ ជាដើម។ ចំណែកបន្លែយកផ្លែមានដូចជា ត្រសក់ម្រះ ត្រឡាច ឃ្លោក ល្ពៅ ប៉េងប៉ោះ ននោងជ្រុង ននោងមូល ប្រពាយ ត្រប់ សណ្តែកកួរ ពោត ម្ទេសហាវ៉ៃ ម្ទេសអាចន៍សត្វ ល្ហុង ពោតបារាំង ជាដើម។ រីឯ បន្លែយកមើមមានដូចជា ឆៃថាវ ដំឡូងបារាំង ដំឡូងមី ដំឡូងជ្វា ខ្ទឹមស ខ្ទឹមក្រហម ការ៉ុត ត្រាវ ខ្ញី រំដេង រមៀត។ ។ល។ ចុងក្រោយបន្លែដែលយើងអាចបរិភោគដើមបានរួមមានដូចជា ព្រលិត ទំពាំងបារាំង...។

---

[13] វចនានុក្រមជួនណាត មេពាក្យ កសិកម្ម"

[14] DK illustrated Oxford dictionary. (2003). London: DK Pub.

[15] បណ្ឌិត ឈុន ពហុ, "សេដ្ឋកិច្ចកសិកម្ម", សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

[16] Oxford Dictionaries. (n.d.). Vegetable. Oxford Learner's Dictionaries. Retrieved July 10, 2020, from https://www.oxfordlearnersdictionaries.com/definition/english/vegetable?q=vegetable

### ១.៥.៣ ប្រភេទបន្លែ[17]

នៅក្នុងប្រទេសកម្ពុជាបន្លែត្រូវបានគេចាត់ថ្នាក់ជា៤ប្រភេទ គឺបន្លែធម្មជាតិ បន្លែសុវត្ថិភាព បន្លែសរីរាង្គ និងបន្លែគីមី ប៉ុន្តែជាទូទៅគេនិយមហៅតែ២ប្រភេទប៉ុណ្ណោះ គឺបន្លែធម្មជាតិ និងបន្លែគីមី។ បន្លែទាំង៤ប្រភេទមានលក្ខណៈខុសគ្នាដូចតទៅ៖

**បន្លែធម្មជាតិ៖** បន្លែធម្មជាតិគឺជាបន្លែដែលប្រជាកសិករ ឬប្រជាជនខ្មែរនិយមដាំជាលក្ខណៈគ្រួសារ ឬជាអាជីវកម្ម ប៉ុន្តែមិនប្រើប្រាស់សារធាតុគីមីនោះឡើយ។ បើទោះបីមានសត្វល្អិតចង្រៃស៊ីបន្លែក្តី ក៏ពួកគាត់តែងតែផ្សំថ្នាំបែបធម្មជាតិដើម្បីកម្ចាត់សត្វល្អិតចង្រៃលើបន្លែរបស់គាត់ប៉ុណ្ណោះ។

**បន្លែសុវត្ថិភាព៖** បន្លែសុវត្ថិភាពគឺជាការដាំដុះបន្លែជាលក្ខណៈទ្រង់ទ្រាយធំទៅតាមទំហំដីរបស់កសិករ។ ប៉ុន្តែការដាំដុះនេះមានការប្រើប្រាស់ថ្នាំគីមី ដើម្បីបាញ់សម្លាប់សត្វល្អិតផ្សេងៗដែលស៊ីដំណាំ។ ទោះជាមានការប្រើថ្នាំក្តី ក៏ប៉ុន្តែវាធ្វើឡើងតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ តាមស្តង់ដានៃការណែនាំច្បាស់លាស់ ហើយកសិករដាំបន្លែសុវត្ថិភាពទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវពីអ្នកជំនាញកសិកម្ម ឬអង្គការនានា។

**បន្លែសរីរាង្គ៖** បន្លែប្រភេទនេះ គឺមានការប្រយ័ត្នប្រយែងខ្ពស់លើគុណភាពនៃការដាំដុះ រាប់តាំងពីការជ្រើសរើសដី។ នៅត្រង់នេះមានន័យថា ក្រៅពីមិនប្រើប្រាស់ថ្នាំគីមីលើបន្លែហើយ គឺកសិករត្រូវសិក្សាអំពីប្រវត្តិដីរបស់ខ្លួនឱ្យប្រាកដប្រជាថា ដីមិនធ្លាប់ប្រើប្រាស់ថ្នាំគីមី ឬទទួលឥទ្ធិពលគីមីពីមុនមក។

**បន្លែគីមី៖** បន្លែគីមីគឺជាប្រភេទបន្លែដែលកសិករប្រើប្រាស់ថ្នាំគីមីគ្មានក្បួនខ្នាតត្រឹមត្រូវនោះទេ ហើយភាគច្រើនប្រើប្រាស់ថ្នាំពុលគីមីតាមការយល់ឃើញរបស់ខ្លួនមិនត្រូវតាមការណែនាំ ដែលជួនកាលធ្វើឱ្យប៉ះពាល់សុខភាពយ៉ាងធ្ងន់ធ្ងរដល់អ្នកដាំនិងអ្នកបរិភោគ ដែលបន្លែទាំងនេះត្រូវបាននាំចូលយ៉ាងច្រើនពីក្រៅប្រទេស។

### ១.៥.៤. សារៈសំខាន់នៃបន្លែ

បន្លែពិតជាមានសារៈសំខាន់ណាស់ចំពោះការរស់នៅ និងចំពោះសេដ្ឋកិច្ចជាតិ។ បន្លែមានតួនាទីយ៉ាងសំខាន់សម្រាប់ប្រជាជនលើសាកលលោក ជាពិសេសប្រជាជនកម្ពុជាបន្ទាប់ពី ស្រូវ ត្រី និងសាច់ ដែលបានផ្តល់សារធាតុចិញ្ចឹម និងអាហារូបត្ថម្ភដល់ការធំធាត់របស់មនុស្ស ជួយឱ្យមានសុខភាពល្អ កំលាំងមាំមួន ហើយមានប្រាជ្ញាឈ្លាសវៃ និងមានសម្បុរស្បែកស្រស់ស្អាត។

#### ក. សារៈសំខាន់ចំពោះការរស់នៅ

បន្លែគឺជា ដំណាំដែលមានលក្ខណៈចាំបាច់ សម្រាប់សុខភាពរបស់មនុស្ស ព្រមទាំងអាចចាត់ចូលជាអាហារលេខមួយ បើគិតពីសារធាតុចិញ្ចឹម។ បន្លែមានសម្បូរទៅដោយសារធាតុចិញ្ចឹមជាច្រើនដូចជា ប្រូតេអ៊ីន

[17] ប៊ិន ប៊ុណ្ណា. (2020). កម្ពុជាមានបន្លែប៉ុន្មានប្រភេទ? Sabay News. Retrieved July 11, 2020, from https://news.sabay.com.kh/article/1194327

គ្លុយកូស ជាតិប្រេង ជីវជាតិដែក កាល់ស្យូម សារជាតិខនិជ ព្រមទាំងជីវជាតិ អា បេ សេ ជាដើម ។ល។

សារធាតុចិញ្ចឹមទាំងនេះអាចទ្រទ្រង់សារពាង្គកាយមនុស្សយើងឲ្យរស់រានមានជីវិត មានកម្លាំងពលំបរិបូរ ព្រមទាំងប្រាជ្ញាស្មារតីសម្រាប់អនុវត្តការងារផ្សេងៗបាន។ យើងមិនអាចរក្សាសុខភាពឲ្យបានល្អដោយគ្រាន់តែបរិភោគបាយ នំប៉ុង ឬសាច់ដោយគ្មានបន្លែបានឡើយ។ ការបរិភោគបន្លែឲ្យបានទៀងទាត់អាចធ្វើឲ្យសុខភាពមានលក្ខណៈល្អប្រសើរ។ ក្រៅពីនេះបន្លែអាចប្រើជាគ្រឿងសម្រាប់ជួយលើកកម្ពស់គុណភាព និងរសជាតិអាហារទៀតផង។ បន្លែមានច្រើនប្រភេទសំរាប់ការប្រើប្រាស់ជួនកាលមានលក្ខណៈដូចគ្នា ជួនកាលផ្លាស់ប្តូរទៅតាមរបៀបផ្សេងៗគ្នា។ ក្នុងករណីខ្លះ គេបរិភោគបន្លែស្រស់ ឆៅ ឬចម្អិនទៅជាសម្ល។ ការបរិភោគបន្លែមិនគ្រប់គ្រាន់អាចបណ្តាលឲ្យមានជំងឺខ្វះជីវជាតិ ឬខ្វះប្រូតេអ៊ីន ដែលជាមូលហេតុធ្វើឲ្យជំងឺដទៃទៀតរាតត្បាតដល់រាងកាយរបស់យើង។ ជីវជាតិនីមួយៗមានសារៈសំខាន់ដូចខាងក្រោម៖[18]

-ជីវជាតិ អា៖ អាចធ្វើឱ្យភ្នែកភ្លឺច្បាស់ល្អនិងមានសុខភាពល្អ។ ការខ្វះជីវជាតិ អា អាចបណ្តាលឲ្យភ្នែកកើតជំងឺខ្វាក់មាន់។ ចំពោះកុមារខ្វះជីវជាតិអាវិញ បើស្ថិតក្នុងលក្ខណៈធ្ងន់ធ្ងរអាចធ្វើឱ្យងងឹតភ្នែកតែម្តង។ ប្រភពសំខាន់នៃជីវជាតិ អា គឺមាននៅក្នុងបន្លែស្លឹកដែលមានពណ៌បៃតង ផ្លែឈើដែលមានពណ៌លឿង ប័រស៊ុតសត្វ ឬ ស្ថិតនៅក្នុងថ្លើមសត្វ។

-ជីវជាតិ សេ៖ ជំនួយក្នុងការការពារជំងឺ ជួយឱ្យការមុតរបួសផ្សេងៗឆាប់ជាសះស្បើយ ជួយពង្រឹងប្រព័ន្ធភាពស៊ាំរបស់រាងកាយទប់ទល់នឹងជំងឺផ្សេងៗ និងជួយឱ្យធ្មេញអញ្ចាញមានសុខភាពល្អ។ ប្រភពសំខាន់នៃជីវជាតិ សេ គឺនៅក្នុងបន្លែយកស្លឹក បន្លែយកផ្លែ ផ្លែល្ហុង ផ្លែត្របែក ក្រូចថ្លុង ក្រូចពោធិ៍សាត់ និងក្រូចឆ្មារ ។ល។

-ជីវជាតិ បេ៖ ស្បែក ភ្នែក សរសៃប្រសាទ និងឈាមត្រូវការជីវជាតិបេនេះ ដើម្បីជួយដល់ការលូតលាស់នៃរាងកាយ និងជួយបង្កើនថាមពល។ ការខ្វះជីវជាតិ បេ បណ្តាលឲ្យមានការខ្វះឈាម ខ្សោះកម្លាំង ស្បែកស្ងួតក្រៀម ខ្លួនហើមព្រមទាំងពុំសូវមានប្រាជ្ញាស្មារតីល្អទៀតផង។ ជីវជាតិបេនេះ ស្ថិតនៅក្នុងស្លឹកបន្លែ បន្លែយកមើម អង្ករ ម្សៅ សាច់សត្វ និងថ្លើមសត្វ ...។

-ប្រូតេអ៊ីន៖ ជួសជុលកោសិកានិងជាលិកាសម្រាប់បង្កើនថាមពល និងការលូតលាស់។

-កាល់ស្យូម៖ សម្រាប់ធ្វើឱ្យឆ្អឹង និងធ្មេញរឹងមាំ

-ជីវជាតិដែក៖ ដឹកនាំអុកស៊ីសែនពីសួតទៅកាន់គ្រប់កោសិកាទាំងអស់។

[18] និស្សិតទឹម សាវ៉ាន់, "ការវាយតំលៃលើសួនបន្លែ", សារណាបញ្ចប់ការសិក្សាឆ្នាំ១៩៩៥

តារាងខាងក្រោមបញ្ជាក់ពីកម្រិតជីវជាតិនៅក្នុងបន្លែមួយចំនួន ដែលសម្គាល់បានដោយៈអក្សរX បញ្ជាក់ថាបន្លែមានជីវជាតិចិញ្ចឹមតិច អក្សរ XX បញ្ជាក់ថាបន្លែមានជីវជាតិចិញ្ចឹមមធ្យម និងអក្សរ XXX បញ្ជាក់ថាបន្លែមានជីវជាតិចិញ្ចឹមច្រើន។[19]

តារាងទី១៖ កម្រិតជីវជាតិនៅក្នុងបន្លែប្រភេទនីមួយៗ

| មុខដំណាំ | វីតាមីន អា | វីតាមីន បេ | វីតាមីន សេ | ប្រូតេអុីន | កាល់ស្យូម | ដែក |
|---|---|---|---|---|---|---|
| ម្ទេសប្លោក | X | X | X | X | X | X |
| ត្រប់ | XXX | X | X | X | XXX | X |
| ប៉េងប៉ោះ | XXX | | X | X | X | X |
| ត្រសក់ | XXX | X | | X | XXX | X |
| ការ៉ុត | X | X | X | | X | X |
| ម្រះ | XXX | X | X | X | XXX | X |
| ននោងមូល | XXX | X | X | X | X | X |
| ននោងជ្រុង | XXX | X | X | X | XXX | X |
| សណ្តែកកួរ | X | XXX | X | X | XXX | X |
| ត្រឡាច | X | X | X | X | X | X |
| ឃ្លោក | X | X | X | X | X | X |
| ល្ពៅ | X | XXX | X | X | X | X |
| ត្រកួន | X | X | X | XX | XX | XX |
| ផ្ទី (ផ្ទីស) | XXX | X | X | XX | XX | XXX |
| ស្ពៃក្រញ៉ាញ់ | | X | X | X | X | |
| ស្ពៃក្តោប | | X | X | X | X | |
| ស្ពៃផ្កា | X | | XXX | X | XX | X |
| ជ្រលង់ | XX | | X | X | X | X |

ប្រភព៖ គោលការណ៍ណែនាំសម្រាប់អ្នកសម្របសម្រួលស្តីពីផលិតកម្មដំណាំសរីរាង្គ

**ខ. សារៈសំខាន់ផ្នែកសេដ្ឋកិច្ច**

ក្រៅពីមានសារៈសំខាន់សំរាប់ការរស់នៅ បន្លែក៏មានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចផងដែរ។ ការបរិភោគ

[19] "គោលការណ៍ណែនាំសម្រាប់អ្នកសម្របសម្រួលស្តីពីផលិតកម្មដំណាំសរីរាង្គ", ២០១២, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បន្លែធ្វើឱ្យមានសុខភាពល្អ កម្រមានជំងឺមកបៀតបៀន មិនធ្វើឱ្យអ្នកខាតបង់ប្រាក់កាសសំរាប់ចំណាយលើការព្យាបាលជំងឺ ចំនេញពេលវេលាប្រកបរបរចិញ្ចឹមជីវិត។ គេអាចដាំដុះបន្លែដោយខ្លួនឯង ដើម្បីកាត់បន្ថយការចំណាយ និងអាចមានបន្លែស្រស់ៗសម្រាប់បរិភោគទៀតផង។ ក្រៅពីការដាំដុះសម្រាប់ផ្គត់ផ្គង់គ្រួសារ គេក៏អាចដាំបន្លែសំរាប់យកទៅលក់នៅតាមទីផ្សារតូច-ធំ ដែលអាចផ្តល់ជាប្រាក់កាសតិចតួច ឬច្រើនទៅតាមទំហំផលិតផល។ យើងសង្កេតឃើញថា នៅប្រទេសកម្ពុជាប្រជាជនមួយចំនួនតូចដែលមានមុខរបរជាអ្នកដាំបន្លែភាគច្រើនមានទីលំនៅតាមជាយក្រុង ឬស្ថិតតាមតំបន់មាត់ទន្លេ។ ប្រជាជនទាំងនេះមានបទពិសោធន៍ច្រើនខាងដំណាំបន្លែ។ ប្រសិនបើពួកគាត់មានមធ្យោបាយផលិតគ្រប់គ្រាន់ និងមានការយល់ដឹងពីបច្ចេកទេសដាំដុះបែបទំនើប និងបែបសុវត្ថិភាពទៀតនោះពួកគាត់នឹងអាចផលិតបន្លែបានផលច្រើន ព្រមទាំងទទួលបានប្រាក់កម្រៃច្រើន និងអាចធ្វើឲ្យជីវភាពរស់នៅរបស់គាត់បានធូរធារថែមទៀត។

### ១.៥.៥ កត្តាសំខាន់ទាក់ទងនឹងការដាំដុះបន្លែ[20]

ដើម្បីធានាទទួលបានប្រាក់ចំណូលច្រើនពីមុខរបរដាំបន្លែនេះ កសិករត្រូវតែស្វែងយល់ពីកត្តាទាំងឡាយដែលទាក់ទងនឹងការដាំដុះបន្លែជាមុនសិន។ កត្តាសំខាន់ៗទាំងនោះរួមមាន អាកាសធាតុ ទឹក ដី ជី និងសត្វល្អិតចង្រៃ។

#### ១.៥.៥.១ កត្តាអាកាសធាតុ

ប្រភេទ ឬពូជដំណាំមួយចំនួន ត្រូវការលក្ខខណ្ឌបរិយាកាសជុំវិញប្លែកៗពីគ្នា។ អាកាសធាតុជាកត្តាមួយយ៉ាងសំខាន់ក្នុងចំណោមកត្តាសំខាន់ៗដទៃទៀត ដែលអាចកំណត់នូវលទ្ធភាពក្នុងការដាំដុះបន្លែ ឬក្នុងការផលិតពូជ។ ដោយហេតុនេះហើយ ទើបកសិករត្រូវដឹងជាចាំបាច់នូវប្រភេទពូជ និងតម្រូវការរបស់វាជាមុន មុននឹងផលិត។

##### ក.សីតុណ្ហភាព

សីតុណ្ហភាពមានឥទ្ធិពលយ៉ាងខ្លាំងទៅលើដំណុះគ្រាប់ ការលូតលាស់របស់ដំណាំ និងការផលិតពូជ។ ចំពោះអាកាសធាតុត្រជាក់ខ្លាំង ឬក្តៅខ្លាំង មិនអំណោយផលឲ្យគ្រាប់ពូជដុះបានល្អឡើយ។ សីតុណ្ហភាពដែលសមស្របសម្រាប់ដំណុះគ្រាប់បន្លែគឺចន្លោះពី ១៦ អង្សាសេ ទៅ ២០ អង្សាសេ។ នៅសីតុណ្ហភាពលើសពី ៣០ អង្សាសេ ដំណុះគ្រាប់ត្រូវថយចុះ ឬ ត្រូវបញ្ឈប់តែម្តង។ សីតុណ្ហភាពក្តៅខ្លាំងអាចធ្វើឲ្យដំណាំរាំងស្ទះក្នុងការស្រូបយកជីជាតិសម្រាប់ចិញ្ចឹម ដើម ទង ទោះបីសារធាតុទាំងនោះមាននៅក្នុងដីស្រាប់ក៏ដោយ ព្រមទាំងធ្វើឱ្យស្លោកផ្លែ ឬស្លឹកទៀតផង។

---

[20] បណ្ឌិត ប្រិន វ៉ូរ៉េល និងតាត់ អេងឡាយ, "ដំណាំបន្លែនៅកម្ពុជា", ឆ្នាំ១៩៩២

**ខ.ទឹកភ្លៀង**

ទឹកភ្លៀង គឺជាកត្តាសំខាន់សម្រាប់ដំណាំទូទៅ។ ការដាំដុះបន្លែមួយចំនួនត្រូវពឹងផ្អែកទៅលើទឹកភ្លៀង ប៉ុន្តែនៅរដូវភ្លៀងអាចធ្វើឲ្យមានការលំបាកខ្លះដែរដូចជា ស្មៅឆាប់ដុះ ដំណាំឈ្លក់ទឹកពេលភ្លៀងខ្លាំង បាត់បង់ដីដោយសារការហូរតាមទឹក ធ្វើឲ្យដីឆាប់ហាប់ មានជំងឺផ្សិតច្រើន ហើយជួនកាលធ្វើឲ្យការប្រើប្រាស់ថ្នាំពុលគ្មានប្រសិទ្ធភាព ។ល។ ប៉ុន្តែនៅរដូវប្រាំង ការដាំដុះទាមទារធ្វើឲ្យបានពីដើមរដូវ និងទាមទារការស្រោចទឹកច្រើន ឬធ្វើការបញ្ចូលទឹកជំនួសភ្លៀង។ នៅចុងរដូវវស្សាភ្លៀងច្រើនធ្លាក់ខ្លាំងហួស ឯចុងរដូវប្រាំងច្រើនខ្វះទឹក ហើយមានសីតុណ្ហភាពក្តៅខ្លាំង ដែលនាំឲ្យការដាំដុះពុំសូវផ្តល់ផលបានច្រើនឡើយ។ ចំណែកឯ ភ្លៀងធ្លាក់ខ្លាំងរួចរាំងស្ងួតយូរក្រោយពេលដាំគ្រាប់វិញ អាចបណ្តាលឲ្យគ្រាប់មិនដុះព្រោះដីស្រទាប់លើហាប់ខ្លាំង គ្រាប់ពិបាកដុះចេញ រួចពន្លកគ្រាប់ក៏ងាប់ក្នុងដីនោះតែម្តង។ ដូច្នេះគេអាចនិយាយបានថាទឹកភ្លៀងជាកត្តាសំខាន់ក្នុងការដាំដុះបន្លែ និងជាកត្តាកំណត់ទិន្នផលផងដែរ។

**គ.សំណើមបរិយាកាស**

សំណើមក្នុងបរិយាកាសក៏ដើរតួនាទីសំខាន់ក្នុងការដាំដុះបន្លែដែរ។ សំណើមបរិយាកាសមានកម្រិតខ្ពស់កាលណាភ្លៀងធ្លាក់ខ្លាំង។ ក្នុងរដូវប្រាំងសំណើមក្នុងបរិយាកាសមានកម្រិតទាប នាំឱ្យកម្រិតនៃការស្រោចទឹកក៏អាស្រ័យទៅតាមនោះដែរ។ កាលណាបរិយាកាសសើម រុក្ខជាតិនឹងបន្ថយនូវការបំភាយចំហាយទឹក ដែលនាំឲ្យរុក្ខជាតិត្រូវការទឹកតិចជាងមុន។ វត្តមានរបស់សត្វល្អិតចង្រៃ ឬជំងឺពុំសូវកើតទេ នៅខែវិច្ឆិកា ធ្នូ និងមករា ពីព្រោះសីតុណ្ហភាពចុះហើយសំណើមក្នុងបរិយាកាសក៏ចុះទាបដែរ។ ចំណែកនៅចុងរដូវវស្សាវិញ មានភ្លៀងធ្លាក់ខ្លាំងដែលធ្វើឲ្យសត្វចង្រៃមួយចំនួនធំត្រូវស្លាប់ ជាហេតុនាំឲ្យការកកើតកូនចៅនៅដើមរដូវប្រាំងពុំសូវមានសកម្មភាពខ្លាំងក្លា។

**១.៥.៥.២ កត្តាទឹក**[21]

ចំពោះដំណាំមួយចំនួនដែលមិនសូវទាមទារការស្រោចទឹកជាប្រចាំ គេអាចដាំដោយមិនបាច់ស្រោចទឹក ប៉ុន្តែគេត្រូវដាំនៅលើប្រភេទដីដែលអាចរក្សាទឹកទុកបានយូរ។ ចំពោះដំណាំបន្លែមួយចំនួនទៀត ដែលទាមទារការស្រោចទឹកច្រើនត្រូវបានគេដាំនៅក្បែរមាត់ទន្លេ បឹងបួរ ត្រពាំង អាងឬអណ្តូងទឹក ដើម្បីងាយស្រួលក្នុងការស្រោចស្រព។ តម្រូវការទឹកផ្លាស់ប្តូរទៅតាមមុខដំណាំ រដូវ តំបន់ និងទៅតាមដំណាក់កាលលូតលាស់របស់វា។ ការស្រោចទឹកច្រើនហួសអាចបណ្តាលឲ្យបន្លែឈ្លក់ទឹក ស្រពោន ឬងាប់ ឬអំណោយផលដល់ការកកើត

[21] បណ្ឌិត ប្រិន វ៉ូវែល និងតាត់ អេងឡាយ, "ដាំណាំបន្លែនៅកម្ពុជា", ឆ្នាំ១៩៩២, ទំព័រទី១៧០

នៃជំងឺផ្សេងៗ។ រីឯការខ្វះទឹកនាំឲ្យដំណាំបន្ថយការលូតលាស់ ឬងាប់។ គេធ្វើការបែងចែកបន្លែទៅតាមតម្រូវការទឹកជាក្រុមដូចខាងក្រោមៈ

-បន្លែត្រូវការទឹកខ្ពស់: ស្ពៃ សាលាដ ខ្ទឹម ស្ពៃក្តោប

-បន្លែត្រូវការសំណើម: ខ្ទឹមស ត្រសក់ ខ្ទឹមបារាំង

-បន្លែត្រូវការទឹកតិច: ឆៃថាវ សណ្តែក ដំឡូងបារាំង ពោត

-បន្លែធន់ភាពរាំងស្ងួត: ប្រពាយយក្ស ឪឡឹក ល្ពៅ។

**១.៥.៥.៣ កត្តាដី**[22]

ដីស្រទាប់លើ គឺជាដីដែលឬសរុក្ខជាតិងាយចាក់ចូលនិងស្រូបជីជាតិ។ វាជាដីសំខាន់សម្រាប់ដំណាំបន្លែ ពីព្រោះដីស្រទាប់លើនេះមានលក្ខណៈធូរ ល្បាយខ្សាច់ ស្រទាប់ភ្ជួរជ្រៅ។ ដីខ្សាច់ និងដីឥដ្ឋមិនមានការអនុគ្រោះដល់ការដុះលូតលាស់របស់ដំណាំឡើយ។ ចំណែកឯដីអាស៊ីតមានស្រទាប់ភ្ជួរស្តើង មិនអាចឱ្យបន្លែយកមើមដុះលូតលាស់ និងផ្តល់ទិន្នផលខ្ពស់ទេ។ ដីដែលដំណាំបន្លែទាមទារគឺជា ធូរជ្រៅ មានជីជាតិច្រើន និងជាទូទៅមាន pH ពី ៦.៥ ទៅ ៧.៥។

**១.៥.៥.៤. កត្តាជី**[23]

ដំណាំត្រូវការសារធាតុចិញ្ចឹមមួយចំនួនពីដី ដើម្បីដុះលូតលាស់បានល្អ។ សារធាតុសំខាន់សម្រាប់ដុះលូតលាស់របស់រុក្ខជាតិមានដូចជា អុកស៊ីសែន កាបោន និងអ៊ីដ្រូសែន។ សារធាតុចិញ្ចឹមចម្បងមាន អាសូត ប៉ូតាស្យូម ផូស្វ័រ សារធាតុចិញ្ចឹមចម្បងបន្ទាប់មាន កាល់ស្យូម ម៉ាញេស្យូម និងស្ពាន់ធ័រ។ សារធាតុចិញ្ចឹមបន្ទាប់បន្សំមាន ប៊រ ម៉ូលីដែន ក្លរ ដែក ម៉ង់កាណែស ស័ង្កសី និងទង់ដែង។ បន្លែជាប្រភេទដំណាំដែលមានឬសខ្លី មិនអាចស្រូបយកជីជាតិពីក្នុងដីបានជ្រៅឡើយ។ ដូច្នេះ វាទាមទារការដាក់ជីច្រើនដើម្បីជំនួយដល់ការលូតលាស់។ រុក្ខជាតិប្រភេទឬពូជផ្សេងគ្នាទាមទារនូវជីជាតិខុសៗគ្នាដែរ។ ជាទូទៅដំណាំបន្លែយកស្លឹកត្រូវការនូវអាសូតច្រើន បន្លែយកផ្កានិងផ្លែត្រូវការនូវផូស្វ័រច្រើន ដំណាំយកមើម ទាមទារនូវប៉ូតាស្យូមច្រើនដើម្បីផ្តល់ទិន្នផលខ្ពស់។ ការដាក់ជីអាសូតច្រើនហួស ធ្វើឲ្យបន្លែយកគ្រាប់ពន្យាពេលទុំ និងធ្វើឲ្យរុក្ខជាតិងាយនឹងកើតជំងឺ។ ផ្ទុយទៅវិញ ការខ្វះសារធាតុចិញ្ចឹមខាងលើណាមួយវាបណ្តាលឲ្យដំណាំកើតជំងឺដែរ ដែលគេហៅថាជំងឺខ្វះជីជាតិឬជំងឺខ្វះសារធាតុចិញ្ចឹម។

**១.៥.៥.៥. កត្តាសត្វល្អិតចង្រៃ**[24]

[22] បណ្ឌិត ប្រិន រ៉ូវែល និងតាត់ អេងឡាយ, "ដំណាំបន្លែនៅកម្ពុជា", ឆ្នាំ១៩៩២

[23] បណ្ឌិត ប្រិន រ៉ូវែល និងតាត់ អេងឡាយ, "ដំណាំបន្លែនៅកម្ពុជា", ឆ្នាំ១៩៩២

សត្វល្អិតប្រភេទផ្សេងគ្នា បំផ្លាញទៅលើដំណាំផ្សេងគ្នា ហើយការបំផ្លាញក៏មានសភាពផ្សេងៗពីគ្នាដែរ។ នៅក្នុងចម្ការបន្លែក្រៅពីសត្វល្អិតចង្រៃក៏នៅមានសត្វល្អិតមានប្រយោជន៍ច្រើនប្រភេទនៅក្នុងនោះដែរ។ ឈ្មោះសត្វល្អិតចង្រៃមួយចំនួន ដែលធ្វើការបំផ្លាញទៅលើដំណាំបន្លែមានដូចជា ដង្កូវឃោលទោងបំផ្លាញដំណាំស្ពៃក្ដោប ដង្កូវហ្វូងបំផ្លាញទៅលើដំណាំស្ពៃផ្កា ដង្កូវបាក់ខ្នងបំផ្លាញទៅលើដំណាំខាត់ណាខៀវ ដង្កូវស៊ីត្រួយបំផ្លាញទៅលើដំណាំខាត់ណា ត្រចៀកគូបំផ្លាញទៅលើដំណាំស្ពៃស ចៃបំផ្លាញទៅលើដំណាំស្ពៃក្រញាញ់ ដង្កូវកាត់ដើមបំផ្លាញទៅលើដំណាំសាលាដ ដង្កូវចោះផ្លែបំផ្លាញទៅលើដំណាំប៉េងប៉ោះ រុយសបំផ្លាញទៅលើដំណាំម្ទេស គឹងបំផ្លាញទៅលើដំណាំដំឡូងជ្វា ដង្កូវស៊ីផ្លែនិងដង្កូវកាត់ដើមបំផ្លាញទៅលើដំណាំពោតផ្អែម។

### **១.៥.៦. បច្ចេកទេសដាំដុះបន្លែ**[25]

បច្ចេកទេសដាំដុះបន្លែមានសារៈសំខាន់ណាស់ ក្នុងការដាំដំណាំបន្លែឱ្យបានជោគជ័យ។ បច្ចេកទេសដាំដុះបន្លែដែលកសិករកម្នាក់ៗត្រូវចេះនោះមានដូចជា ការជ្រើសរើសទីតាំងនិងការរៀបចំដី ការជ្រើសរើសពូជ និងការដាំដុះ។ល។

## **១.៦. ការវិភាគ**SWOT[26]

ការវិភាគSWOT គឺជាការវិភាគទៅលើកត្តាខាងក្នុងនិងកត្តាខាងក្រៅរបស់អាជីវកម្មមួយ ដោយផ្អែកទៅលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគម្រាមកំហែង។ វាគឺជាវិធីសាស្ត្រដើម្បីវិភាគមើលសម្រាប់ការធ្វើគម្រោង ធ្វើផែនការណ៍ ឬហានិភ័យនៃអាជីវកម្ម។ ការវិភាគSWOT មានលក្ខណៈងាយស្រួល និងសាមញ្ញបំផុត ដែលវាជួយឱ្យអ្នកផ្តោតទៅលើភាពខ្លាំង កាត់បន្ថយការគម្រាមកំហែង និងចេះទាញយកគុណសម្បត្តិពីឱកាសឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

[24] បណ្ឌិត ប្រិន វ៉ូវែល និងតាត់ អេងឡាយ, "ការគ្រប់គ្រងសត្វល្អិតលើបន្លែនៅកម្ពុជា", ឆ្នាំ១៩៩១, ទំព័រទី២៤

[25] ដំណាំស្រូវនៅកម្ពុជា, "ជំពូកទី៧ ប្រព័ន្ធកសិកម្មដែលមានដំណាំស្រូវជាមូលដ្ឋាន", ពិនិត្យដោយ បណ្ឌិត ម៉ែន សារុម ,គ្មានកាលបរិច្ឆេទ

[26] APAMAT. (2019, July 4). តើអ្វីគឺជាការវិភាគ SWOT ? Retrieved July 11, 2020, from https://apamat.com/2019/07/03/តើអ្វីគឺជាការវិភាគ-swot/

# ជំពូកទី២

# ទីផ្សារបន្លែនៅកម្ពុជា

## ២.១. តម្រូវការបន្លែនៅរាជធានីខេត្តទាំង៩

តាមការអង្កេត និងស្រាវជ្រាវរបស់មជ្ឈមណ្ឌលសិក្សាគោលនយោបាយ នៅខែតុលា ឆ្នាំ២០១៩ លើស្តង់បន្លែបោះដុំសរុបចំនួន ៧៧៨ស្តង់ នៅតាមផ្សារចំនួន១៧ក្នុងខេត្តចំនួន៩ រួមមានដូចជា ខេត្តពោធិ៍សាត់ បាត់ដំបង សៀមរាប កំពង់ធំ ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម កណ្តាល និងរាជធានីភ្នំពេញ ជាលទ្ធផលបានបង្ហាញថា តម្រូវការបន្លែនៅក្នុងរាជធានីខេត្តទាំង៩មានចំនួន ១០៥៨តោនក្នុងមួយថ្ងៃ។ ទន្ទឹមនឹងនេះបរិមាណបន្លែផ្គត់ផ្គង់ពីសំណាក់អ្នកផលិតក្នុងស្រុកមានប្រមាណ ៥០៤តោនស្មើនឹង៤៨ភាគរយ នៃបរិមាណបន្លែលក់ក្នុងមួយថ្ងៃ ចំណែកបន្លែនាំចូលពីបរទេសមានប្រមាណ ៥៥២តោនស្មើនឹង៥២ភាគរយ នៃបរិមាណបន្លែដែលត្រូវបានលក់ក្នុងមួយថ្ងៃ និងបន្លែមិនដឹងប្រភពមានចំនួន១២១៥គីឡូក្រាម។ ក្នុងចំណោមបន្លែនាំចូលពីបរទេសចំនួន ៥៥២តោន បរិមាណបន្លែនាំចូលមកពីប្រទេសវៀតណាមមានច្រើនជាងគេបំផុតគឺ ២៦៤តោនក្នុងមួយថ្ងៃស្មើនឹង២៥ភាគរយ បន្ទាប់មកគឺប្រទេសចិនមានចំនួន១៨៥តោនក្នុងមួយថ្ងៃ ស្មើនឹង១៨ភាគរយ និងប្រទេសថៃមានចំនួន ១០៣តោនក្នុងមួយថ្ងៃ ស្មើនឹង១០ភាគរយ នៃបរិមាណតម្រូវការបន្លែសរុប។ ខេត្តក្រុងដែលមានតម្រូវការបន្លែខ្ពស់ជាងគេបង្អស់ក្នុងមួយថ្ងៃមាន ទីក្រុងភ្នំពេញ ៥៤៧តោន ខេត្តបាត់ដំបង ២២៣តោន និងខេត្តត្បូងឃ្មុំ ១០៥តោន។ ខេត្តក្រុងទាំង៣នេះក៏ជាប្រភពផ្គត់ផ្គង់បន្លែដ៏ធំទៅកាន់ខេត្តនានានៃប្រទេសកម្ពុជាផងដែរ។ ចំណែកខេត្តចំនួន៣ដែលមានតម្រូវការបន្លែទាបជាងគេបំផុតរួមមាន ខេត្តពោធិ៍សាត់ ១១តោន ព្រៃវែង ១៨តោន និងខេត្តកណ្តាល២៤តោន។ ក្នុងចំណោមបរិមាណតម្រូវការបន្លែនៅក្នុងទីក្រុងភ្នំពេញ ៥៤៧តោន មានបន្លែចំនួន ២១៧តោនស្មើនឹង៤០ភាគរយ ជាផលិតផលបន្លែក្នុងស្រុក និងបន្លែចំនួន៣៣០តោនស្មើនឹង៦០ភាគរយជាបន្លែនាំចូលពីបរទេស។ ខេត្តបាត់ដំបង គឺជាខេត្តដែលមានតម្រូវការបន្លែផលិតក្នុងស្រុកចំនួនច្រើនបន្ទាប់ពីក្រុងភ្នំពេញ ដែលមានចំនួន១៣៦តោនស្មើនឹង៦១ភាគរយ និងចំនួន៨៧តោនស្មើនឹង៣៩ភាគរយជាបន្លែនាំចូល។ ចំណែកឯ ខេត្តត្បូងឃ្មុំដែលជាខេត្តមានតម្រូវការបន្លែផលិតក្នុងស្រុកច្រើនបន្ទាប់ពីខេត្តបាត់ដំបង មានតម្រូវការបន្លែផលិតក្នុងស្រុកចំនួន៧០តោនស្មើនឹង៦៧ភាគរយ និងបរិមាណបន្លែនាំចូលចំនួន៣៥តោន ស្មើនឹង៣៣ភាគរយ។ ចំណែកខេត្តពោធិ៍សាត់មានតម្រូវការបន្លែផលិតក្នុងស្រុកតិចជាងគេ មានចំនួន៥តោនស្មើនឹង៤១ភាគរយ និងបន្លែនាំចូលចំនួន៦តោនស្មើនឹង៥៩ភាគរយ។ ចំណែកឯខេត្តព្រៃវែងវិញ មានតម្រូវការបន្លែផលិតក្នុងស្រុកចំនួន៨តោនស្មើនឹង៤៤ភាគរយ និងបន្លែនាំចូលចំនួន១០

តោនស្មើនឹង៥៦ភាគរយ។ ខេត្តកណ្ដាលមានតម្រូវការបន្លែផលិតក្នុងស្រុកចំនួន១១តោនស្មើនឹង៤៧ភាគរយ និងបន្លែនាំចូលចំនួន១៣តោនស្មើនឹង៥៣ភាគរយ។

រូបភាពទី១៖ បរិមាណបន្លែដែលផ្គត់ផ្គង់ពីក្នុងស្រុក និងបន្លែនាំចូលពីបរទេស(តោន/ថ្ងៃ)




| | ត្បូងឃ្មុំ | បាត់ដំបង | កំពង់ចាម | កណ្ដាល | សៀមរាប | ព្រៃវែង | ពោធិ៍សាត់ | ភ្នំពេញ | កំពង់ធំ | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| នាំចូលពីបរទេស | 35 | 86 | 14 | 13 | 32 | 10 | 6 | 330 | 25 | 552 |
| ផលិតក្នុងស្រុក | 70 | 136 | 15 | 11 | 28 | 8 | 5 | 217 | 15 | 504 |

ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

## ២.២. ប្រភេទបន្លែមានតម្រូវការខ្ពស់ និងទាបបំផុតនៅរាជធានីខេត្តទាំង៩

ក្នុងចំណោមប្រភេទបន្លែដែលត្រូវបានអង្កេត និងស្រាវជ្រាវចំនួន៤៩ប្រភេទ ក្នុងនោះប្រភេទបន្លែចំនួន ១០មុខ ដែលមានបរិមាណតម្រូវការខ្ពស់ជាងគេបំផុតគឺ ស្ពៃក្ដោប ត្រសក់ ខ្ទឹមស ដំឡូងជ្វា ល្ពៅ ខ្ទឹមបារាំង ការ៉ុត ល្ហុងខ្ចី ក្រូចឆ្មារ និងឆៃថាវ ដែលបរិមាណតម្រូវការបន្លែទាំង១០មុខនេះមានចំនួន៥៤៧តោនក្នុងមួយថ្ងៃ។ ក្នុងនោះបរិមាណបន្លែចំនួន៥ប្រភេទដែលមានបរិមាណតម្រូវការខ្ពស់ជាងគេបំផុតនោះគឺ ស្ពៃក្ដោប ៩៥តោនក្នុងមួយថ្ងៃ ត្រសក់ ៨៧តោនក្នុងមួយថ្ងៃ ខ្ទឹមស ៥៩តោនក្នុងមួយថ្ងៃ ដំឡូងជ្វា ៤៨តោនក្នុងមួយថ្ងៃ និង ល្ពៅ ៤៦តោនក្នុងមួយថ្ងៃ។ ចំណែកឯ បន្លែ៥ប្រភេទដែលមានតម្រូវការទាបជាងគេបំផុតគឺ ស្លឹកផ្ទី៩៨៧គីឡូក្រាមក្នុងមួយថ្ងៃ ស្ពៃឆាយស៊ីម១,០៣តោនក្នុងមួយថ្ងៃ សណ្ដែកបារាំង១២,៨តោនក្នុង១ថ្ងៃ ម្ទេសអាចម៍

សត្វ១,៤តោនក្នុងថ្ងៃ និងឃ្លោក១,៩តោនក្នុង១ថ្ងៃ។ គួរបញ្ជាក់ផងដែរថា ក្នុងចំណោមបន្លែដែលមានតម្រូវការខ្ពស់បំផុតទាំង ១០ប្រភេទ បន្លែ៤ប្រភេទដែលមានសក្តានុពលក្នុងការដាំដុះនៅក្នុងស្រុកមានដូចជា ស្ពៃក្តោប ត្រសក់ ដំឡូងជ្វា និងល្ពៅ។ ចំណែកបន្លែ៤ប្រភេទទៀតគឺខ្ទឹមស ខ្ទឹមបារាំង ការ៉ុត និងក្រូចឆ្មារ តម្រូវឱ្យមានការនាំចូលពីក្រៅប្រទេស ព្រោះពួកវាសុទ្ធសឹងតែជាប្រភេទបន្លែដែលទាមទារលក្ខខណ្ឌអាកាសធាតុត្រជាក់ទើបអំនោយផលដល់ការដាំដុះ ហើយមិនសូវអំណោយផលសម្រាប់ស្ថានភាពអាកាសធាតុនៅកម្ពុជានោះ។ ចំពោះការ៉ុតវិញ យើងឃើញថាមានតែខេត្តស្ទឹងត្រែងមួយប៉ុណ្ណោះ ដែលមានស្ថានភាពដីអាចដាំដុះបាន។ ចំណែកឯ ខ្ទឹមស និងខ្ទឹមបារាំងត្រូវការនាំចូលទាំងស្រុងពីបរទេស។

រូបភាពទី២៖ បន្លែ២០ប្រភេទដែលមានតម្រូវការខ្ពស់ជាងគេបំផុតនៅរាជធានីខេត្តទាំង៩(តោន/ថ្ងៃ)




ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

## ២.៣. គម្លាតតម្លៃមធ្យមរបស់បន្លែផលិតក្នុងស្រុក និងបន្លែនាំចូល

ដោយសារតែបន្លែដែលផ្គត់ផ្គង់នៅតាមទីផ្សារបន្លែប្រចាំថ្ងៃមានប្រភពមកពីអ្នកផលិតក្នុងស្រុកផង និងនាំចូលមកពីបរទេសផង នាំឲ្យតំលៃរវាងបន្លែផ្គត់ផ្គង់ពីអ្នកផលិតក្នុងស្រុក និងបន្លែនាំចូលមានគម្លាតពីគ្នាបន្តិចបន្តួច។ បន្លែផលិតក្នុងស្រុកជាមធ្យមមានតំលៃថ្លៃជាងបន្លែនាំចូល ៦៤៣រៀលក្នុងមួយគីឡូក្រាម។ ជាក់ស្តែងប្រភេទបន្លែក្នុងស្រុកដែលមានតំលៃថ្លៃជាងបន្លែនាំចូលរួមមាន ដំឡូងបារាំង ដំឡូងជ្វា ស្ពៃជ្រក់ ស្ពៃក្រញាញ់ រមៀត ក្រូចឆ្មារ ម្រះ ស្ពៃបូកគោ ស្ពៃក្តោប ល្ពៅ ត្រាវ ខាត់ណាផ្កា ស្លឹកគ្រៃ និងត្រសក់។ ចំណែកបន្លែដែល

មានតំលៃថោកជាងបន្លែនាំចូលរួមមាន ផ្សិត ស្លឹកថ្មី ផែថាវ សាលាដ ពពាយជ្រុង ម្ទេសហាវ៉ៃ ត្រឡាច ពោតបារាំង ត្រប់ស្រួយ ស្មៀតពោត ននោងមូល ប៉េងប៉ោះ ននោងជ្រុង ឃ្លោក សណ្តែកគួរ សណ្តែកបារាំង ខាត់ណាដើម ស្ពៃឆាយស៊ីម ស្ពៃខៀវ ស្ពៃចង្កឹះ ស្ពៃផ្កក់ចយ ល្ពៅងខ្ទី ត្រប់វែង ស្លឹកខ្ទឹម រំដេង ត្រសក់ស្រូវ និងម្ទេសអាចន៍សត្វ។

រូបភាពទី៣៖ គម្លាតខុសគ្នារវាងតម្លៃមធ្យមរបស់បន្លែផលិតក្នុងស្រុក និងបន្លែនាំចូលពីបរទេស (រៀល/គ.ក)




ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

## ២.៤. បរិមាណបន្លែផលិតក្នុងស្រុក និងបន្លែនាំចូល

ក្នុងចំណោមខេត្តក្រុងដែលបានអង្កេតទាំង៩ បើគិតជាទំហំនៃបរិមាណផ្គត់ផ្គង់បន្លែ ខេត្តបាត់ដំបង ត្បូងឃ្មុំ និងខេត្តសៀមរាបមានសក្តានុពលខ្ពស់ជាងគេក្នុងការផលិតបន្លែសម្រាប់ផ្គត់ផ្គង់នៅក្នុងខេត្តរបស់ខ្លួន ដែលក្នុងនោះ ខេត្តបាត់ដំបងបានផ្គត់ផ្គង់បន្លែដោយអ្នកផលិតក្នុងខេត្តរបស់ខ្លួនរហូតដល់១២៣តោន ស្មើនឹង ៥៥ភាគរយ ខេត្តត្បូងឃ្មុំ៤២តោនស្មើនឹង៤០ភាគរយ ខេត្តសៀមរាប១៩តោនស្មើនឹង៣២ភាគរយនៃបរិមាណ

បន្លែលក់ដូរសរុបក្នុងខេត្តនីមួយៗ។ ដោយសារតែមិនមែនជាតំបន់ផលិតបន្លែ ក្រុងភ្នំពេញបាននាំចូលបន្លែពីខេត្តដទៃក្នុងបរិមាណច្រើនជាងគេបំផុត មានប្រមាណ២១៧តោនស្មើនឹង៤០ភាគរយ នៃបរិមាណបន្លែលក់ដូរសរុបក្នុងក្រុងភ្នំពេញសម្រាប់ចែកចាយទៅទូទាំងប្រទេសកម្ពុជា។ បើទោះបីជាខេត្តទាំងពីរនេះគឺជាខេត្តនាំមុខគេក្នុងការផលិត និងផ្គត់ផ្គង់បន្លែទៅកាន់ខេត្តដទៃទៀតក្តី ខេត្តត្បូងឃ្មុំបាននាំចូលបន្លែមកពីខេត្តដទៃច្រើនបន្ទាប់ពីទីក្រុងភ្នំពេញ ដែលមានបរិមាណសរុប២៨តោនក្នុងមួយថ្ងៃស្មើនឹង២៧ភាគរយ និងបាត់ដំបងសរុប១៣តោនក្នុងមួយថ្ងៃស្មើនឹង៦ភាគរយនៃបរិមាណតម្រូវការបន្លែក្នុងខេត្តនីមួយៗ។ ចំពោះការនាំចូលបន្លែមកពីបរទេសមកផ្គត់ផ្គង់ក្នុងរាជធានីភ្នំពេញច្រើនជាងគេបំផុតគឺមកពីប្រទេសវៀតណាម ដែលមានបរិមាណសរុប១៧៥តោនស្មើនឹង៣២ភាគរយ បន្ទាប់មកប្រទេសចិនដែលមានបរិមាណសរុប១៣៥តោនស្មើនឹង២៥ភាគរយ និងមកពីប្រទេសថៃមានចំនួនសរុប២១តោនស្មើនឹង៤ភាគរយនៃបរិមាណបន្លែលក់ដូរប្រចាំថ្ងៃនៅទីក្រុងនេះ។ ដោយសារតែខេត្តត្បូងឃ្មុំមានទីតាំងភូមិសាស្ត្រនៅជាប់នឹងប្រទេសវៀតណាម។ ដូច្នេះបន្លែដែលនាំចូលមកពីប្រទេសវៀតណាមមានបរិមាណច្រើនបន្ទាប់ពីទីក្រុងភ្នំពេញ ដែលមានបរិមាណសរុប២៦តោនក្នុងថ្ងៃស្មើនឹង២៥ភាគរយនៃបរិមាណបន្លែលក់ដូរសរុបក្នុងខេត្តនេះ។ បន្ទាប់មកគឺខេត្តកណ្ដាលដែលបាននាំចូលបន្លែមកពីប្រទេសវៀតណាមប្រមាណ១២តោនក្នុងមួយថ្ងៃស្មើនឹង៤៩ភាគរយ នៃបរិមាណបន្លែសរុប ដែលលក់ក្នុងខេត្តនេះ។

រូបភាពទី៤៖ បរិមាណបន្លែផ្គត់ផ្គង់ពីប្រភពនីមួយៗនៅក្នុងរាជធានីខេត្តទាំង៩ (តោន/ថ្ងៃ)




ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

ចំពោះខេត្តបាត់ដំបងនិងខេត្តសៀមរាប ដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃបាននាំចូលបន្លែច្រើនមកពីប្រទេសនេះបន្ទាប់ពីទីក្រុងភ្នំពេញ ដែលក្នុងនោះបន្លែប្រមាណ៦០តោនត្រូវបាននាំចូលខេត្តបាត់ដំបង ដែលបរិមាណនេះស្មើនឹង២៧ភាគរយ នៃបរិមាណបន្លែប្រើប្រាស់សរុបក្នុងខេត្ត។ ចំណែកឯ ខេត្តសៀមរាបវិញបាននាំចូលបន្លែប្រមាណ១៣តោនក្នុងមួយថ្ងៃស្មើនឹង២២ភាគរយពីប្រទេសនេះដូចគ្នា។ ខេត្តបាត់ដំបងក៏បាននាំចូលបន្លែច្រើនពីប្រទេសចិនបន្ទាប់ពីទីក្រុងភ្នំពេញដូចគ្នា ដែលមានបរិមាណរហូតដល់ទៅ១៨តោនស្មើនឹង៨ភាគរយនៃបរិមាណបន្លែប្រើប្រាស់សរុបក្នុងខេត្ត។ ចំពោះការផ្គត់ផ្គង់បន្លែពីអ្នកផលិតបន្លែក្នុងខេត្ត ខេត្តព្រៃវែង ពោធិ៍សាត់ និងកំពង់ធំមានបរិមាណតិចតួចបំផុត ហើយការផ្គត់ផ្គង់បន្លែត្រូវបាននាំចូលមកពីខេត្តដទៃ និងមកពីប្រទេសវៀតណាមភាគច្រើន លើកលែងតែខេត្តកំពង់ធំ ដែលនាំចូលពីប្រទេសថៃក្នុងបរិមាណប្រហាក់ប្រហែលនឹងបរិមាណបន្លែនាំចូលពីប្រទេសវៀតណាម ដែលការនាំចូលនេះមានបរិមាណ៧តោនស្មើនឹង១៧ភាគរយ។ ខេត្តនេះក៏បាននាំចូលបន្លែពីប្រទេសចិនផងដែរ ដែលមានបរិមាណ១០តោនស្មើនឹង២៦ភាគរយនៃបរិមាណបន្លែប្រើប្រាស់សរុបក្នុងខេត្ត។

## ២.៥. ប្រភេទបន្លែផលិតក្នុងស្រុក និងប្រភេទបន្លែនាំចូល

រូបភាពទី៥៖ ប្រភេទបន្លែតាមប្រភពផ្គត់ផ្គង់នីមួយៗនៅក្នុងរាជធានីខេត្តទាំង៩ (ភាគរយ)




ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

ក្នុងចំណោមបន្លែទាំង៤៩មុខដែលត្រូវបានយកមកធ្វើការសិក្សា មានបន្លែចំនួន៩មុខប៉ុណ្ណោះ ដែលមានបរិមាណសរុប១២៥តោនត្រូវបានផ្គត់ផ្គង់ទាំងស្រុង ឬស្ទើរតែទាំងស្រុងដោយអ្នកផលិតក្នុងស្រុក។ បន្លែទាំង៤មុខ ដែលត្រូវបានផ្គត់ផ្គង់ទាំងស្រុងពីអ្នកផលិតក្នុងស្រុករួមមាន ត្រកួន ស្លឹកផ្ទី រមៀត និងស្ពៃខៀវ។ ចំពោះខ្ទឹមស្លឹក និងរំដេងត្រូវបានផ្គត់ផ្គង់ពីក្នុងស្រុក៩៩ភាគរយ សណ្តែកគួរត្រូវបានផ្គត់ផ្គង់ពីក្នុងស្រុក៩៨ភាគរយ ល្ពៅងខ្ទី និងត្រប់ស្រួយត្រូវបានផ្គត់ផ្គង់ពីក្នុងស្រុក៩៥ភាគរយ។ ចំណែកបន្លែដែលនាំចូលទាំងស្រុង ឬស្ទើរតែទាំងស្រុងមានចំនួន៧មុខ ហើយមានបរិមាណសរុប១៦៣.៦តោន។ ក្នុងនោះបន្លែចំនួន៥ប្រភេទ ដែលត្រូវបាននាំចូលភាគច្រើនពីប្រទេសវៀតណាម រួមមាន ក្រូចឆ្មារ៨៩ភាគរយ ផ្សិត៨៨ភាគរយ សណ្តែកបារាំង៨២ភាគរយ ប៉េងប៉ោះ៧៨ភាគរយ និងដំឡូងបារាំង៦២ភាគរយ។ ចំណែកឯបន្លែដែលត្រូវបាននាំចូលច្រើនជាងគេពីប្រទេសចិនរួមមាន ខ្ទឹមស ៩៣ភាគរយ ស្ពៃបូកគោ ៨៣ភាគរយ ខ្ទឹមក្រហម ៧៣ភាគរយ ការ៉ុត ៦២ភាគរយ និងផ្កាខាត់ណា៥៦ភាគរយ។ សម្រាប់បន្លែ៥ប្រភេទដែលត្រូវបាននាំចូលពីប្រទេសថៃច្រើនជាងគេវិញរួមមានដូចជា ស្ឡឹកពោត៦៩ភាគរយ ត្រាវ៤៨ភាគរយ ដំឡូងជ្វា៤៨ភាគរយ ខ្ញី៣៣ភាគរយ និងខាត់ណាផ្កា២១ភាគរយ។ សរុបមកគ្មានបន្លែប្រភេទណាមួយដែលត្រូវបានផ្គត់ផ្គង់ទាំងស្រុងពីប្រទេសវៀតណាម ថៃ ឬចិននោះទេ ពោលគឺមានការចូលរួមផ្គត់ផ្គង់ពីភាគីទាំង៣។ តែទោះជាយ៉ាងណាក៏ដោយ ក៏ប្រទេសវៀតណាមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់បន្លែមកកាន់ទីផ្សារកម្ពុជាដែរ។

### ២.៥.១. ប្រភេទបន្លែនាំមុខគេទាំង១០ដែលផលិតក្នុងស្រុកច្រើនជាងគេបំផុត

រូបភាពទី៦៖ ប្រភេទបន្លែនាំមុខគេទាំង១០មុខដែលផលិតក្នុងស្រុកច្រើនជាងគេបំផុតក្នុងរាជធានីខេត្តទាំង៩




ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

ប្រភេទបន្លែនាំមុខគេចំនួន១០ប្រភេទ ដែលត្រូវបានផ្គត់ផ្គង់ពីអ្នកផលិតក្នុងស្រុកក្នុងបរិមាណច្រើនជាងគេបំផុតរួមមាន ត្រសក់ច្រើនជាងគេបំផុតគឺ ៦៦តោនក្នុងមួយថ្ងៃ បន្ទាប់មកគឺល្ពៅ ៤១តោនក្នុងមួយថ្ងៃ ល្ពៅ ៤០តោនក្នុងមួយថ្ងៃ សាលាដ ៣៣តោនក្នុងមួយថ្ងៃ ត្រប់ស្រួយ ២៦តោនក្នុងមួយថ្ងៃ ស្ពៃចង្កឹះ ២៥តោនក្នុងមួយថ្ងៃ ត្រឡាច ២៤តោនក្នុងមួយថ្ងៃ ស្ពៃក្តោប ២៣តោនក្នុងមួយថ្ងៃ ស្ពៃក្រញាញ់ ២២តោនក្នុងមួយថ្ងៃ និងផៃថាវត្រូវបានផ្គត់ផ្គង់ពីអ្នកផលិតក្នុងស្រុកប្រមាណ១៩តោនក្នុងមួយថ្ងៃ។ បន្លែ១០ប្រភេទនេះសុទ្ធសឹងតែជាប្រភេទបន្លែដែលមានសក្តានុពលប្រកួតប្រជែងខ្ពស់ជាមួយប្រទេសជិតខាង។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺទោះបីជាអ្នកផលិតក្នុងស្រុកអាចផ្គត់ផ្គង់ បន្លែត្រសក់ ផៃថាវ និងស្ពៃក្តោបក្នុងបរិមាណច្រើនយ៉ាងណាក៏ដោយ ក៏នៅតែមានការនាំចូលត្រសក់២១តោន ផៃថាវ១៩តោន និងស្ពៃក្តោប៧២តោនក្នុងមួយថ្ងៃ ពីប្រទេសវៀតណាមដើម្បីបំពេញតម្រូវការបន្លែក្នុងប្រទេសដដែរ។ ប្រការនេះ គេអាចសន្និដ្ឋានបានថា សូម្បីតែប្រភេទបន្លែដែលអាចធ្វើការផ្គត់ផ្គង់ និងមានសក្តានុពលខ្ពស់ក្នុងការផលិតពីសំណាក់អ្នកផលិតក្នុងស្រុក ក៏ពួកគេនៅមិនទាន់មានសមត្ថភាពផ្គត់ផ្គង់បានតាមតម្រូវការទីផ្សារដែរ។

### ២.៥.២. ប្រភេទបន្លែនាំមុខគេទាំង១០ដែលនាំចូលពីបរទេសច្រើនជាងគេបំផុត

រូបភាពទី៧៖ ប្រភេទបន្លែនាំមុខគេទាំង១០មុខដែលនាំចូលពីបរទេសច្រើនជាងគេបំផុតក្នុងរាជធានីខេត្តទាំង៩




ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

ប្រភេទបន្លែដែលមានការនាំចូលពីបរទេសច្រើនជាងគេបំផុតរួមមាន ស្ពៃក្តោបដែលមានបរិមាណសរុបចំនួន៧២តោនក្នុងមួយថ្ងៃ បន្ទាប់មកគឺខ្ទឹមស ៥៩តោនក្នុងមួយថ្ងៃ ខ្ទឹមបារាំង ៤៤តោនក្នុងមួយថ្ងៃ ការ៉ុត ៤៤ តោនក្នុងមួយថ្ងៃ ក្រូចឆ្មារ ៣៨តោនក្នុងមួយថ្ងៃ និងជំឡូងជ្វា ៣១តោនក្នុងមួយថ្ងៃពីប្រទេសវៀតណាម និងថៃ។ ចំណែក ស្ពៃបូកគោត្រូវបាននាំចូលប្រមាណ៣១តោនក្នុងមួយថ្ងៃពីប្រទេសចិន។ ដោយឡែក ប៉េងប៉ោះត្រូវបាននាំចូលប្រមាណ២៤តោនក្នុងមួយថ្ងៃ ត្រសក់២១តោនក្នុងមួយថ្ងៃ និងផ្លៃចាវ១៩តោនក្នុងមួយថ្ងៃ ដែលភាគច្រើនលើសលប់ត្រូវបាននាំចូលមកពីប្រទេសវៀតណាម។ ក្នុងចំណោមបន្លែនាំចូលទាំង១០ប្រភេទនេះ បន្លែមួយចំនួនដែលរួមមានដូចជា ស្ពៃក្តោប ស្ពៃបូកគោ ការ៉ុត ខ្ទឹមបារាំង ខ្ទឹមស ប៉េងប៉ោះ និងក្រូចឆ្មារសុទ្ធសឹងតែជាប្រភេទបន្លែទាមទារលក្ខខណ្ឌអាកាសធាតុត្រជាក់ទើបអំណោយផលសម្រាប់ការដាំដុះ ហើយមិនសូវអំណោយផលសម្រាប់លក្ខខណ្ឌអាកាសធាតុនៅកម្ពុជានោះទេ ជាពិសេសត្រូវចំណាយទុនខ្ពស់ហើយទាមទារការប្រើប្រាស់បច្ចេកទេសទំនើបក្នុងការផលិត និងពិបាកក្នុងការប្រកួតប្រជែងជាមួយបន្លែនាំចូលមកពីប្រទេសជិតខាង ដោយសារតែកត្តាថ្លៃដើមខ្ពស់ និងផលិតភាពទាបរបស់អ្នកផលិតក្នុងស្រុក។

## ២.៦. តម្រូវការបន្លែបន្ថែមក្នុងខេត្តក្រុងទាំង៩

រូបភាពទី៨៖ បរិមាណតម្រូវការបន្លែបន្ថែមរបស់អាជីវករលក់បន្លែនៅរាជធានីខេត្តទាំង៩ (គ.ក/ថ្ងៃ)




ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

ក្នុងចំណោមស្តង់លក់បន្លែទាំង៧៧៨ស្តង់នៅក្នុងរាជធានីខេត្តទាំង៩នេះ អ្នកលក់បន្លែចំនួន២ភាគរយនៃចំនួនស្តង់សរុបបានបង្ហាញថាគេត្រូវការបន្លែបន្ថែមសម្រាប់ពង្រីកការលក់ដូរ ដែលក្នុងនោះពួកគេត្រូវការ

បន្លែចំនួន៩មុខដែលមានបរិមាណសរុបចំនួន១០,៧តោនបន្ថែមទៀត។ បន្លែ៣ប្រភេទ ដែលមានតម្រូវការបន្ថែមខ្ពស់ជាងគេបំផុតនោះគឺ ត្រសក់២០៥០គីឡូក្រាមក្នុងមួយថ្ងៃ ត្រប់ស្រួយ២០០០គីឡូក្រាមក្នុងមួយថ្ងៃ និងម្រះ១៨០០គីឡូក្រាមក្នុងមួយថ្ងៃ។ ដោយឡែក ប្រភេទបន្លែដែលមានបរិមាណតម្រូវការបន្ថែមទាបជាងគេបំផុតវិញនោះ គឺសណ្តែកគួរ៥០គីឡូក្រាមក្នុងមួយថ្ងៃ ស្ពៃក្រញាញ់១៨០គីឡូក្រាមក្នុងមួយថ្ងៃ និងស្ពៃផ្លក់ចយ ឬស្ពៃតឿ ៥០០គីឡូក្រាមក្នុងមួយថ្ងៃ។

សរុបសេចក្តីមក យើងឃើញថាបរិមាណបន្លែផ្គត់ផ្គង់ពីអ្នកផលិតក្នុងស្រុកមានត្រឹមតែ៥០៤តោនស្មើនឹង ៤៨ភាគរយ ខណៈដែលបន្លែនាំចូលមកពីបរទេសមានបរិមាណដល់ទៅ ៥៥២តោនស្មើនឹង៥២ភាគរយ នៃបរិមាណបន្លែប្រើប្រាស់សរុបក្នុងមួយថ្ងៃ។ បន្លែមួយចំនួនត្រូវការការផ្គត់ផ្គង់ពីបរទេសទាំងស្រុង ដោយសារតែវាមិនសូវអំណោយផលសម្រាប់លក្ខខណ្ឌអាកាសធាតុនៅកម្ពុជា ជាពិសេសត្រូវការចំណាយទុនខ្ពស់ហើយទាមទារការប្រើប្រាស់បច្ចេកទេសទំនើបក្នុងការផលិត និងពិបាកក្នុងការប្រកួតប្រជែងជាមួយបន្លែនាំចូលមកពីបរទេស ដែលបន្លែទាំងនោះមានដូចជា ដំឡូងបារាំង ស្ពៃបូកគោ ការ៉ុត ខ្ទឹមបារាំង ខ្ទឹមស ខ្ទឹបារាំង និងខ្ទឹមក្រហម។ ដោយឡែកបន្លែដែលត្រូវបានផ្គត់ផ្គង់យ៉ាងច្រើនពីអ្នកផលិតក្នុងស្រុកមានដូចជា ត្រសក់ ឆៃថាវ និងស្ពៃក្តោប ក៏នៅតែត្រូវបាននាំចូលពីប្រទេសវៀតណាមក្នុងបរិមាណសរុប ១១២តោនក្នុងមួយថ្ងៃ នេះបញ្ជាក់ឲ្យឃើញថា សូម្បីតែបន្លែដែលអាចដាំដុះបានច្រើនក្នុងស្រុក ក៏សមត្ថភាពអ្នកផលិតក្នុងស្រុកនៅមិនទាន់មានសមត្ថភាពអាចផ្គត់ផ្គង់បានតាមតម្រូវការទីផ្សារដែរ។

# ជំពូកទី៣

# វិធីសាស្ត្រដាំដុះបន្លែ និងបទពិសោធន៍ដាំដុះជាក់ស្តែង

តាមប្រសាសន៍របស់លោកសម វិទូ ប្រធានអង្គការសេដាក បានលើកឡើងថាមានកត្តាចំនួន៥ដែលជួយបង្កើនសមត្ថភាពដាំដុះបន្លែក្នុងស្រុក។ កត្តាទាំង៥នោះរួមមានដូចជា ទឹក ការផ្សព្វផ្សាយ បច្ចេកទេស ទុន និងទីផ្សារ ។ ចំពោះកត្តាទឹក រាជរដ្ឋាភិបាល និងក្រសួងកសិកម្មបានធ្វើសកម្មភាពជាច្រើនរួមមាន ការស្តារប្រព័ន្ធធារាសាស្ត្រ ការជីកអណ្តូង ជីកស្រះ ដើម្បីសម្រួលដល់ការស្រោចស្រពដំណាំបន្លែរបស់កសិករ។ ចំណែកឯកត្តាទុនវិញ រាជរដ្ឋាភិបាលបានផ្តល់ទុនចំនួន ៥០លានដុល្លារអាមេរិកដល់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មដើម្បីផ្តល់ជាកម្ចីមានការប្រាក់ទាបដល់កសិករដែលខ្វះខាតដើមទុន។ សម្រាប់បញ្ហាទីផ្សារវិញ ដូចដែលយើងបានឃើញនៅក្នុងជំពូកទី២រួចមកហើយថា ទីផ្សារបន្លែនៅមានយ៉ាងច្រើនសម្រាប់កសិករដាំបន្លែនៅកម្ពុជាធ្វើការផ្គត់ផ្គង់។ ក្នុងនោះមានតម្រូវការបន្លែ៥៥២តោនដែលយើងអាចធ្វើការផ្គត់ផ្គង់ជំនួសបន្លែនាំចូល លើកលែងតែបន្លែមួយចំនួនដូចជាខ្ទឹមស ខ្ទឹមបារាំង ខ្ទឹមក្រហម ស្ពៃបូកគោ ការ៉ុត និងដំឡូងបារាំង ដែលជាបន្លែដែលយើងមិនអាចដាំដុះបាន ដោយសារកត្តាអាកាសធាតុមិនអំណោយផលសម្រាប់ការដាំដុះបន្លែក្នុងស្រុកប៉ុណ្ណោះ។ បន្ថែមពីនេះកសិករនៅកម្ពុជាក៏មានទីផ្សារបន្លែបន្ថែមទៀតចំនួន ១០,៧តោន ក្នុងមួយថ្ងៃផងដែរ។ សម្រាប់ផ្នែកបច្ចេកទេសវិញ ឃើញថាមានបច្ចេកទេសចំនួន២ដែលមានឥទ្ធិពលទៅលើសមត្ថភាពផលិតនិងផលបន្លែដែលទទួលបាន។ បច្ចេកទេសទាំង២នោះគឺបច្ចេកទេសដាំដុះឱ្យបានផលច្រើន ចំណាយតិចក្នុងការផលិត មិនមានផលប៉ះពាល់ដល់អ្នកដាំនិងអ្នកបរិភោគ មានទីផ្សារ អាចប្រកួតប្រជែងជាមួយបន្លែនាំចូលនិងមិនចំណាយពេលយូរក្នុងការផលិត។ បច្ចុប្បន្នយើងមានវិធីសាស្ត្រដាំដុះបន្លែ២ប្រភេទ ដែលទទួលបានផលបន្លែច្រើន ផលបន្លែមានសុវត្ថិភាព មានគុណភាព មិនមានសារធាតុគីមីដែលនាំឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋទាំងអ្នកដាំនិងអ្នកបរិភោគដូចដែរយើងត្រូវការខាងលើ ហើយវិធីសាស្ត្រដាំដុះបន្លែទាំង២ប្រភេទនេះក៏ទទួលបានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម និងអង្គការនានាដែលពាក់ព័ន្ធផងដែរ។ ដោយឡែកបច្ចេកទេសមួយទៀត ដែលអាចធ្វើឱ្យផលដែលកសិករផលិតបានថយចុះ ហើយមិនអាចចែកចាយបានទៅកាន់ទីផ្សារឆ្ងាយៗបាន ជាពិសេស មិនសូវមានអ្នកដឹងនិងចាប់អារម្មណ៍ ហើយក្រសួងក៏មិនទាន់ផ្សព្វផ្សាយទូលំទូលាយនោះគឺបច្ចេកទេសក្រោយពេលប្រមូលផល។ យោងតាមអង្គការFAO បានលើកឡើងថា ការបាត់បង់បន្លែមានកម្រិតខ្ពស់ ប្រមាណ៩%ទៅ២៥%នៃផលិតកម្ម ដោយសារការខ្វះបច្ចេកទេសក្រោយប្រមូលផលដូចជា បច្ចេកទេសរក្សាទុក វេចខ្ចប់ ដឹកញ្ជូន និងតាំងលក់លើទីផ្សារជាដើម។ ចំពោះបច្ចេកទេសដាំដុះ២ប្រភេទ ដែលត្រូវបានគាំទ្រឱ្យយកមកអនុវត្តក្នុងការដាំដុះបន្លែ ដើម្បីផ្គត់ផ្គង់

ទីផ្សារគឺមាន៖ បច្ចេកទេសដាំដុះបន្លែសរីរាង្គ និងបច្ចេកទេសដាំដុះបន្លែសុវត្ថិភាព។

## ៣.១ បន្លែសរីរាង្គ

ការដាំដុះបន្លែសរីរាង្គ គឺជាការដាំដុះបន្លែដោយប្រើធនធានតិច ហើយមានការប្រយ័ត្នប្រយែងខ្ពស់ទៅលើគុណភាពនៃការដាំដុះដោយគោរពតាមគោលការណ៍ធម្មជាតិដោយប្រើប្រាស់វត្ថុធាតុដើមពីធម្មជាតិ ជៀសវាងការប្រើប្រាស់ថ្នាំគីមី មិនប៉ះពាល់បរិស្ថាន ទឹក ដី ដើម្បីជៀសវាងការប៉ះពាល់ដល់សុខភាពទាំងអ្នកដាំ និងអ្នកបរិភោគ ព្រមទាំងកាត់បន្ថយការចំណាយក្នុងការទិញថ្នាំគីមី ដោយប្រើប្រាស់ជីធម្មជាតិដូចជា ជីកំប៉ុស្ត ជីស្រស់ និងថ្នាំកសិកម្មផ្សំពីរុក្ខជាតិជាដើម។

### ៣.១.១. ការដាំដុះបន្លែសរីរាង្គ

មានកត្តាជាច្រើនដែលរួមចំណែកក្នុងការដាំដុះបន្លែ ដើម្បីទទួលបានផលជាទីគាប់ចិត្ត បានផលបន្លែច្រើន ផលបន្លែមានគុណភាព មានរសជាតិឆ្ងាញ់ មានសោភ័ណភាពល្អគួរជាទីបរិភោគ និងលក់បានតំលៃខ្ពស់ហើយសមស្របតាមតម្រូវការទីផ្សារ។

#### ក. ការជ្រើសរើសដី

ធ្វើការជ្រើសរើសដីដោយពិនិត្យលើប៉េហាស់ដី។ ដីដែលអាចដាំដំណាំបានល្អ គឺជាដីដែលមានប៉េហាស់ស្ថិតនៅចន្លោះពី ៥,៥ ទៅ ៨ តែចំពោះប្រភេទបន្លែស្ទើរតែទាំងអស់ត្រូវការប៉េហាស់ពី ៥,៥ ទៅ ៦,៥។ កសិករដាំបន្លែត្រូវចេះកែប្រែដីឱ្យមានកម្រិតប៉េហាស់មួយសមស្របតាមតម្រូវការរបស់ដំណាំបន្លែទើបទទួលបានផលល្អ។ កសិករកែប្រែប៉េហាស់ដីដោយប្រើកំបោរ ដើម្បីបង្កើនប៉េហាស់របស់ដីតាមប្រភេទនីមួយៗ។ ក្រៅពីកត្តាប៉េហាស់ដី គេត្រូវជ្រើសរើសដីមានជីជាតិល្អ គឺដីមានពណ៌ខ្មៅ ធ្មោត ក្រហម មានក្លិនល្អ ជួយដល់ការលូតលាស់របស់រុក្ខជាតិខ្លាំង និងជាដីសម្បូរមីក្រូសារពាង្គកាយ។ ដីដែលមានផ្ទុកសារធាតុសរីរាង្គ និងមានមីក្រូសារពាង្គកាយច្រើន គឺជាដីដែលមានជីជាតិបំផុត ហើយដីនេះត្រូវបានគេហៅថាដីស្រទាប់លើ។ ដីស្រទាប់លើនេះមាន អាហារ ខ្យល់ និងទឹកច្រើនសម្រាប់សារធាតុសរីរាង្គ ហើយជាប្រភេទដីមានលក្ខណៈធូរដែលធ្វើអោយឫសដុះលូតលាស់ល្អបំផុត។

#### ខ.ការរៀបចំដីដាំបន្លែ

ចំពោះការរៀបចំដី ដំបូងកសិករត្រូវភ្ជួរដីហាលចោល២ឬ៣ដង យ៉ាងតិច៧ថ្ងៃ ដើម្បីសម្លាប់មេរោគ ជំងឺ និងសត្វចង្រៃដែលមាននៅក្នុងដី។ បន្ទាប់មកធ្វើការរាស់បំបែកដីអោយល្អិត ស្មើល្អ និងរើសឫសស្មៅចេញឱ្យអស់ ហើយធ្វើរងបន្លែតាមបណ្តោយថ្ងៃ ដើម្បីអោយពន្លឺព្រះអាទិត្យចេញចូលគ្រប់គ្រាន់ និងត្រូវប្រើជីកំប៉ុស្តស្ងួតទ្រាប់បាតរងពី ១ទៅ ២គីឡូក្រាមក្នុងមួយម៉ែត្រការេ។ ចំពោះការធ្វើរងគេអាចធ្វើរងចង្អូរកណ្តាលរងដំណាំ

ឬរងលើកខ្ពស់ ឬកាប់ជ្រៅ។

**គ. ការប្រើប្រាស់ជី**

ការប្រើប្រាស់ជីធម្មជាតិជាកត្តាសំខាន់ចំពោះការដាំដំណាំសរីរាង្គ។ ជីធម្មជាតិ ជាជីដែលយើងប្រមូលបានពីធម្មជាតិដែលមានដូចជា លាមកសត្វគ្រប់ប្រភេទ ស្លឹកឈើស្រស់ ស្មៅចំបើង និងកាកសំណល់នានាពីផ្ទះបាយ។ ជីធម្មជាតិរួមមាន ជីលាមកសត្វ ជីកំប៉ុស្ត និងជីស្រស់។ គុណប្រយោជន៍នៃជីធម្មជាតិគឺវាផ្តល់ធាតុអាហារគ្រប់គ្រាន់ដល់រុក្ខជាតិ ក្នុងនោះមានធាតុអាហារចាំបាច់ ធាតុអាហារបន្ទាប់បន្សំ និងធាតុអាហារបន្ថែម។ វាជួយរំលាយពពួកសរីរាង្គ និងជីគីមីដែលជាប់ក្តាំងនៅក្នុងដី ជួយធ្វើឱ្យដីធូរ ជ្រាបទឹក និងមានខ្យល់ក្នុងដី ព្រមទាំងជួយធ្វើប្រតិកម្មជាមួយអាស៊ីតក្នុងដីឱ្យសមស្របសំរាប់ការលូតលាស់របស់រុក្ខជាតិ បង្កើតកោសិកាឲ្យមានជាតិសើម ធ្វើឲ្យរុក្ខជាតិរឹងមាំ ជួយធ្វើឱ្យបណ្តូលពណ៌ខៀវ ជំនួយដី ជួយការពាររោគឬសស្អុយរលួយ ធ្វើឲ្យបន្លែទទួលបានទិន្នផលខ្ពស់ រសជាតិឆ្ងាញ់។ ក្រៅពីគុណប្រយោជន៍ទាំងនេះ ការប្រើប្រាស់ជីកំប៉ុស្តជំនួសជីគីមីបានជួយកាត់បន្ថយការបំពុល ការខូចខាតបរិស្ថាន និងជួយថែរក្សាប្រភពថាមពលដែលពុំអាចបង្កើតជាថ្មីឡើងវិញ។ .

**ឃ. ការគ្រប់គ្រងទឹក**

ទឹកពិតជាមានតួនាទីសំខាន់ណាស់ ព្រោះវាជាភ្នាក់ងាររំលាយ និងដឹកជញ្ជូនសារធាតុចិញ្ចឹមពីកន្លែងមួយទៅកន្លែងមួយទៀត។ ពេលដីមានសំណើមគ្រប់គ្រាន់ រុក្ខជាតិក៏ងាយស្រួលក្នុងការស្រូបយកទឹកដែរ។ ការគ្រប់គ្រងទឹកគឺត្រូវធ្វើយ៉ាងណាកុំអោយដីស្ងួតពេក ទឹកដក់ជាប់ ឬដីជាំទឹកខ្លាំងពេក ត្រង់នេះមានន័យថាកសិករត្រូវធ្វើឱ្យដីមានសំណើមសមរម្យល្អសម្រាប់ការលូតលាស់របស់ដំណាំ។ បរិមាណទឹកដែលត្រូវស្រោចគឺអាស្រ័យទៅលើប្រភេទដំណាំ រដូវកាល និងលក្ខណៈធម្មជាតិរបស់ដី។

**ង. ការជ្រើសរើសគ្រាប់ពូជ**

ពូជដែលដាំត្រូវតែជាពូជដែលមានប្រវត្តិច្បាស់លាស់ ជាពូជក្នុងស្រុកដែលមានដំណុះខ្ពស់៨០% គ្រាប់ធំពេញសុទ្ធមិនលាយ ពូជដែលបានមកពីការប្រើជីធម្មជាតិ ធន់នឹងជំងឺ សត្វល្អិត និងអាកាសធាតុ ពូជដែលផ្តល់ទិន្នផលច្រើន ពូជដែលបេះលើកទី២និងទី៣។ ចំពោះរបៀបពិសោធន៍គ្រាប់ពូជវិញ គេអាចយកគ្រាប់ពូជមកដាក់ក្នុងកែវដែលមានទឹកហើយជ្រើសយកតែគ្រាប់ដែលលិចទឹកប៉ុណ្ណោះ ពីព្រោះមានន័យថាវាជាគ្រាប់ពូជល្អ។ ចំណែកឯការរក្សាទុកគ្រាប់ពូជអោយល្អគេអាចធ្វើដូចខាងក្រោម៖

-សម្ភារៈ និងទីកន្លែងដែលទុកដាក់គ្រាប់ពូជត្រូវតែស្អាតមិនលាយឡំជាមួយគ្រាប់ពូជដទៃ

-សំអាតគ្រាប់ពូជមុននឹងហាល សម្រាប់គ្រាប់ពូជបន្លែខ្លះត្រូវអុំយកកំទេចកំទីចេញ

-គ្រាប់ពូជចាំបាច់ត្រូវស្តុកទុកនៅកន្លែងត្រជាក់ ស្ងួត និងមានម្លប់ ព្រោះគ្រាប់ពូជដកដង្ហើមយឺតបំផុតនៅក្នុងកន្លែងទាំងនេះ ឬទុកដាក់គ្រាប់ពូជនៅកន្លែងចង្ក្រានបាយដែលមានផ្សែង ដើម្បីជៀសវាងការបំផ្លាញពីសត្វល្អិត(វិធីបុរាណ)

-រក្សាទុកគ្រាប់ពូជនៅក្នុងដប កែវ ឬបំពង់ឫស្សី ដោយបំពេញគ្រាប់ពូជតែ១/៣ជាមួយផេះ ឬធ្យូងដើម្បីការពារផ្សិតកុំអោយដុះលើគ្រាប់ពូជ

-ពេលរក្សាទុកគ្រាប់ពូជលើសពី២ខែ ត្រូវយកគ្រាប់ពូជចេញពីដបមកហាលថ្ងៃដើម្បីសម្ងួត។

**ច. ការរៀបចំបណ្តុះកូនដំណាំ**

ការដាំដំណាំមានច្រើនរបៀបដូចជាការយកគ្រាប់ទៅដាំដោយផ្ទាល់ ការដាំដោយបណ្តុះគ្រាប់រួចដកកូនទៅដាំឬស្ទូង និងការដាំដោយប្រើមែក ទង ដើម និងមើម។ ដំណាំបន្លែជាច្រើនប្រភេទត្រូវបានអនុវត្តការដាំតាមរបៀបបណ្តុះកូនជាមុន មុនដកយកទៅដាំ ព្រោះវាមានលក្ខណៈល្អប្រសើរជាងការដាំដោយផ្ទាល់។ ដើម្បីបណ្តុះកូនដំណាំអោយលូតលាស់បានល្អ គេត្រូវគិតគូទៅលើកត្តាមួយចំនួនដូចជា ការរៀបចំថ្នាលសម្រាប់បណ្តុះកូនដំណាំ ការលាយដីសម្រាប់បណ្តុះកូន និងវិធីការពារដំណាំកុំអោយមានការបំផ្លាញពីសត្វល្អិត។ ចំពោះថ្នាលបណ្តុះកូនដំណាំ គេអាចធ្វើជាថ្នាលបណ្តុះផ្ទាល់ដី ឬថ្នាលបណ្តុះលើរានផុតពីដី។

**ឆ.ការសាប**

មុននឹងសាបគេស្រោចទឹកលើថ្នាលដាំដំណាំអោយសើមហើយរាបស្មើ ដើម្បីជៀសវាងការធ្លាក់គ្រាប់ពូជចូលជ្រៅពេកពិបាកដុះពន្លក។ បន្ទាប់មកធ្វើការសាបគ្រាប់ស្តើងៗ ហើយធ្វើការរោយម្សៅផេះសាត់ ឬផេះជុំវិញដើម្បីការពារកុំអោយស្រមោចចូលស៊ី រួចហើយត្រូវប្រើស្លឹកឈើ ឬស្បៃមុងគ្រប២ទៅ៣ថ្ងៃ។ ចំពោះពេលវេលាសាបគ្រាប់ពូជ ត្រូវសាបនៅពេលព្រឹកចន្លោះពីម៉ោង៧ទៅ៨ ឬពេលរសៀលនៅម៉ោង៥ ដើម្បីការពារគ្រាប់ពូជត្រូវថ្ងៃខ្លាំង។ ក្រោយមកត្រូវធ្វើការដករំលោះកូនបន្លែដែលដុះញឹកពេក ឬកូនបន្លែដែលគ្មានសុខភាពល្អ ដើម្បីអោយកូនដំណាំដុះលូតលាស់ធំធាត់ល្អ។ កសិករអាចចាប់ផ្តើមប្រើជីកំប៉ុស្តទឹកបំប៉ននៅពេលកូនដំណាំមានអាយុចាប់ពី១០ថ្ងៃ ឡើង។

**ជ. ការដាំដុះ**

ការដាំដុះបានផ្តល់នូវការអនុគ្រោះយ៉ាងច្រើនដល់ដំណាំបន្លែគ្រប់ប្រភេទ ដោយរួមចំណែកក្នុងការកាត់បន្ថយការបំផ្លាញពីសត្វល្អិត ជំងឺ និងស្មៅ។ ជាពិសេសបង្កើនការលូតលាស់បានល្អ ចំណេញទឹក ចំណេញពេលវេលានៃការថែទាំ និងជី។ ចំពោះការដាំដុះកសិករអាចដាំដុះតាមរបៀបផ្សេងៗដូចជា ដាំដុះតាមបែបបន្លែចម្រុះ សួនរង្វង់ ដំណាំចង្អូរកណ្តាល ដំណាំបង្វិល ដំណាំបន្លែមួយមុខ និងដំណាំឆ្លាស់។

**ឈ.កត្តាចង្រៃ**

ការដាំដំណាំបន្លែតែងតែជួបប្រទះនូវបញ្ហាជាច្រើនដូចជាជំងឺរុក្ខជាតិ ស្មៅដុះច្រើន សត្វល្អិតស៊ីបំផ្លាញ ដែលធ្វើឱ្យដំណាំទទួលបាននូវទិន្នផលទាប និងលូតលាស់មិនបានល្អ។ ដើម្បីដោះស្រាយបញ្ហានេះ កសិករមួយចំនួនធំបានចំណាយថវិកាយ៉ាងច្រើនក្នុងការទិញថ្នាំពុលគីមីយកមកប្រើប្រាស់ ក្នុងបំណងការពារដំណាំពីសត្វល្អិតចង្រៃនិងជំងឺ ព្រមទាំងដើម្បីទទួលបានទិន្នផលខ្ពស់។ ប៉ុន្តែចំពោះការដាំបន្លែសរីរាង្គវិញ មិនត្រូវការចំណាយថវិកាទិញថ្នាំគីមីដែលនាំឲ្យប៉ះពាល់ដល់បរិស្ថាន ព្រមទាំងបាត់បង់ជីជាតិដីនោះទេ។ ក្នុងការដាំបន្លែសរីរាង្គ គេធ្វើការគ្រប់គ្រងកត្តាចង្រៃតាមលក្ខណៈធម្មជាតិដោយប្រើប្រាស់វិធានការការពារកត្តាចង្រៃដែលចំណាយតិច និងមានប្រសិទ្ធភាពខ្ពស់៣ប្រភេទ៖

- **វិធានការក្សេត្រសាស្ត្រ**

វិធានការក្សេត្រសាស្ត្រគឺជាវិធានការសាមញ្ញមួយដែលមិនចំណាយប្រាក់ច្រើននិងមិនមានការប្រើប្រាស់សារធាតុពុល ដោយគ្រាន់តែអនុវត្តតាមខាងក្រោម៖

**ដាំដំណាំចម្រុះ៖** រៀបចំអោយមានដំណាំច្រើនមុខ ឬដាំបន្លែចម្រុះមុខ ព្រោះការដាំរបៀបនេះធ្វើឱ្យសត្វល្អិតចង្រៃពិបាកនឹងបំផ្លាញ ដោយសារតែសត្វល្អិតចង្រៃត្រូវការស៊ីបំផ្លាញតែដំណាំមួយមុខ ដែលវាចូលចិត្តប៉ុណ្ណោះ។

**ដាំដំណាំឆ្លាស់៖** រៀបចំអោយមានដំណាំឆ្លាស់រងគ្នារវាងដំណាំធម្មតានិងដំណាំមានក្លិនឆួល ដែលមានដូចជា ស្លឹកគ្រៃ ខ្ទឹម ដើម្បីបណ្ដេញសត្វល្អិតចង្រៃ។

**ដាំដំណាំបង្វិល៖** ការដាំបង្វិលជួយកាត់បន្ថយការកើនឡើងនូវសត្វល្អិត និងជំងឺ។

**ដាំដំណាំអន្ទាក់៖** ដាំដំណាំមួយមុខទៀតនៅក្នុងចំការ ដើម្បីទាក់ទាញសត្វល្អិតចង្រៃឱ្យចេញឆ្ងាយពីមុខដំណាំដែលគេចង់ដាំយកផលបម្រាប់លក់ដូរ។ ឧទាហរណ៍៖ ដាំស្ពៃខៀវក្នុងចំការស្ពៃក្ដោបដើម្បីទាក់ទាញសត្វល្អិតចង្រៃ ជាពិសេសដង្កូវយោលទោង ពីព្រោះដង្កូវយោលទោងចូលចិត្តស្ពៃខៀវជាងស្ពៃក្ដោប។

**ជ្រើសរើសគ្រាប់ពូជធន់៖** ជំងឺជាធម្មតាកើតឡើងដោយសារគ្រាប់ពូជមិនល្អ។ ការជ្រើសរើសគ្រាប់ពូជបានល្អអាចកាត់បន្ថយជំងឺយ៉ាងច្រើន។

**សម្អាតគ្រាប់ពូជមុនដាំ៖** សម្អាតគ្រាប់ពូជដោយលាងជាមួយទឹកនោមគោ ឬសំដិលហាលថ្ងៃរយៈពេល២ទៅ៣ម៉ោង មុនពេលយកទៅដាំដើម្បីឱ្យគ្រាប់ពូជមានកម្លាំងក្នុងការដុះលូតលាស់ និងពុំសូវមានការបំផ្លាញពីសត្វល្អិត។

**ភ្ជួររាស់ដី៖** ការភ្ជួររាស់មានសារៈសំខាន់ក្នុងការកម្ចាត់ជំងឺ សត្វល្អិត និងជាពិសេសកម្ចាត់ស្មៅចង្រៃ ដែលជាជម្រកសត្វល្អិត និងជំងឺ។

**ប្រើជីធម្មជាតិដើម្បីបង្កើនសកម្មភាពក្នុងដី** អាចជួយកាត់បន្ថយភ្នាក់ងារបង្កជំងឺ ផ្សិត និងធ្វើឱ្យមានស្ថេរភាពទម្រង់ដី ដែលធ្វើឱ្យដីមានខ្យល់ចេញចូល ជ្រាបទឹកបានល្អ និងផ្តល់សារធាតុជំនួយដល់ដំណាំ។

**ធ្វើការដាំដុះទាន់ពេលវេលានិងដាំដុះតាមចន្លោះគុម្ពឱ្យបានត្រឹមត្រូវ** ដើម្បីជួយបញ្ចៀសការបំផ្លាញដោយសត្វល្អិតចង្រៃ ហើយត្រូវទុកចន្លោះគុម្ពពីដំណាំមួយទៅមួយអោយបានសមស្រប ដើម្បីជួយកាត់បន្ថយការរាលដាលនៃជំងឺ។

**គ្រប់គ្រងទឹក៖** ដោយធ្វើយ៉ាងណាកុំអោយដីស្ងួតពេក និងកុំឱ្យមានទឹកដក់ជាប់ ឬជាំទឹកខ្លាំងពេក។

- **វិធានការមេកានិច**

ចំពោះវិធានការនេះ គេដាក់អន្ទាក់ដោយប្រើផ្លែត្នោតទុំដាក់ក្នុងចាន អង្គប់ របាំង ឬប្រើអន្ទាក់ភ្លើងដោយមានបិទជ័រស្អិតដើម្បីកម្ចាត់មមាច និងមេអំបៅ ឬធ្វើការរុំការពារផ្លែដោយស្បោង ឬក្រដាសចាស់ជៀសវាងមេអំបៅ ឬយពងដាក់មានដង្កូវ ឧស្សាហ៍តាមដានដំណាំ និងដកដើមដែលមានជំងឺចោល។ ការប្រើសំឡេង ការប្រើផ្សែង និងការប្រើថ្នាំពុលធម្មជាតិ ដែលជាថ្នាំពុលម៉្យាងផ្សំពីរុក្ខជាតិ ក៏អាចជួយបណ្តេញនិងសម្លាប់សត្វល្អិតមួយចំនួនបានដែរ ព្រោះវាមានក្លិនខ្លាំងជួយក្នុងការបណ្តេញសត្វល្អិត។

- **វិធានការជីវសាស្ត្រ**

វិធានការជីវសាស្ត្រ គឺជាការថែរក្សាសត្វមានប្រយោជន៍រួមមានពពួកសត្វល្អិតមួយចំនួន ដែលស៊ីសត្វល្អិតដែលបំផ្លាញដំណាំ។ ពួកសត្វល្អិតមានប្រយោជន៍មាន៖ សត្វបក្សី ឆ្កែញ៉ាំង អណ្តើកមាស កន្ទុំរុយ ហ៊ីងកង្កែប គីង្គក់ កូនគ្រៀល កញ្ចាញ់ចេក កណ្តូបអង់តែនវែង ពីងពាង និងថ្លែន ជាដើម។

## ៣.២ បន្លែសុវត្ថិភាព

ក្រៅពីការដាំដុះបន្លែសរីរាង្គ ការដាំដុះបន្លែសុវត្ថិភាពក៏រួមចំណែកក្នុងការការពារបរិស្ថាន ព្រមទាំងគិតគូពីសុខភាព សុវត្ថិភាព និងគុណភាពបន្លែផងដែរ។ បើទោះបីជាការដាំបន្លែសុវត្ថិភាពមានការប្រើប្រាស់ថ្នាំពុលគីមីក៏ពិតមែន ប៉ុន្តែការប្រើប្រាស់ថ្នាំគីមីគឺធ្វើឡើងដោយគោរពតាមស្តង់ដារដែលបានកំណត់ ក្បួនខ្នាតត្រឹមត្រូវ និងមានបច្ចេកទេសច្បាស់លាស់ដោយប្រើប្រាស់តែថ្នាំគីមីដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់។

### ៣.២.១. ការដាំដុះបន្លែសុវត្ថិភាព

**ក.ការជ្រើសរើសដី**

ចំពោះការដាំបន្លែសុវត្ថិភាព ដើម្បីដឹងពីប្រភេទដីនិងងាយស្រួលក្នុងការកែលម្អដីសំរាប់ការដាំបន្លែ គេត្រូវ

ធ្វើវាយនភាពដី ដើម្បីដឹងថាតើដីនោះគឺជាប្រភេទដីខ្សាច់ ដីឥដ្ឋ ឬ ដីល្បាយ។ ការធ្វើវាយនភាពដីមានឥទ្ធិពលលើការស្រោចស្រព អាចឱ្យយើងដឹងថាដីអាចទទួលបានទឹកចំនួនប៉ុន្មាន និងដឹងពីចន្លោះពេលដែលគួរស្រោចស្រពបន្លែនីមួយៗ ហើយវាក៏មានឥទ្ធិពលទៅលើអាហារចិញ្ចឹមរបស់ដំណាំផងដែរ។ ក្រៅតែពីការធ្វើវាយនភាពដី គេក៏អាចមើលលើរចនាសម្ព័ន្ធដីបានដែរ។ រចនាសម្ព័ន្ធដីត្រូវបានចែកជា២ប្រភេទគឺ ដីមានរចនាសម្ព័ន្ធល្អ និងដីមានរចនាសម្ព័ន្ធមិនល្អ។ ចំពោះដីមានរចនាសម្ព័ន្ធមិនល្អ គេអាចកែប្រែរចនាសម្ព័ន្ធដីដោយប្រើប្រាស់កៅស៊ូ ឬសារធាតុសរីរាង្គមកគ្របដី ប្រើប្រាស់កំបោរស គ្រប់គ្រងទឹកឱ្យបានល្អ និងភ្ជួរលប់កាកសំណល់ដំណាំចាស់ៗកប់ទៅក្នុងដី ដើម្បីជួយបង្កើនសារធាតុសរីរាង្គ ដែលជួយដល់ការដុះលូតលាស់ឬសដំណាំ។

**ខ. ការរៀបចំដី**

មុនធ្វើការដាំដុះគេធ្វើការសម្អាតកាកសំណល់មិនរលួយដែលមាននៅក្នុងដី សម្អាតភាពកខ្វក់ដែលរំខានដល់ការលូតលាស់និងសុវត្ថិភាពផលិតផលដំណាំ និងធ្វើការវាស់ប៉េហាស់ដី។ ប្រសិនបើប៉េហាស់ដីស្ថិតក្នុងចន្លោះ ៥,៥ ទៅ ៦,៥ នោះមានន័យថាជាដីសមស្របសម្រាប់ដំណាំទូទៅ តែបើប៉េហាស់ទាបជាង៥,៥ ត្រូវបាចកំបោរ ១៥០ក្រាមក្នុងមួយម៉ែត្រការេ ហើយបើប៉េហាស់ខ្ពស់ជាង៧ ត្រូវដាក់អាស៊ីតអាលុយមីញ៉ូមស៊ុតផាត ឬដាក់ជីកំប៉ុស្តបន្ថែមពី១ទៅ៣គីឡូក្រាមក្នុងមួយម៉ែត្រការេ។ បន្ទាប់មកធ្វើការបំផុសជម្រៅ ដើម្បីបំបែកដីឱ្យម៉ដ្ឋ ធូរ និងជ្រាបទឹកបានល្អ ដោយភ្ជួរដីជម្រៅយ៉ាងហោច០,៣ម៉ែត្រ ហើយធ្វើការរាស់បំបែក និងហាលឱ្យបានស្ងួត ដើម្បីកាត់បន្ថយកត្តាចង្រៃផ្សេងៗ។ បន្ទាប់មកធ្វើការលើកនិងគ្របរងដោយប្រើកៅស៊ូប្លាស្ទិច ឬប្រើស្លឹករុក្ខជាតិងាប់ស្ងួតគ្របរងដើម្បីការពារការហូរច្រោះ ស្មៅដុះ និងរក្សាសំណើមដី។ នៅរដូវភ្លៀង ការប្រើកៅស៊ូប្លាស្ទិចទទួលផលល្អ ម៉្យាងទៀតចំណាំផ្លាតរបស់កៅស៊ូគ្របរងដំណាំអាចជួយបណ្តេញសត្វល្អិតចង្រៃដែលរស់នៅក្រោមស្លឹកដំណាំ។ ចំណែកឯ នៅរដូវក្តៅត្រូវគ្របចំបើងពីលើបន្ថែមដើម្បីបន្ថយកម្តៅ ឬគ្របការពារស្មៅដោយប្រើរុក្ខជាតិដែលរួមមានដូចជាចំបើង ស្មៅស្ងួត អង្កាម កំប្លោក និងសារធាតុសរីរាង្គផ្សេងទៀតដែលស្ងួតហើយអាចរលួយក្លាយជាជីធ្វើឲ្យដីមានគុណភាពល្អ។ បន្ទាប់មកត្រូវធ្វើប្រព័ន្ធរំដោះទឹក ដោយជីកប្រឡាយព័ទ្ធជុំវិញតួចម្ការអោយបានធំ និងជ្រៅជាងចន្លោះរង ដើម្បីអោយទឹកដែលលើសពីតម្រូវការហូរចេញទាន់ពេលវេលា ពីព្រោះថាបើមានទឹកដក់ច្រើននឹងធ្វើឱ្យចម្ការមានសំណើមខ្ពស់ អំណោយផលដល់ការរីករាលដាលនៃពពួកកត្តាចង្រៃដូចជាជំងឺផ្សិត ជាំទឹក និងស្មៅ។ ចុងក្រោយគឺ ត្រូវដាំដំណាំការពារ តម្លើងទ្រើងឬចំណារ និងតម្លើងប្រព័ន្ធទឹក។

**គ. ការប្រើប្រាស់ដី**

សារធាតុចិញ្ចឹមឬជីពិតជាមានសារៈសំខាន់ណាស់សម្រាប់ការដុះលូតលាស់របស់ដំណាំបន្លែ បរិមាណទិន្នផលដែលទទួលបាន គុណភាព រសជាតិ ព្រមទាំងរូបរាងបន្លែដែលជាកត្តាមួយជះឥទ្ធិពលដល់តម្រូវការ។ សារធាតុចិញ្ចឹមរបស់ដំណាំ និងអាហារចិញ្ចឹមចំនួន១៦មុខ គឺជាសារធាតុចាំបាច់សម្រាប់គាំទ្រដល់ការដុះលូតលាស់និងការបង្កបង្កើតបានជារុក្ខជាតិទាំងមូល។ កាលណាខ្វះសារធាតុណាមួយក្នុងចំណោមសារធាតុចិញ្ចឹមទាំង១៦មុខ ដំណាំបន្លែមិនអាចដុះលូតលាស់បានល្អឡើយ។ សារធាតុចិញ្ចឹមទាំងនោះមាន សារធាតុចិញ្ចឹមចម្បងបំផុតគឺ អុកស៊ីសែន កាបោន និងអ៊ីដ្រូសែនដែលមានក្នុងដី។ សារធាតុចិញ្ចឹមចម្បងគឺ អាសូត ប៉ូតាស្យូម និងផូស្វ័រ សារធាតុចិញ្ចឹមចម្បងបន្ទាប់គឺ កាល់ស្យូម ម៉ាញ៉េស្យូម និងស្ពាន់ធ័រ។ សារធាតុចិញ្ចឹមបន្ទាប់បន្សំគឺ ប៊រ ម៉ូលីដែន ក្លរ ដែក ម៉ង់កាណែស ស័ង្កសី និងទង់ដែង។ ក្នុងការផ្តល់សារធាតុចិញ្ចឹម គេត្រូវប្រើសូលុយស្យុងជីទ្រាប់បាត ដោយចាក់ក្នុងរណ្តៅមុនពេលស្ទូងកូនដំណាំ និងដាក់ជីបំប៉នបង្កប់ទៅក្នុងដីបាញ់នៅលើស្លឹក ឬបញ្ចូលតាមប្រព័ន្ធខ្មើប។ ចំពោះកម្រិតនិងបរិមាណជីដែលប្រើប្រាស់ត្រូវមានការប្រែប្រួលទៅតាមកម្រិតជីជាតិដី។

### ឃ. ការជ្រើសរើសគ្រាប់ពូជ

ការជ្រើសរើសពូជ គឺត្រូវជ្រើសយកពូជដែលមានភាពធន់នឹងជំងឺ សត្វល្អិត និងអាកាសធាតុ ផ្តល់ទិន្នផលខ្ពស់ មានតម្រូវការទីផ្សារនិងមានតំលៃខ្ពស់ មានសារធាតុចិញ្ចឹម និងមានចំណូលចិត្តច្រើនពីអ្នកហូប។ ចំពោះល្បាយដីត្រូវប្រើល្បាយដីដែលគេផ្សំរួច (ទិញពីផ្សារ) ឬល្បាយដីដែលផ្សំឡើងដោយខ្លួនឯងដោយមានការលាយបញ្ចូលគ្នាពីធាតុផ្សំ៣ប្រភេទ គឺដីស្រទាប់លើ១ភាគ+ដីកំប៉ុស្ត១ភាគ+ធ្យូងអង្កាម១ភាគ។ បន្ទាប់ពីធ្វើការលាយល្បាយដីរួចហើយ ត្រូវយកល្បាយនោះទៅជ្រើមទឹក រួចផ្អាប់ទុកប្រហែល៤៨ម៉ោង ដើម្បីឱ្យពពួកភ្នាក់ងារចម្លងរោគ និងគ្រាប់ស្មៅធ្វើសកម្មភាព។

### ង. ការរៀបចំបណ្តុះកូនដំណាំ

ក្នុងការបណ្តុះគ្រាប់ពូជ គេធ្វើការបណ្តុះគ្រាប់ពូជដោយដាក់១រន្ធ១គ្រាប់ និងកប់ក្នុងជម្រៅ១.៥ នៃទំហំទទឹងគ្រាប់ពូជ រួចលប់ដីអោយបានជិត បន្ទាប់មកធ្វើការស្រោចទឹក និងហ៊ុំថាសបណ្តុះដោយរក្សាទុករយៈពេល ៣ ទៅ ៤យប់ នៅកន្លែងបិទជិត មានសីតុណ្ហភាពថេរ មិនប៉ះពាល់ជាមួយខ្យល់ និងមិនមានពន្លឺ។ នៅពេលគ្រាប់ដុះពន្លកត្រូវយកថាសបណ្តុះទៅដាក់ក្នុងរោងបណ្តុះកូន បន្ទាប់មកស្រោចទឹក ថែទាំធ្វើយ៉ាងណាឲ្យដីក្នុងថាសសើមល្មមជាប្រចាំ និងស្រោចជីបំប៉នបើកូនដំណាំមិនល្អ។ នៅរដូវក្តៅខ្លាំងត្រូវប្រើដំបូលដែលមិនមានពន្លឺរំខានមកគ្របពីលើរោងបណ្តុះនិងបើកចេញវិញនៅពេលមេឃត្រជាក់។

### ច. ការស្ទូងកូនដំណាំ

ការស្ទូងកូនចាំបាច់ត្រូវអនុវត្តទៅតាមអាយុរបស់កូនដំណាំ។មុនពេលដកកូនមកស្ទូងត្រូវផ្អាកការស្រោចទឹកយ៉ាងតិច១២ម៉ោង ដើម្បីអោយកូនដំណាំស្រូបទឹកបានឆាប់រហ័សក្រោយពេលដាំរួច។ ចំណែករងដំណាំវិញត្រូវស្រោចទឹកអោយបានសើមល្អរួចប្រើសូលុយស្យុងជីទ្រាប់បាតដែលមានជាតិផូស្វ័រច្រើន បន្ទាប់មករងចាំដល់ទឹកជីស្រូបចូលក្នុងដីអស់ប្រហែល៨០ភាគរយ ទើបធ្វើការចោះរន្ធស្ទូងកូនដោយចោះរណ្តៅដាំកូនដំណាំឱ្យមានគម្លាតខុសៗគ្នាអាស្រ័យទៅលើប្រភេទដំណាំ និងត្រូវមានជម្រៅស្មើនឹងប្រវែង និងទំហំប៉ុនដីដែលជាប់កូនដំណាំពេលដកចេញពីថាសបណ្តុះ។

### ឆ. ការគ្រប់គ្រងទឹក

ការស្រោចស្រពលើដំណាំលើកចុងក្រោយត្រូវអនុវត្តអោយបានចប់រួចរាល់នៅមុនម៉ោង៤រសៀល ដើម្បីទុកអោយដីស្រស់ទឹកបានល្អនៅពេលយប់។ ចំពោះប្រភពទឹកដែលអាចស្រោចដំណាំបានល្អ គឺទឹកអណ្តូង ឬទឹកក្រោមដី ទឹកស្រះ ឬត្រពាំងដែលជាប្រភពទឹកបិទជិត ហើយមានកម្រិតប៉េហាស់ប្រែប្រួលតិច និងទឹកដែលមានចរន្តទឹកដូចជា ទឹកស្ទឹង ព្រែក អូរ ឬប្រលាយ។ ទឹកសម្រាប់ស្រោចដំណាំបន្លែគួរមានកម្រិតPH ចន្លោះ៥.០ ទៅ ៧.០ ថ្លា គ្មានភាពកខ្វក់ពីគីមី។ កសិករអាចជ្រើសរើសរបៀបស្រោចស្រពដំណាំបន្លែដោយប្រើរបៀបស្រោចជាគ្រាប់ភ្លៀង ប្រើធុងសម្រាប់ស្រោច បាញ់ទុយោទឹក បូមបង្ហូរតាមចន្លោះរង ប្រើជម្រាលតាមទំនាញផែនដី និងប្រើប្រព័ន្ធខ្មៅ។ ការប្រើប្រព័ន្ធខ្មៅក្នុងការស្រោចបន្លែផ្តល់ភាពងាយស្រួលដល់កសិករជាងគេ ពីព្រោះកសិករអាចបញ្ចូលជី និងថ្នាំក្នុងទឹកតែម្តង។ ការធ្វើបែបនេះអាចជួយសន្សំពេលវេលា ទឹក ពលកម្ម និងបង្កការងាយស្រួលដល់កសិករជាស្ត្រីទៀតផង។

### ជ. ការគ្រប់គ្រងភក្តាចង្រៃលើបន្លែ

ចំពោះការកម្ចាត់ស្មៅចង្រៃ កសិករដាំបន្លែខ្នាតតូច និងខ្នាតមធ្យមអាចគ្រប់គ្រងស្មៅបានតាមរយៈការគ្របរងដោយប្រើកៅស៊ូប្លាស្ទិកឬចំបើង ហើយនៅតាមចន្លោះរងអាចប្រើកាក់សំណល់រុក្ខជាតិដែលមានដូចជាអង្កាម ឬផេះអង្កាម ចំបើងស្ងួត ឬស្មៅស្ងួត កំប្លោក ស្លឹកចេក ឬប្រភេទរុក្ខជាតិផ្សេងទៀតដែលងាយរលួយនៅក្នុងដី។

ចំពោះការការពារ និងការកម្ចាត់សត្វល្អិតចង្រៃ កសិករអាចធ្វើការការពារនិងកម្ចាត់សត្វចង្រៃតាមរយៈវិធីសាស្ត្រ៣ខាងក្រោម៖

- **វិធីសាស្ត្រជីវសាស្ត្រ**

វិធិសាស្ត្រជីវសាស្ត្រ គឺជាការធ្វើការការពារជាមុនដោយប្រើភ្នាក់ងារបង្ករោគ និងរក្សាតុល្យភាពសត្វល្អិតមានប្រយោជន៍ និងប្រើប្រាស់នូវប្រភេទថ្នាំជីវសាស្ត្រដែលមានលក់ច្រើននៅទីផ្សារកម្ពុជាដូចជា៖

-បាក់តេរី (Bacillus Theringiensis-Bt) មានប្រសិទ្ធភាពកម្ចាត់កូនដង្កូវដែលទើបញាស់

-ផ្សិត (Metarhizium anisopilae) ប្រសិទ្ធភាពកម្ចាត់ក្រុមសត្វល្អិតបឺតជញ្ជក់រុក្ខរស

-ផ្សិត (Verticillium lecanii) ប្រសិទ្ធភាពកម្ចាត់ក្រុមសត្វល្អិតបឺតជញ្ជក់រុក្ខរស

-ផ្សិត (Beauveria Bassiana) មានប្រសិទ្ធភាពកម្ចាត់សត្វល្អិតចង្រៃច្រើនប្រភេទដូចជា ចៃ រុយស ដង្កូវមេអំបៅ ទ្រីប ដង្កូវភ្លើង ពពួកខ្មុង ត្រឹង។ល។

- **អនុវត្តវិធីសាស្ត្រដាំដុះ**

អនុវត្តវិធីសាស្ត្រដាំដុះដោយប្រើពូជធន់ទៅនឹង ជម្ងឺ សត្វល្អិត និងអាកាសធាតុ ជ្រើសរើសទីតាំងដាំដុះ និង

ធ្វើការដាំដុះអោយបានត្រឹមត្រូវតាមបច្ចេកទេសដូចជា ការបណ្តុះកូនដំណាំ ការស្ទូងកូនក្នុងចន្លោះគុម្ព ដោតចំណារ ដាក់ទ្រើង កាត់តែងមែក សម្អាតស្មៅ ដាំដុះតាមរដូវកាលដាំដុះ គ្រប់គ្រងទឹកឱ្យបានល្អ និងការដាំឆ្លាស់មុខដំណាំ។

- **វិធីសាស្ត្រគីមី**

វិធីសាស្ត្រគីមីសំដៅទៅលើការប្រើប្រាស់ថ្នាំពុលគីមីកសិកម្មរួមមានថ្នាំកំចាត់សត្វល្អិត ថ្នាំកំចាត់ជម្ងឺ ថ្នាំកំចាត់ស្មៅ និងការដាក់ជីគីមី។ កសិករត្រូវប្រើថ្នាំទៅតាមកម្រិតណែនាំលើស្លាកសញ្ញារបស់ថ្នាំ ហើយចាំបាច់ត្រូវប្រើថ្នាំឆ្លាស់ក្រុមគីមី ដើម្បីកុំអោយសត្វល្អិតមានភាពស៊ាំជាមួយថ្នាំ។

## ៣.៣. ការអនុវត្តការដាំដុះជាក់ស្តែង

ក្រឡេកមកមើលការដាំដុះបន្លែរបស់កសិករនៅឃុំគោកគង់លិច ស្រុកកញ្ជ្រៀច ខេត្តព្រៃវែងវិញ ថាតើកត្តាទឹកទុន បច្ចេកទេស ទីផ្សារ និងការផ្សព្វផ្សាយនៅទីនេះមានលក្ខណៈបែបណា និងពិតជាជួយបង្កើនសមត្ថភាពដាំដុះបន្លែរបស់កសិករនៅទីនេះដូចម្តេចខ្លះ។

### ៣.៣.១. ស្ថានភាពទូទៅនៃខេត្តព្រៃវែង

ខេត្តព្រៃវែងគឺជាខេត្តមួយដែលមានចំងាយប្រហែល១០០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ខេត្តនេះមានផ្ទៃដីកសិកម្មធំទូលាយឆ្ងាយដាច់កន្ទុយភ្នែកជាច្រើនកន្លែង ច្រើនតំបន់ ដែលក្នុងនោះផ្ទៃដីដាំបន្លែគ្រប់មុខមាន ៩០៦ហិកតា។ ខេត្តនេះមានផ្ទៃដីសរុបចំនួន៤,៨៨៣គីឡូម៉ែត្រការេ ស្មើនឹង២,៧០ភាគរយ នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា ដែលចែកចេញជាស្រុកចំនួន១២ ឃុំចំនួន១១៦ និងភូមិចំនួន១១៣៩។ ចំពោះធនធានទឹក និងធារាសាស្ត្រវិញ ខេត្តនេះមានប្រព័ន្ធធារាសាស្ត្រសរុប១៨៦កន្លែង (ខ្នាតធំ៤កន្លែង ខ្នាតមធ្យម១១៤កន្លែង

ខ្នាតតូច៦៨កន្លែង និងស្ថានីយ៍បូមទឹក១២កន្លែង ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីសរុប១៧៣,៦៦៦ ហិកតា ស្មើនឹង៥៣.៥០%នៃផ្ទៃដីបង្កបង្កើនផលសរុប។

ក្នុងចំណោមស្រុកទាំង១២ក្នុងខេត្តព្រៃវែង ស្រុកកញ្ជ្រៀចគឺជាស្រុកមួយដែលទទួលបានភាពល្បីល្បាញខ្លាំងទៅលើការដាំដំណាំបន្លែទាំងសុវត្ថិភាព និងសរីរាង្គ។ ស្រុកនេះមានចំងាយជាង៣៧គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង និងមានទីតាំងភូមិសាស្ត្រជាប់នឹងស្រុកមួយចំនួនដូចជាស្រុកស្វាយអន្ទរ ស្រុកស៊ីធរកណ្ដាល ស្រុកកម្ចាយមារ ស្រុកពញាក្រែក ពារាំង និងស្រុកអូរាំងឪ។ ស្រុកនេះមានប្រជាជនសរុបចំនួន៧៣៧០៨នាក់ និងមានផ្ទៃដីសរុបប្រមាណ៣២៨៧២ហិចតា ដែលចែកចេញជា៨ឃុំ និង៩៩ភូមិ។

ឃុំគោកគង់លិច គឺជាឃុំមួយស្ថិតក្នុងស្រុកកញ្ជ្រៀច ដែលមានផ្ទៃដីសរុប៣៨៣៦ហិកតា និងមានព្រំប្រទល់ ខាងត្បូងជាប់ឃុំថ្មពូន ខាងជើងជាប់ឃុំទួលសុភី និងឃុំចូក ខាងកើតជាប់ឃុំគោកគង់កើត ខាងលិចជាប់ឃុំត្នោត និងឃុំកញ្ជ្រៀច។ ឃុំនេះមានភូមិចំនួន១៧ភូមិ ដែលក្នុងនោះមានភូមិចំនួន៦គឺ ភូមិអ្នកតាជ័យ ភូមិត្រពាំងប្រស្រែលិច ត្រពាំងប្រស្រែកើត ភូមិទួលពពេល ភូមិព្រៃចក និងភូមិត្រពាំងបានដាំបន្លែសុវត្ថិភាព និងសរីរាង្គ ទាំងរដូវវស្សា និងរដូវប្រាំងនៅលើផ្ទៃដីដាំដុះប្រមាណ២៩ទៅ៣០ហិកតា ដែលពីដំបូងឡើយការដាំបន្លែធ្វើលើផ្ទៃដីប្រមាណ១៥ហិចតាតែប៉ុណ្ណោះ។ ចំណែកបន្លែដែលកសិករដាំនៅក្នុងឃុំនេះមាន ស្ពៃចង្កឹះ ស្ពៃតឿ ខាត់ណាដើម ស្ពៃក្រញាញ់ ស្ពៃស សាលាដ ឆៃថាវ ម្រះ និងត្រសក់។ នៅរដូវប្រាំងវិញ ប្រជាពលរដ្ឋបានបង្កើនការដាំដុះបន្លែសុវត្ថិភាពនិងសរីរាង្គនៅលើផ្ទៃដីធ្វើស្រែបន្ថែមទៀត។ ប្រជាពលរដ្ឋដែលជាកសិករដាំបន្លែនៅឃុំនេះ ដាំបន្លែនេះជាង២០ឆ្នាំមកហើយ មុនដំបូងមានប្រមាណជា៥ទៅ ៦គ្រួសារតែប៉ុណ្ណោះ ដែលចាប់អាជីពដាំបន្លែនេះ ហើយចំណូលទទួលបានពីការលក់បន្លែក៏ទទួលបានតិចតួច ដោយពេលនោះពួកគាត់មិនទាន់ចេះបច្ចេកទេស ដាំដុះ ឬរបៀបប្រើថ្នាំធម្មជាតិ និងថ្នាំកសិកម្មអ្វីឡើយ ប៉ុន្តែក្រោយមកក៏មានមន្រ្តីជំនាញផ្នែកកសិកម្មចុះណែនាំបង្រៀនបច្ចេកទេសការដាំបន្លែសរីរាង្គនិងសុវត្ថិភាព។ តាំងពីពេលនោះមកផលបន្លែរបស់កសិករមានការកើនឡើង ហើយបន្លែដែលកសិករដាំមានទីផ្សារ ដោយមានឈ្មួញចុះមកប្រមូលទិញដល់កន្លែង ពោលគឺកសិករចាំតែកាត់ដាក់ថង់ ដែលជាការលើកទឹកចិត្តដល់កសិករឱ្យមានទឹកចិត្តដាំដុះបន្លែកាន់តែច្រើន។ នាពេលបច្ចុប្បន្ន ចំនួនកសិករដាំដុះបន្លែមានការកើនឡើងរហូតដល់៩១គ្រួសារ។

### ៣.៣.២.ការអនុវត្តការដាំដុះបន្លែរបស់កសិករក្នុងឃុំគោកគង់លិច

#### ក. ការរៀបចំដី

ដំណាំបន្លែទាមទារឱ្យមានការរៀបចំដីអោយបានល្អបំផុតទាំងការសម្អាតដី សម្អាតស្មៅ ធ្វើដីឱ្យស្រស់ល្អ មិនដក់ទឹកពេក មិនស្ងួតពេក មានជីជាតិគ្រប់គ្រាន់ រួមទាំងការលើករង ដាក់ជីទ្រាប់បាត...។ តាមសម្ភាសន៍

កសិករបានរៀបចំដីដូចខាងក្រោម៖

- ដំបូងធ្វើការសម្អាតដី សម្អាតស្មៅ ធ្វើដីអោយស្រស់ល្អ មិនជោកនិងមិនស្ងួតទឹកពេក ដោយធ្វើការភ្ជួរដីត្រលប់ដីហាលថ្ងៃ។ កសិករភ្ជួរដីដោយប្រើម៉ាស៊ីនភ្ជួរ មួយឬពីរដងក្នុងមួយរដូវដាំដុះតាមលក្ខណៈរបស់ដី។ ពួកគាត់ធ្វើការភ្ជួររាស់ដី ដើម្បីត្រលប់ដីខាងក្រោមដែលសម្បូរមមោក និងសារធាតុសរីរាង្គឡើងមកលើ បន្ទាប់ពីការប្រមូលផលបន្លែដែលបានដាំដុះសារមុនរួចរាល់ ប៉ុន្តែកសិករខ្លះធ្វើការភ្ជួររាស់ដីតែមួយសារប៉ុណ្ណោះ ពីព្រោះពួកគាត់យល់ថាដីនៅមានលក្ខណៈល្អ នៅមានជីជាតិ និងមិនមានស្មៅដុះច្រើននៅឡើយ។
- បន្ទាប់មកកសិករធ្វើការលើករងបណ្តុះកូនដំណាំដោយកាប់ដីលើករងដោយប្រើចបកាប់ ហើយរីដីឱ្យស្មើស្អាត។ កសិករបញ្ជាក់ថាការលើករងអោយបានល្អពិតជាសំខាន់ណាស់សំរាប់ដំណុះកូនបន្លែឲ្យដុះធំធាត់ និងមិនក្រិន។ ម្យ៉ាងទៀតការលើករងបានត្រឹមត្រូវធ្វើអោយបន្លែជៀសផុតពីការជាំទឹក ស្មៅដុះ ឬសត្វល្អិតចង្រៃផ្សេងៗ។ សម្រាប់ដំណាក់កាលដាំដុះ រងត្រូវលើកខ្ពស់ ស្មើស្អាត និងមិនដក់ទឹក ការធ្វើដូច្នេះនាំឱ្យពេលដក់ទឹកហើយបន្លែរលួយ កសិករអាចងាយស្រួលក្នុងការកែរងឡើងវិញ។
- បន្ទាប់ពីលើករងសម្រាប់ការដាំដុះបន្លែរួចហើយ កសិករធ្វើការរោយជីទ្រាប់បាត។ សម្រាប់ដំណាំបន្លែសរីរាង្គ កសិករដាក់ជីអាច់គោទ្រាប់បាតហើយស្រោចទឹក ប៉ុន្តែចំពោះបន្លែសុវត្ថិភាព ពួកគាត់ធ្វើការរោយម្សៅជីធម្មជាតិរបស់ជប៉ុនរហូតដល់បាន១៥ថ្ងៃ ទើបកសិករដកកូនមកដាំ។

**ខ. ការជ្រើសរើសពូជ**

ចំពោះកាជ្រើសរើសគ្រាប់ពូជវិញក៏ជាកត្តាមួយសំខាន់សម្រាប់ការដាំបន្លែផងដែរ។ គ្រាប់ពូជដែលកសិករប្រើប្រាស់នៅទីនេះ គឺកសិកររក្សាទុកគ្រាប់ពូជដោយខ្លួនឯងចំពោះពូជស្ពៃចង្កឹះ នៅពេលបន្លែស្ពៃដាំបានផលល្អ ចំណែកឯគ្រាប់ពូជសាលាដ ស្ពៃក្រញាញ់ ខ្ទឹមស្លឹក និងបន្លែមួយចំនួនទៀត កសិករទិញពីទីផ្សារក្នុងស្រុកដូចជាផ្សារអូររាំងឪ ផ្សារត្បូងឃ្មុំ ជាដើម។ ចំពោះគ្រាប់ពូជមានលក់ជាកញ្ចប់ និងកំប៉ុង។ ចំពោះតំលៃគ្រាប់ពូជកញ្ចប់ មួយកញ្ចប់៥០០០រៀល ចំណែកឯគ្រាប់ពូជកំប៉ុងវិញ មួយកំប៉ុង១០០០០រៀល។

**គ. ការដាំដុះ**

បន្ទាប់ពីកសិករលើករងនិងរីដីស្អាតហើយ ពួកគាត់ដាក់សាបគ្រាប់ និងស្រោចទឹកអោយលប់គ្រាប់បន្តិចហើយយកសំណាញ់ខ្មៅមកគ្រប។ ចំពោះវិធីសាបគ្រាប់ កសិករដាក់គ្រាប់ក្នុងកំប៉ុងត្រីខ ឬកំប៉ុងដាក់គ្រាប់ពូជដែលទិញមកពីផ្សារដែលបានចោះរន្ធតូចៗរួច ហើយអង្រួនអោយស្មើ បន្ទាប់មកបាចដីផេះធម្មជាតិជប៉ុនបន្តិចហើយស្រោចទឹក។ បន្ទាប់ពីធ្វើការសាបគ្រាប់ពូជរួចរាល់ កសិករយកសំណាញ់ខ្មៅមកគ្របចំនួន២យប់ហើយ

ទើបបើកសំណាញ់សំដិល។ ចំពោះខែវស្សាវិញ នៅពេលភ្លៀងគេដាក់សំណាញ់ពណ៌ស ពីព្រោះសំណាញ់ស នេះមានលក្ខណៈញឹក អាចការពារកូនបន្លែពីការខូចខាតដោយសារទឹកភ្លៀងបាន។ កសិករស្រោចទឹក៣ដង ក្នុងមួយថ្ងៃរហូតដល់កូនបន្លែដុះបែកស្លឹក៣ ទើបប្រស់ជីអ៊ុយរេបន្តិចចំពោះបន្លែសុវត្ថិភាព និងមិនប្រើជីអ្វីទាំង អស់ចំពោះបន្លែសរីរាង្គ។ បន្ទាប់ពីធ្វើការបណ្តុះអស់រយៈពេល១៥ថ្ងៃហើយ កសិករដកកូនបន្លែមកដាំលើរង ដែលបានរៀបចំស្អាតនិងបានដាក់ជីទ្រាប់បាតរួចរាល់។ ចំពោះកូនបន្លែ កសិករធ្វើការរើសកូនណាធំៗ ថ្លោស ល្អមកដាក់ដាំដោយដាំចំងាយពីគ្នា១ដើម ១តឹក ក្នុង១រង កសិករដាក់ដាំ១០ជួរ។ កូនបន្លែតូចៗ កសិករទុកវា ដកពេលក្រោយ ហើយកសិករបន្តធ្វើការដកកូនបន្លែបន្តបន្ទាប់រហូតដល់អស់ពីរងបណ្តុះ។

**ឃ. ការថែទាំ**

បន្ទាប់ពីដាក់ដាំហើយកសិករគ្របរងបន្លែ ៣យប់៣ថ្ងៃដើម្បីអោយត្រជាក់ បន្ទាប់ពីបើករងបាន២ថ្ងៃហើយ កសិករប្រស់ជីអ៊ុយរេតិចៗ។ បើមានដង្កូវ កសិករធ្វើការបង្ហើរថ្នាំតិចៗផងដែរ។ ក្នុងរយៈពេលប្រហែលជា១០ ថ្ងៃ កសិករធ្វើការប្រស់ជីអ៊ុយរេតិចៗទៀតរហូតដល់បន្លែបាន ១៥ ទៅ១៧ថ្ងៃ ទើបចាប់ផ្តើមកាត់។ បើបន្លែមាន ដង្កូវកសិករប្រើជីពណ៌សញ្ញាក្បាលក្របី តែបើអត់ដង្កូវកសិករមិនប្រើថ្នាំទេ ហើយកសិករផ្អាកបាញ់ថ្នាំមួយស ប្តាហ៍មុនពេលកាត់ ។ សត្វល្អិតដែលកសិករជួបច្រើនជាងគេគឺដង្កូវរយោលទោង។

**ង. ការស្រោចទឹក**

មុនធ្វើការស្រោចទឹក កសិករធ្វើការសង្កេតទៅលើរង។ បើរងជោរទឹក កសិករស្រោចទឹកក្នុងមួយថ្ងៃតែ២ ដងប៉ុណ្ណោះ គឺស្រោចនៅពេលថ្ងៃ និងពេលល្ងាច។ បើនៅខែក្តៅខ្លាំង កសិករធ្វើការស្រោចទឹក៣ដងក្នុងមួយ ថ្ងៃ ដោយស្រោចពេលព្រឹកនៅម៉ោងដប់ព្រឹក ពេលថ្ងៃស្រោចនៅម៉ោង១រសៀល និងពេលល្ងាចធ្វើការស្រោច ទឹកនៅម៉ោង៥ល្ងាច។ បើសិនកសិករបានធ្វើការបាញ់ថ្នាំពីល្ងាច នោះព្រឹកថ្ងៃបន្ទាប់កសិករនឹងធ្វើការស្រោច ទឹកដើម្បីកុំអោយបន្លែរលួយខូចស្លឹក។ ចំពោះរបៀបស្រោចស្រពវិញ កសិករនៅឃុំនេះប្រើវិធីស្រោចផ្សេងៗពី គ្នា។ ចំការខ្លះប្រើវិធីស្រោចដោយប្រើប្រព័ន្ធបង្ហូរទឹកខ្មើប ខ្លះប្រើទុយោសាចដែលមានលេខ៥. ៤. ឬ៣.។ ចំណែកកសិករដែលមានចំការបន្លែតូចៗ ពួកគាត់ប្រើធុងស្រោច។ ចំពោះការស្រោចទឹក កសិករចំណាយតែ លើថ្លៃប្រេងបូមទឹកពីអណ្តូងមកប៉ុណ្ណោះ។

**ច. ការប្រមូលផល**

សម្រាប់ស្ពៃចង្កឹះបន្ទាប់ពីដាំបាន១៥ទៅ១៧ថ្ងៃ កសិករចាប់ផ្តើមធ្វើការកាត់ប្រមូលផល តែបើបន្លែមិនសូវ ល្អ កសិករពន្យាថ្ងៃកាត់បន្លែរហូតដល់រយៈពេល២០ថ្ងៃរាប់ចាប់ពីថ្ងៃដាំលើរង។ ចំពោះសាលាដមានរយៈពេល ដាំដុះយូរថ្ងៃជាងបន្លែស្ពៃ គឺបន្លែនេះមានរយៈពេលពី២២ទៅ២៥ថ្ងៃ ទើបបានកាត់។ ចំណែកខ្ទឹមស្លឹកចំណាយ

ពេលរហូតដល់១ខែ៥ថ្ងៃ ទើបបានកាត់។ ចំពោះមធ្យោបាយប្រមូលផល កសិករប្រើកាំបិតតូចៗ ដើម្បីកាត់បន្លែតាមរងនីមួយៗ ដោយបេះចេញនៅដើមនិងស្លឹកដែលខូចចេញ និងច្រកចង់ជាការស្រេច។ កសិករមិនចាំបាច់ចំណាយលើការដឹកជញ្ជូនបន្លែយកអោយឈ្មួញនោះទេ ពីព្រោះថាពេលប្រមូលផលឈ្មួញកណ្ដាលមកយកបន្លែដល់ចម្ការ បើសិនបន្លែត្រូវកាត់ស្អែក កសិករត្រូវប្រាប់ឈ្មួញជាមុនមួយថ្ងៃ។ ដូច្នេះស្អែកព្រលឹមឡើងឈ្មួញកណ្ដាលនឹងយកចង់មកទុកអោយច្រកបន្លែ និងដឹកយកទៅដោយខ្លួនឯង។

**ឆ. រដូវដាំដុះបន្លែ**

នៅខែប្រាំងបន្លែសម្បូរសត្វបំផ្លាញជាងគេ ជាពិសេសនៅខែមករា និងជួនកាលចេញនៅខែមេសា ដូច្នេះកសិករមិនអាចដាំស្ពៃចង្កឹះបានទេ។ កសិករដាំបន្លែប្រភេទស្ពៃខ្លះផ្អាកការដាំដុះមួយរយៈពេល ហើយកសិករខ្លះទៀតងាកមកដាំខ្ទឹមស្លឹក និងសាលាដនៅរដូវកាលនេះ។ ខែដែលបន្លែងាយស្រួលដាំជាងគេគឺនៅខែតុលា ខែវិច្ឆិកា និងខែធ្នូ ហើយបន្លែលក់បានថ្លៃនិងបានផលច្រើនថែមទៀត។ ចាប់ពីខែមករា ដល់ខែមីនា ខែមេសា បន្លែស្ពៃចង្កឹះដែលកសិករនិយមដាំមានតំលៃថោក រហូតដល់ខែមេសា ខែឧសភា ខែមិថុនា បន្លែដាំមិនសូវបានផលទេ ពីព្រោះវាជារដូវក្ដៅបន្លែពិបាកក្នុងការដុះលូតលាស់។ ដូច្នេះកសិករដាំខ្ទឹមស្ទើរតែពេញចំការតែម្ដង ព្រោះវាបានតំលៃរហូតដល់៣៥០០រៀលក្នុង១គីឡូក្រាម។ ចំពោះបន្លែមួយចំនួនដែលដាំមិនបាននៅខែក្ដៅខ្លាំងហើយខ្វះទឹកមិនអាចដាំដុះបាន ឈ្មួញបាននាំចូលបន្លែពីខេត្តដទៃដែលអាចដាំដុះបាននៅរដូវក្ដៅនេះមកផ្គត់ផ្គង់តម្រូវការបន្លែក្នុងស្រុក។

**ជ. ប្រភពទឹក**

ទឹកគឺជាកត្តាជំរុញការលូតលាស់របស់ដំណាំបន្លែ។ កាលណាកសិករធ្វើការស្រោចស្រពទឹកមិនគ្រប់គ្រាន់ទេ បន្លែដុះលូតលាស់នឹងមិនបានល្អ ក្រិន ខ្វះប្រូតេអ៊ីន និងមិនមានរសជាតិឆ្ងាញ់។ ដូច្នេះសម្រាប់ចំការបន្លែនីមួយៗ ត្រូវមានប្រភពទឹកនៅជិត និងមានទឹកគ្រប់គ្រាន់សម្រាប់ស្រោច។ ចំពោះកសិករនៅក្នុងឃុំនេះប្រើទឹកអណ្ដូងសម្រាប់ស្រោចស្រព។ ចំការបន្លែដែលតូច កសិករប្រើអណ្ដូងមួយរួមគ្នា (ពីរចម្ការអណ្ដូងមួយ) ហើយកសិករដែលមានដីចម្ការបន្លែធំវិញ ប្រើអណ្ដូងមួយសម្រាប់ស្រោចស្រពចម្ការបន្លែមួយ។ អណ្ដូងភាគច្រើនត្រូវបានជីកនៅជិតចំការបន្លែតែម្ដង ដើម្បីងាយស្រួលក្នុងការបូមទឹកស្រោចបន្លែ និងចំណេញប្រេង។

**ឈ. ប្រភពដើមទុន**

ដើមទុនជាកត្តាមួយសំខាន់សំរាប់ការចាប់ផ្ដើមធ្វើអ្វីមួយ មិនថាមុខរបរនោះធំឬតូចនោះទេ។ បើមិនមានដើមទុនទេ ទោះបីជាមានគំនិតចង់ធ្វើអ្វីក៏មិនអាចចទៅរួចដែរ។ ជាពិសេសក្នុងការធ្វើកសិកម្ម កសិករត្រូវមានដើមទុនក្នុងការទិញជី ប្រេង សំណាញ់ និងទិញសម្ភារៈផ្សេងទៀតដែលត្រូវការក្នុងដំណើរការដាំដុះនិងថែទាំ

ហេតុដល់ប្រមូលផលបន្លែ។ ជាក់ស្តែងកសិករនៅក្នុងឃុំនេះភាគច្រើនមានប្រាក់ដើមទុនខ្លួនឯងសំរាប់ដាំបន្លែ និងខ្លះទៀតពីដំបូងឡើយបានទទួលប្រាក់ទុនពីអង្គការប៉ាឌីដែលជាអង្គការបានចុះមកផ្សព្វផ្សាយបច្ចេកទេសកសិកម្មដោយសហការជាមួយខាងមន្ទីរកសិកម្មខេត្តព្រៃវែង។ នាពេលនោះ អង្គការបានផ្តល់ប្រាក់ទុនមួយចំនួន៣២០០០០រៀល ដល់កសិករដែលខ្វះខាតទុន ដោយអោយកសិករខ្ចីជាទុនបង្វិល ដោយក្នុងការខ្ចីប្រាក់ ១០០០០រៀល គិតការប្រាក់២០០រៀល។

### ៣.៣.៣. ស្ថានភាពទីផ្សារបន្លែនៅក្នុងឃុំគោកគង់លិច

#### ក. ទីផ្សារបន្លែ

ទីផ្សារជាកន្លែងដោះដូរទំនិញរវាងអ្នកផ្គត់ផ្គង់ និងអ្នកទិញដែលមានតម្រូវការលើទំនិញ ឬសេវាកម្មហើយមានលទ្ធភាពក្នុងការទិញ។ យោងតាមការចុះសម្ភាសន៍កសិករដាំបន្លែនៅក្នុងឃុំគោកគង់លិច យើងឃើញថាបន្លែនៅទីនេះមានទីផ្សារណាស់ ដោយភាគច្រើនត្រូវបានឈ្មួញកណ្តាលចុះមកប្រមូលទិញផ្ទាល់ដល់ចំការតែម្តង។ កសិករយល់ថាការលក់បន្លែអោយឈ្មួញមកទិញដល់ចំការបែបនេះចំណេញពេលវេលា មិនចាំបាច់ចំណាយទៅលើថ្លៃដឹកជញ្ជូនបន្លែទៅកាន់ទីផ្សារនោះទេ ចំណែកឯតំលៃវិញ មានភាពខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ ដោយបន្លែដែលឈ្មួញយកទៅលក់បន្តអោយអ្នកលក់រាយនៅតាមផ្សារនីមួយៗក្នុងស្រុក មានតំលៃលើសពីតំលៃ ដែលពួកគាត់លក់ទៅអោយឈ្មួញក្នុង១គីឡូក្រាម៥០០រៀល ទៅ១០០០រៀលតែប៉ុណ្ណោះ។ ដូច្នេះឈ្មួញកណ្តាលចំណេញ៥០០រៀល ទៅ១០០០រៀលក្នុង១គីឡូក្រាម។ ចំពោះការផ្គត់ផ្គង់បន្លែបន្តទៅកាន់ផ្សារប្រើប្រាស់ ឈ្មួញបោះបន្លែតទៅកាន់ផ្សារក្នុងស្រុកមួយចំនួនដូចជា ផ្សារស្ទួង ផ្សារអូររាំងឪ ខេត្តត្បូងឃ្មុំ ផ្សារមួយចំនួនទៀត ហើយឥលូវមានឈ្មួញមកពីស្រុកឆ្ងាយដូចជាក្រចេះ ស្ទឹងត្រែងមកសួរនាំទិញផងដែរ។ ក្រៅពីនេះមានឈ្មួញបន្លែពីភ្នំពេញចុះមកប្រមូលទិញបន្លែ នៅពេលបន្លែនៅភ្នំពេញមិនគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការ។ បន្លែទាំងអស់ត្រូវបានប្រមូលទិញអស់ៗ ទោះបីខែសម្បូរក៏ដោយក៏ប៉ុន្តែបានតំលៃថ្លៃថោក។ បន្លែកសិករនិយមដាំមានបន្លែប្រភេទស្ពៃ សាលាដ ខ្ទឹមស្លឹក ម្រះ និងត្រសក់ជាដើម។ ចំពោះស្ពៃចង្កឹះមានតំលៃថោកដោយសារកសិករនៅទីនេះនិយមដាំច្រើនតាមគ្នា។ ដូច្នេះកសិករមួយចំនួនងាកមកដាំសាលាដនៅរដូវដាំដុះស្ពៃចង្កឹះ ដើម្បីអាចលក់បានថ្លៃនិងរកចំណូលបានច្រើន។ ចំពោះផលបន្លែបើនៅពេលទទួលបានផលល្អមធ្យម ហើយមិនមានទទួលរងការបំផ្លាញពីសត្វចង្រៃនោះ កសិករអាចទទួលផលបន្លែបានប្រមាណ១០០គីឡូក្រាមក្នុង១រង បើបន្លែបានផលល្អខ្លាំងនោះកសិករអាចបានផល១៥០គីឡូក្រាមទៅ ១៨០គីឡូក្រាមក្នុង១រង។ នៅខែតុលា ខែវិច្ឆិកា និងខែធ្នូ បន្លែស្ពៃចង្កឹះលក់បានថ្លៃប្រហែល១២០០រៀល ទៅ ១៥០០រៀលក្នុងមួយគីឡូក្រាម។ ចំណែកសាលាដបានតំលៃប្រហែល ២០០០រៀលក្នុងមួយគីឡូក្រាម។ នៅ

ខែមករា ខែមីនា ខែមេសា បន្លែស្ពៃចង្កឹះទទួលបានផលច្រើនហើយកសិករដាំបន្លែនេះស្ទើរគ្រប់គ្នា ដែលជាហេតុនាំឲ្យស្ពៃចង្កឹះធ្លាក់ថ្លៃយ៉ាងខ្លាំង មកត្រឹមតំលៃ៤០០រៀលក្នុងមួយគីឡូក្រាមប៉ុណ្ណោះ។ ទោះបីជាធ្លាក់ថ្លៃដូច្នេះក៏ដោយ ក៏ប៉ុន្តែឈ្មួញនៅតែមកប្រមូលទិញអស់ៗ។ រហូតមកដល់ខែមេសា ខែឧសភា ខែមិថុនា បន្លែដាំមិនសូវបានផលទេ ដូច្នេះកសិករងាកមកដាំខ្ទឹមស្លឹក ព្រោះបានតំលៃរហូតដល់៣៥០០រៀល ក្នុងមួយគីឡូក្រាមឯណោះ។ នៅរដូវក្តៅកសិករនៅទីនេះមិនអាចដាំដុះបន្លែបាន ដូច្នេះបន្លែត្រូវបានឈ្មួញនាំចូលមកពីស្រុកស្អាង ខេត្តកណ្តាល និងខេត្តត្បូងឃ្មុំដើម្បីបំពេញតម្រូវការបន្លែក្នុងស្រុក។

### ខ. បណ្តាញចែកចាយផលិតផលបន្លែ

ក្នុងការចែកចាយបន្លែផលិតបានក្នុងឃុំគោកគង់លិច ស្រុកកញ្ច្រៀច ខេត្តព្រៃវែងនេះ ឈ្មួញកណ្តាលមានតួនាទីសំខាន់ក្នុងការនាំយកបន្លែពីចំការបន្លែរបស់កសិករទៅកាន់ទីផ្សារ។ បន្លែត្រូវបានឈ្មួញកណ្តាលប្រមូលទិញនាំយកបោះដុំឱ្យអ្នកលក់បន្លែតាមតូបក្នុងផ្សារដើម្បីលក់បន្តដល់អ្នកបរិភោគ។ ចំណែកឯ អ្នកលក់បន្លែនៅផ្សារខ្លះទៀតមកទិញបន្លែពីចំការទៅលក់ខ្លួនឯងតែម្តង ហើយក៏មានប្រជាពលរដ្ឋមួយចំនួនតូចមកសុំចែកទិញបន្លែពីចំការទៅបរិភោគផងដែរ។

# ជំពូកទី៤
# របកគំហើញ និង ការវិភាគ

តាមរយៈការបកស្រាយនៅក្នុងជំពូក១ ជំពូកទី២ និងជំពូកទី៣រួចមក យើងអាចបានយល់ច្បាស់នូវទ្រឹស្តី និងស្ថានភាពទីផ្សារបន្លែក៏ដូចជាតម្រូវការ និងការផ្គត់ផ្គង់បន្លែនៅក្នុងរាជធានីខេត្ត៩ ដែលបានសិក្សាស្រាវជ្រាវដោយមជ្ឈមណ្ឌលសិក្សាគោលនយោបាយ ព្រមទាំងវិធីសាស្ត្រដាំដុះបន្លែទាំងសរីរាង្គនិងសុវត្ថិភាព រួមទាំងការអនុវត្តការដាំដុះជាក់ស្តែងរបស់កសិករក្នុងឃុំគោកគង់លិចផងដែរ។ នៅក្នុងជំពូកនេះនាងខ្ញុំនឹងធ្វើការវិភាគតាមបែបSWOT ដែលជាការវិភាគទៅលើកត្តាខាងក្នុង និងកត្តាខាងក្រៅរបស់អាជីវកម្មមួយ ដោយផ្អែកទៅលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគម្រាមកំហែង។

## ៤.១. ការវិភាគSWOT លើតម្រូវការបន្លែនិងការផ្គត់ផ្គង់បន្លែនៅកម្ពុជា

បន្ទាប់ពីការសិក្សាស្វែងយល់ពីតម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជានៅក្នុងជំពូក២រួចមក នាងខ្ញុំបានធ្វើការវិភាគ និងបានរកឃើញចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង នៃតម្រូវការ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជាដូចខាងក្រោម៖

❖ **ចំណុចខ្លាំងនៃទីផ្សារបន្លែក្នុងស្រុក**

- ទីផ្សារបន្លែក្នុងស្រុកមានតម្រូវការដល់ទៅ១០៥៨តោនក្នុងមួយថ្ងៃ
- បន្លែផ្គត់ផ្គង់ពីក្នុងស្រុកមិនមានផ្ទុកសារធាតុទប់ស្កាត់ការរលួយដូចបន្លែនាំចូល
- មានគុណភាព និងសុវត្ថិភាពជាងបន្លែនាំចូល
- បន្លែផលិតក្នុងស្រុកភាគច្រើនអាចផ្គត់ផ្គង់ក្នុងតម្លៃទាបជាងបន្លែនាំចូល

❖ **ចំណុចខ្សោយនៃទីផ្សារបន្លែក្នុងស្រុក**

- មិនអាចផលិតបានគ្រប់គ្រាន់តាមតម្រូវការ
- បន្លែមួយចំនួនមិនសមស្របនឹងលក្ខខណ្ឌអាកាសធាតុនៅកម្ពុជា បន្លែខ្លះទៀតដាំបានបរិមាណតិចតួចដោយសារស្ថានភាពដី និងខ្លះត្រូវការចំណាយទុនខ្ពស់
- បន្លែក្នុងស្រុកមិនសូវមានសោភ័ណភាពដូចបន្លែនាំចូល
- មានបន្លែតែ៩មុខប៉ុណ្ណោះដែលផ្គត់ផ្គង់ទាំងស្រុង ឬស្ទើរតែទាំងស្រុងពីអ្នកផលិតក្នុងស្រុក
- មានបន្លែ៧ប្រភេទដែលនាំចូលទាំងស្រុង ឬស្ទើរតែទាំងស្រុងពីបរទេស មានបរិមាណសរុបរហូតដល់ ១៦៣.៦តោនក្នុងមួយថ្ងៃ (ក្រូចឆ្មារនាំចូលស្ទើរតែទាំងស្រុង ផលិតក្នុងស្រុកបានតិចតួច)
- បន្លែមានតម្រូវការខ្ពស់មួយចំនួន មិនអាចដាំដុះបានដោយសារអាកាសធាតុ និងចំណាយទុនខ្ពស់។

❖ **ឱកាស**

- មានបរិមាណបន្លែ៥៥២តោន ដែលកម្ពុជាអាចពិចារណាបង្កើនការដាំដុះផ្គត់ផ្គង់ពីក្នុងស្រុក
- ក្នុងចំណោមបន្លែមានតម្រូវការបន្ថែម សុទ្ធសឹងតែជាប្រភេទបន្លែដែលអាចដាំដុះបាននៅក្នុងស្រុក
- បន្លែនាំចូលភាគច្រើនមានតម្លៃខ្ពស់ជាងបន្លែផលិតក្នុងស្រុក
- បន្លែដែលមានតម្រូវការខ្ពស់ភាគច្រើនជាបន្លែដែលមានសក្តានុពលអាចដាំដុះបានក្នុងស្រុក និងមានតម្លៃថោកជាងបន្លែនាំចូល
- នៅតាមខេត្តនីមួយៗសុទ្ធតែមិនទាន់ផលិតបន្លែបានគ្រប់គ្រាន់តាមតម្រូវការបន្លែក្នុងខេត្តរបស់ខ្លួននៅឡើយ ដែលវាជាឱកាសល្អមួយដែលកសិករក្នុងខេត្តនីមួយៗគួរចាប់យក

❖ **ការគំរាមកំហែងនៃបន្លែនាំចូល**

- ប៉ះពាល់សុខភាព កម្លាំង ប្រាជ្ញាស្មារតី
- ជីវភាពប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋបោះបង់របរកសិកម្ម
- បន្លែគ្មានទីផ្សារ កសិកម្មក្នុងស្រុកថយទៅៗ
- ចំណាយជាតិកើនឡើង។

❖ **ការគំរាមកំហែងចំពោះឱកាសផ្គត់ផ្គង់បន្លែម**

- អាកាសធាតុ
- ថ្លៃ ឬតម្លៃ
- សោភ័ណភាពនៃបន្លែ
- ប្រភពស្រោចស្រព
- បន្លែគរចោល គ្មានទីផ្សារ
- ស្ថានភាពដីនៅតំបន់មួយចំនួនមិនអំនោយផលដល់ការដាំដុះ និងត្រូវចំណាយទុនខ្ពស់។

## ៤.២. វិភាគSWOT លើវិធីសាស្ត្រដាំដុះបន្លែសរីរាង្គ និងសុវត្ថិភាព

យោងទៅតាមវិធីសាស្ត្រដាំដុះបន្លែ ទាំងសរីរាង្គ និងសុវត្ថិភាពនៅក្នុងជំពូកទី៣ នាងខ្ញុំបានរកឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងនៃវិធីសាស្ត្រដាំដុះនីមួយៗដូចខាងក្រោម៖

### ៤.២.១. វិភាគSWOT លើវិធីសាស្ត្រដាំដុះបន្លែសរីរាង្គ

❖ **ចំណុចខ្លាំង**

- មានសុវត្ថិភាព គុណភាព រសជាតិឆ្ងាញ់ មានប្រូតេអ៊ីនខ្ពស់ មិនមានផ្ទុកសារជាតិពុលគីមី
- ចំណាយតិចដោយប្រើជីធម្មជាតិនិងថ្នាំកសិកម្មកម្ចាត់កត្តាចង្រៃ
- លក់បានតម្លៃខ្ពស់
- មិនប៉ះពាល់បរិស្ថាន ទឹក មិនធ្វើឱ្យខូចដីជាតិដី
- កាត់បន្ថយកាកសំណល់សារធាតុសរីរាង្គ ជួយបង្កើនបរិមាណពពួកម៉ាក្រូ និងពពួកមីក្រូសរីរាង្គនៅក្នុងដីដែលជាការជួយដល់គុណភាពដី ខ្យល់ ទឹក និងដី
- ជួយកាត់បន្ថយការកើនឡើងកម្តៅផែនដីពីការបំពុលតាមរយៈថ្នាំពុលគីមី
- ដីអាចប្រើប្រាស់ធ្វើការដាំដុះបានរយៈពេលយូរ
- មិនប៉ះពាល់សុខភាពអ្នកដាំ និងអ្នកបរិភោគ
- អ្នកបរិភោគមានរាងកាយមាំមួនសុខភាពល្អ មិនមានជំងឺបៀតបៀន មានប្រាជ្ញាឈ្លាសវៃ
- ទទួលបានការគាំទ្រពីបណ្តាលផ្សារទំនើប ម៉ាតនានានៅទីក្រុងភ្នំពេញ
- ទទួលបានការបណ្តុះបណ្តាលនិងជំនួយច្រើនពីបណ្តាលអង្គការនានា
- ធ្វើការផ្គត់ផ្គង់បន្លែព្រមជាមួយនឹងគុណភាព និងការធានាសុវត្ថិភាពសុខភាព។

❖ **ចំណុចខ្សោយ**

- មិនសូវមានសោភ័ណភាព
- ចំណាយរយៈពេលក្នុងការដាំដុះយូរទើបបានផល
- ចំណាយកម្លាំងពលកម្មខ្ពស់
- តម្លៃខ្ពស់ជាងបន្លែធម្មតា
- ពិបាកក្នុងការសម្គាល់ពីភាពខុសគ្នារវាងបន្លែសរីរាង្គ និងបន្លែធម្មតា
- ទីផ្សារមិនទាន់ស្គាល់ទូលំទូលាយ
- ពិបាកក្នុងការរកវត្ថុធាតុដើមដើម្បីផលិតជីកំប៉ុស្ត ឬថ្នាំកសិកម្ម
- ងាយទទួលរងការបំផ្លាញពីកត្តាចង្រៃ
- ផលិតបានតិចក្នុងមួយរដូវកាលដាំដុះ ដែលមិនអាចផ្គត់ផ្គង់ទាន់តាមតម្រូវទីផ្សារ។

❖ **ឱកាស**

- ទីផ្សារស្ថិតក្នុងកម្រិតដំបូង ដែលផ្តលឱកាសសម្រាប់ការពង្រីក និងទទួលស្គាល់ច្រើន

❖ **ការគំរាមកំហែង**

- ពិបាកក្នុងការធ្វើឱ្យអ្នកបរិភោគជឿជាក់ថាជាបន្លែគ្មានជាតិគីមី
- ពិបាកក្នុងការសម្គាល់ថាជាបន្លែសរីរាង្គ
- តម្លៃថ្លៃអាចជាកត្តាជះឥទ្ធិពលដល់ការទិញ
- ងាយទទួលរងការគម្រាមកំហែងពីកត្តាចង្រៃ
- ពិបាកក្នុងការប្រឈមជាមួយកត្តាអាកាសធាតុប្រែប្រួល និងទឹកស្រោចស្រព
- ពិបាកក្នុងការប្រកួតប្រជែងផ្នែកសោភ័ណភាព និងតម្លៃជាមួយនឹងបន្លែនាំចូល
- បន្លែរក្សាទុកមិនបានយូរ ងាយខូច ងាយរលួយ
- អាចខ្វះខាតវត្ថុធាតុដើមក្នុងការផលិតជី ថ្នាំកសិកម្មពីធម្មជាតិ
- អាចខ្វះខាតកម្លាំងពលកម្មក្នុងការដាំដុះ និងធ្វើជីធម្មជាតិ។

**៤.២.២. វិភាគSWOT លើវិធីសាស្ត្រដាំដុះបន្លែសុវត្ថិភាព**

❖ **ចំណុចខ្លាំង**

- មានសុវត្ថិភាព សោភ័ណភាព និងគុណភាព
- តម្លៃមិនថ្លៃដូចបន្លែសរីរាង្គ
- ទទួលបានផលច្រើន ហើយឆាប់ហ័ស
- ប្រើកម្លាំងពលកម្មតិច ស្ត្រីក៏អាចធ្វើបាន
- មិនត្រូវការវត្ថុធាតុដើមក្នុងការផលិតជី ឬថ្នាំ និងមិនចំណាយពេលវេលាច្រើនលើការផលិត
- រឹងមាំអាចទប់ទល់នឹងកត្តាអាកាសធាតុ និងកត្តាចង្រៃមួយចំនួនបាន
- មិនប៉ះពាល់ដល់សុខភាពអ្នកដាំ និងអ្នកបរិភោគដោយការប្រើប្រាស់ថ្នាំតាមកំណត់ មានស្តង់ដារ
- មានការទទួលស្គាល់ និងមានទីផ្សារខ្ពស់
- មានរសជាតិឆ្ងាញ់
- មិនប៉ះពាល់ដល់បរិស្ថាន គុណភាពដី និងធម្មជាតិ។

❖ **ចំណុចខ្សោយ**

- ចំណាយលើការប្រើប្រាស់ថ្នាំគីមី និងសម្ភារៈផលិតដូចជាផ្ទះសំណាញ់ ប្រព័ន្ធទឹក ធ្វើរោង ឬទ្រើង...

❖ **ឱកាស**

- ក្លាយជាប្រភពបន្លែដែលផ្គត់ផ្គង់បន្លែលើទីផ្សារជំនួសបន្លែនាំចូល។

❖ **ការគម្រាមកំហែង**

- តម្លៃអាចធ្លាក់ថោកនៅរដូវប្រមូលផល ព្រោះការនិយមដាំបន្លែប្រភេទដូចគ្នា។

## ៤.៣. វិភាគលើការដាំដុះបន្លែជាក់ស្តែងនៅឃុំគោកគង់លិច

### ៤.៣.១. វិភាគSWOTលើការដាំដុះបន្លែជាក់ស្តែង

❖ **ចំណុចខ្លាំង**

- កសិករនៅទីនេះមានបទពិសោធន៍ដាំដុះយូរឆ្នាំ និងមានបច្ចេកទេសដាំដុះត្រឹមត្រូវ
- ផ្ទៃដីមានជីជាតិ អាកាសធាតុអំណោយផល និងប្រភពទឹកស្រោចស្រពគ្រប់គ្រាន់នៅរដូវធម្មតា
- បន្លែមានទីផ្សារ ហើយដាំបានផលច្រើន
- បន្លែដាំដុះទីនេះ ត្រូវបានចែកចាយទៅកាន់ផ្សារក្នុងស្រុក ខេត្តជិតៗ និងនាំមកភ្នំពេញមួយចំនួន
- ទទួលបានគាំទ្រពីខាងកសិកម្មក្នុងឃុំ និងមានអ្នកផ្សព្វផ្សាយកសិកម្មជួយផ្តល់យោបល់និងផ្តល់ទុន
- មានកេរ្តិ៍ឈ្មោះ និងមានការទទួលស្គាល់ចំពោះការដាំដុះបន្លែសុវត្ថិភាព និងសរីរាង្គយូរឆ្នាំ
- បន្លែស្តែអំណោយផលក្នុងការដាំដុះខ្លាំង ហើយនៅរដូវប្រាំងកសិករអាចដាំដុះបន្លែបាននៅក្នុងវាលស្រែថែមទៀត។

❖ **ចំណុចខ្សោយ**

- ប្រភពទឹកខ្វះនៅរដូវក្តៅខ្លាំង ដោយសារអណ្តូងមិនសូវមានទឹក
- ប្រជាពលរដ្ឋនិយមដាំបន្លែប្រភេទតែមួយដូចគ្នា
- មិនដឹងពីតម្រូវការទីផ្សារ ដោយសារការផ្សព្វផ្សាយពីតម្រូវការមានភាពខ្វះខាត
- នៅរដូវក្តៅខ្លាំងអាចជះឥទ្ធិពលដល់ការដាំដុះ។

❖ **ឱកាស**

- អាចក្លាយជាតំបន់ផ្គត់ផ្គង់បន្លែនៅទូទាំងខេត្តព្រៃវែង ហើយនាំចេញផ្គត់ផ្គង់ទៅកាន់ខេត្តដទៃនិងអាចជាប្រភពផ្គត់ផ្គង់បន្លែដល់ក្រុងភ្នំពេញផងដែរ
- ក្លាយជាតំបន់គម្រូសម្រាប់ការដាំដុះបន្លែសរីរាង្គ និងសុវត្ថិភាព។

❖ **ការគម្រាមកំហែង**

- នៅខែក្តៅខ្លាំងប៉ះពាល់ដល់ការដាំដុះ
- បន្លែធ្លាក់ថ្លៃថោកដោយសារកសិករដាំបន្លែប្រភេទតែមួយ
- មានការនាំចូលបន្លែមកពីប្រភពផ្សេង ព្រោះកសិករដាំបន្លែតែប៉ុន្មានប្រភេទដែលធ្លាប់ដាំកន្លងមក
- ផលបន្លែមិនអាចនាំចេញទៅផ្គត់ផ្គង់នៅខេត្តឆ្ងាយៗ ព្រោះតែបច្ចេកទេសក្រោយប្រមូលផលនៅមាន

កម្រិត។

## ៤.៤. ការវិភាគ SWOT រួម

❖ **ចំណុចខ្លាំង**

- ក្នុងចំណោមបន្លែទាំង៤៩មុខ កម្ពុជាអាចដាំដុះបន្លែបានប្រហែល៤៥ប្រភេទ
- មានបន្លែ៩មុខជាបន្លែដែលផ្គត់ផ្គង់ទាំងស្រុង ឬស្ទើរតែទាំងស្រុងពីអ្នកផលិតកក្នុងស្រុក
- មានការជួយលើកទឹកចិត្ត និងបណ្តុះបណ្តាលបច្ចេកទេសដាំដុះពីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម និងអង្គការនានា
- មានការជំនួយទុនពីរាជរដ្ឋាភិបាល
- មានទីផ្សារបន្លែស្រាប់
- សមត្ថភាពក្នុងការដាំដុះបន្លែសរីរាង្គ និងសុវត្ថភាព ដែលចំណាយតិច បានផលច្រើន មានគុណភាព សុវត្ថិភាព មិនប៉ះពាល់បរិស្ថាន មិនប៉ះពាល់សុខភាពអ្នកដាំនិងអ្នកបរិភោគ មានសោភ័ណភាព មិនប៉ះពាល់បរិស្ថាន ទឹក មិនធ្វើឱ្យខូចជីជាតិដី ដីអាចប្រើប្រាស់ធ្វើការដាំដុះបានរយៈពេលយូរ
- ការដាំដុះបន្លែសរីរាង្គ និងសុវត្ថិភាពអាចដាំដុះបានស្ទើរគ្រប់រដូវកាល ស្របនឹងអាកាសធាតុនិងស្ថានភាពដីអំណោយផលដល់ការដាំដុះ។

❖ **ចំណុចខ្សោយ**

- បន្លែនាំចូលមានបរិមាណរហូតដល់៥៥២ (៥២%) នៃបរិមាណតម្រូវការបន្លែសរុប
- បន្លែ៤ប្រភេទដែលស្ថិតនៅក្នុងចំណោមបន្លែមានតម្រូវការខ្ពស់ ត្រូវការនាំចូលពីបរទេសដោយសារកត្តាអាកាសធាតុមិនអំណោយផលសម្រាប់ការដាំដុះ
- បន្លែដែលអាចផលិតបានទាំងស្រុង មិនមែនជាបន្លែស្ថិតនៅក្នុងចំណោមប្រភេទបន្លែ ដែលមានតម្រូវការខ្ពស់
- ប្រភេទបន្លែនាំចូលនាំមុខគេទាំង១០ប្រភេទ សុទ្ធសឹងតែស្ថិតនៅក្នុងចំណោមបន្លែមានតម្រូវការខ្ពស់
- បន្លែ៧ប្រភេទត្រូវបាននាំចូលពីបរទេសមកពីកត្តាអាកាសធាតុ ចំណាយទុនខ្ពស់ក្នុងការផលិត និងបច្ចេកទេសទំនើប
- ខ្វះការផ្សព្វផ្សាយអំពីតម្រូវការបន្លែនៅលើទីផ្សារ ដូចជាប្រភេទបន្លែនិងបរិមាណដែលត្រូវការជាដើម
- មិនទាន់មានការបង្ហាត់បង្រៀនបច្ចេកទេសក្រោយប្រមូលផលដល់កសិករនៅឡើយ
- ប្រភពទឹកមានភាពខ្វះខាតតិចតួចនៅតំបន់មួយចំនួន ដែលធ្វើឱ្យមិនអាចដាំដុះបាន។

❖ **ឱកាស**

- ក្នុងចំណោមតម្រូវការបន្លែសរុប១០៥៨តោនក្នុងមួយថ្ងៃ យើងអាចផ្គត់ផ្គង់បាន៥០៤តោននៅសល់បរិមាណ៥៥២តោនទៀតជាឱកាសផ្គត់ផ្គង់បន្ថែម លើកលែងបន្លែមួយចំនួនដែលមិនអាចដាំដុះបានដោយសារលក្ខខណ្ឌអាកាសធាតុ
- បន្លែនាំចូលខ្លះត្រូវការចំណាយទុនខ្ពស់ក្នុងការផលិត ជាឱកាសសម្រាប់ការផលិតក្នុងស្រុកវិញ
- បរិមាណបន្លែមានតម្រូវការបន្ថែមមានរហូតដល់១០.៧តោនក្នុងមួយថ្ងៃ ដែលជាឱកាសសម្រាប់ផ្គត់ផ្គង់បន្ថែម
- បន្លែដែលមានតម្រូវការបន្ថែមសុទ្ធសឹងតែជាប្រភេទបន្លែអាចផលិតក្នុងស្រុកបាន
- ក្នុងចំណោមបន្លែមានតម្រូវការខ្ពស់បំផុតទាំង១០ប្រភេទ បន្លែ៤ប្រភេទយើងអាចដាំដុះបានច្រើនរួចហើយ រីឯបន្លែ៦មុខទៀតជាឱកាសក្នុងវាយលុកទីផ្សារពីបន្លែក្នុងស្រុក។
- បន្លែនាំចូលភាគច្រើនមានតម្លៃខ្ពស់ជាងបន្លែផលិតក្នុងស្រុក
- ក្នុងចំណោមបន្លែដែលបានស្រាវជ្រាវ៤៩មុខ មានបន្លែនាំចូល២៧មុខមានតម្លៃថ្លៃជាងបន្លែផលិតក្នុងស្រុក ដែលជាឱកាសសម្រាប់បន្លែក្នុងស្រុកឆក់យកទីផ្សារមួយនេះបាន
- នៅតាមខេត្តនីមួយៗ សុទ្ធតែមិនទាន់មានសមត្ថភាពផលិតបន្លែបានគ្រប់គ្រាន់តាមតម្រូវការក្នុងខេត្តរបស់ខ្លួននៅឡើយ វាជាឱកាសល្អមួយដែលកសិករក្នុងខេត្តនីមួយៗគួរចាប់យក

❖ **ការគំរាមកំហែង**

- បន្លែផលិតក្នុងស្រុកចំនួន១៤មុខមានតម្លៃថ្លៃជាងបន្លែនាំចូលជាមធ្យម៦៤៣រៀល/គ.ក ជាហេតុនាំឱ្យបន្លែនាំចូលទទួលបានការគាំទ្រច្រើនជាង
- រាជធានីភ្នំពេញ និងខេត្តចំនួន២ ដែលជាប្រភពចែកចាយបន្លែទៅកាន់ខេត្តនានាទូទាំងប្រទេសគឺជាកន្លែងដែលនាំចូលបន្លែពីបរទេសច្រើនជាងគេបំផុត ដែលនេះស្មើនឹងការផ្សព្វផ្សាយទៅលើការគាំទ្រលើបន្លែនាំចូល ជាហេតុអាចធ្វើអោយទីផ្សារបន្លែក្នុងស្រុកកាន់តែបាត់បង់
- ស្ថានភាពដីនៅតំបន់មួយចំនួនមិនអំនោយផលដល់ការដាំដុះ និងត្រូវចំណាយទុនខ្ពស់
- បន្លែដែលដាំរួចហើយមិនបានវេចខ្ចប់តាមបច្ចេកទេសត្រឹមត្រូវ ងាយប្រឈមនឹងការខូចខាត
- ពិបាកក្នុងការធ្វើឱ្យអ្នកបរិភោគជឿជាក់ថាជាបន្លែគ្មានជាតិគីមី
- នៅខែក្តៅខ្លាំងប៉ះពាល់ដល់ការដាំដុះ

- កសិករដាំបន្លែប្រភេទតែមួយ ដោយសារការខ្វះការយល់ដឹងពីតម្រូវការទីផ្សារ ដែលនាំឱ្យផលបន្លែខ្លះច្រើនជ្រុលហើយបន្លែធ្លាក់ថ្លៃថោក និងបន្លែខ្លះខ្វះខាត ដែលនាំឱ្យមានការនាំចូលពីបរទេសដដែរ
- ផលបន្លែមិនអាចនាំចេញទៅផ្គត់ផ្គង់នៅកន្លែងឆ្ងាយៗបាន ពីព្រោះតែការយល់ដឹងអំពីបច្ចេកទេសក្រោយប្រមូលផលនៅមានកម្រិត។

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សា និងវិភាគទៅលើទីផ្សារបន្លែ និងស្ថានភាពដាំដុះបន្លែនៅកម្ពុជារួចមក យើងឃើញថា ទីផ្សារបន្លែកម្ពុជានៅសល់សក្ដានុពលច្រើនសម្រាប់ប្រជាកសិករដាំបន្លែនៅកម្ពុជា ដោយសារបន្លែដែលកសិករក្នុងស្រុកផលិតបានក្នុងពេលបច្ចុប្បន្នគឺបានត្រឹមតែ៤៨% នៃតម្រូវការទីផ្សារប៉ុណ្ណោះ។ បរិមាណបន្លែ៥២%ទៀត គឺត្រូវបាននាំចូលមកពីបរទេស បណ្ដាលមកពីកត្តា២យ៉ាង។ ទីមួយគឺ បន្លែមួយចំនួនត្រូវការលក្ខខណ្ឌអាកាសធាតុត្រជាក់ទើបអំណោយផលដល់ការដាំដុះ ហើយមិនសមស្របនឹងលក្ខខណ្ឌអាកាសធាតុនៅកម្ពុជា។ ចំណែកឯ កត្តាទីពីរវិញនោះគឺ សមត្ថភាពផលិតបន្លែនៅក្នុងស្រុកមិនទាន់អាចផ្គត់ផ្គង់បន្លែគ្រប់តាមតម្រូវការទីផ្សារបាន ទើបតម្រូវឱ្យមានការនាំចូលបន្លែពីបរទេសដូច្នេះ។ ដូចនេះ យើងឃើញថា បើសមត្ថភាពផលិតបន្លែរបស់កសិករឱ្យការកើនឡើង នោះកម្ពុជានៅសល់ទំហំទីផ្សារធំណាស់សម្រាប់ពួកគាត់ក្នុងការផ្គត់ផ្គង់បន្ថែម។ លើសពីនេះ ទីផ្សារបន្លែបច្ចុប្បន្នក៏កំពុងមានតម្រូវការបន្លែបន្ថែមរហូតដល់ទៅ ១០,៧ តោនក្នុងមួយថ្ងៃថែមទៀត។ ក្រឡេកទៅមើលការដាំដុះបន្លែរបស់ប្រជាកសិករកម្ពុជាវិញ ឃើញថាពួកគាត់អាចមានសមត្ថភាពក្នុងការឈានជើងចូលទីផ្សារទៀតបាន បើសិនជាកត្តាទឹក ទុន ទីផ្សារ ការផ្សព្វផ្សាយ និងបច្ចេកទេស ដែលជាកត្តាជួយបង្កើតសមត្ថភាពផលិតរបស់កសិករ មានភាពល្អប្រសើរ។

ចំពោះបញ្ហាទីផ្សារសម្រាប់ប្រជាកសិករ គឺមានស្រាប់រួចទៅហើយដូចដែលយើងលើកឡើងមកបង្ហាញខាងលើ។ ចំណែកឯបច្ចេកទេសវិញ យើងមានវិធីសាស្ត្រដាំដុះបន្លែសុវត្ថិភាព និងសរីរាង្គដែលជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពក្នុងការជួយបង្កើនផលបន្លែ ចំណាយតិច មានសុវត្ថិភាព និងមានគុណភាពល្អ។ បច្ចេកទេសទាំងនេះគឺត្រូវបានគាំទ្រដោយរាជរដ្ឋាភិបាល ក្រសួងកសិកម្ម និងអង្គការនានា។ សម្រាប់ដើមទុនក្នុងការដាំបន្លែ រាជរដ្ឋាភិបាលក៏បានជួយសម្របសម្រួលដល់កសិករដែលខ្វះខាតដើមទុនផងដែរ។ អ្វីដែលនៅខ្វះចន្លោះនោះ គឺប្រភពទឹកសម្រាប់ស្រោចស្រពបន្លែ និងការផ្សព្វផ្សាយពត៌មានកសិកម្មផ្សេងទៅប្រជាកសិករ។ ចំពោះប្រភពទឹក រាជរដ្ឋាភិបាល និងអង្គការនានាបានជួយក្នុងការរៀបចំប្រព័ន្ធធារាសាស្ត្រ ជីកស្រះ អណ្ដូង និងប្រភពទឹកនានាដល់កសិករ លើកលែងតែនៅតំបន់មួយចំនួនតូចប៉ុណ្ណោះ ដែលនៅខ្វះខាតប្រភពទឹកសម្រាប់ស្រោចស្រពនៅរដូវក្ដៅខ្លាំងនៅឡើយ។ ដូចនេះយើងអាចនិយាយបានថា បញ្ហាទឹកមិនមែនជាបញ្ហាចោទចម្បងនោះទេ។ បញ្ហាដែលកំពុងចោទឡើងនោះគឺ កង្វះការផ្សព្វផ្សាយអំពីតម្រូវការបន្លែនៅលើទីផ្សារឱ្យបានច្បាស់លាស់ដល់កសិករ ថាតើបន្លែប្រភេទណាកំពុងមានតម្រូវការ បន្លែណាត្រូវការបន្ថែម ហើយត្រូវការក្នុងបរិមាណប៉ុន្មាន។ ដូចដែលបានឃើញនាពេលបច្ចុប្បន្ន កសិករភាគច្រើនដាំបន្លែប្រភេទតែមួយច្រើន ដែលនាំ

ឱ្យបន្លែចាស់ គ្មានទីផ្សារ និងលក់បានតម្លៃថោកតាមមាត់របស់ឈ្មួញទិញបន្លែ។ ចំណែកឯបន្លែខ្លះទៀត កសិករដាំមានចំនួនតិច ដែលធ្វើឱ្យបរិមាណបន្លែផលិតបានមិនគ្រប់តាមតម្រូវការទីផ្សារ។

មើលទៅលើការអនុវត្តជាក់ស្តែងរបស់កសិករដាំបន្លែនៅឃុំគោកគង់លិច យើងឃើញថាចំពោះបញ្ហាទុន នោទីនេះ កសិករមិនមានជួបបញ្ហាទុននោះទេ ព្រោះពួកគាត់មានទុនផ្ទាល់ខ្លួនក្នុងការដាំដុះ និងមានអង្គការ ASPIRE រង់ចាំជួយសម្រួលរាល់ការលំបាកនានាទៀតផង។ កត្តាទឹកវិញ កសិករមានអណ្តូងជាប្រភព ស្រោចស្រព ហើយនាពេលខាងមុខខាងមន្ទីកសិកម្មខេត្តព្រៃវែងជាមួយនឹងអង្គការASPIRE គ្រោងនឹងជីក ស្រះដ៏ធំមួយសម្រាប់កសិករ ដើម្បីសម្រួលដល់ការដាំដុះបន្លែរបស់កសិករនៅរដូវប្រាំង។ ដូច្នេះកសិករមិនជួប បញ្ហាទឹកទៀតទេ។។ ចំពោះបច្ចេកទេស កសិករនៅទីនេះបានដាំដុះដោយប្រើបច្ចេកទេសដាំបន្លែសុវត្ថិភាព និងសរីរាង្គ ដែលណែនាំដោយអង្គការASPIRE និងមន្ត្រីខាងមន្ទីកសិកម្ម។ ចាប់តាំងពីមានមន្ត្រីជំនាញផ្នែក កសិកម្មចុះណែនាំ និងបង្រៀនបច្ចេកទេសការដាំបន្លែសរីរាង្គនិងសុវត្ថិភាពមក បន្លែរបស់ពួកគាត់បានផល ច្រើន ដែលនាំឱ្យពួកគាត់រកចំណូលបានច្រើន ដោយសារតែពួកគាត់ចំណាយក្នុងការផលិតតិច ហើយរយៈ ពេលដាំដុះក៏ខ្លីធ្វើឱ្យគាត់ឆាប់បានដាំដុះបន្តទៀត។ ចំណែកផលបន្លែវិញ ក៏មានទីផ្សារស្រោប់ដោយឈ្មួញចុះ មកប្រមូលទិញអស់ៗដល់កន្លែង ដោយកសិករចាំតែច្រកចង់ទុកឱ្យប៉ុណ្ណោះ ដោយសារតែបន្លែរបស់ពួកគាត់ គ្មានជាតិគីមីដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព ដាំដុះដោយធម្មជាតិ និងប្រើប្រាស់សារធាតុគីមីតិចតួចតាម បច្ចេកទេសដាំដុះបន្លែសរីរាង្គនិងសុវត្ថភាព។ ចំពោះបញ្ហាបច្ចេកទេសក្រោយប្រមូលផលវិញ កសិករមិនទាន់ ចេះនោះទេ។ ដូច្នេះផលបន្លែទទួលបានអាចផ្គត់ផ្គង់តែនៅក្នុងស្រុក និងខេត្តជិតៗប៉ុណ្ណោះ មិនអាចធ្វើការផ្គត់ ផ្គង់ទៅកាន់ខេត្តឆ្ងាយៗនោះទេ ព្រោះបន្លែនឹងខូចសោភ័ណភាព បាត់បង់រសជាតិ និងខាតបង់ផលបន្លែ។ ចំពោះបញ្ហាទីផ្សារវិញ បន្លែមានទីផ្សារល្អណាស់ ដោយត្រូវបានប្រមូលទិញអស់ៗ ទោះបីជា នៅខែសម្បូរខ្លាំង ក៏ដោយ។ ដោយឡែក តម្លៃមានបញ្ហា ពីព្រោះកសិករនោទីនេះមិនទទួលបានការផ្សព្វផ្សាយពីតម្រូវការបន្លែ នៅលើទីផ្សារ ថាតើបន្លែប្រភេទណាដែលកំពុងមានតម្រូវការ ហើយត្រូវការក្នុងបរិមាណប៉ុន្មាននោះទេ ដែលជា ហេតុនាំឱ្យពួកគាត់ដាំដុះស្ពៃប្រភេទតែមួយដូចគ្នា បណ្តាលឱ្យបន្លែស្ពៃចាស់លើទីផ្សានាំឱ្យតម្លៃធ្លាក់ចុះយ៉ាង ខ្លាំង។ ប៉ុន្តែមានកសិករមួយចំនួនងាកមកដាំបន្លែប្រភេទផ្សេងនៅរដូវដាំដុះបន្លែស្ពៃ។ ដូច្នេះ ពួកគាត់អាចលក់ បន្លែទាំងនោះបានក្នុងតម្លៃថ្លៃ ហើយបានចំណូលច្រើនថែមទៀត។ ដូចនេះ ការផ្សព្វផ្សាយឱ្យកសិករដឹងពី ប្រភេទបន្លែដែលមានកំពុងតម្រូវការ និងបរិមាណច្បាស់លាស់ ធ្វើឱ្យកសិករលក់បន្លែបានក្នុងតំលៃខ្ពស់ និង មានទីផ្សារ។ ជាពិសេសមិនមានការខ្វះខាតបន្លែប្រភេទផ្សេងសម្រាប់ប្រើប្រាស់ ហើយក៏អាចជៀសវាងនូវការ នាំចូលបន្លែពីកន្លែងដទៃ ដែលយើងមិនដឹងថាមានសុវត្ថិភាពក្នុងការបរិភោគឬអត់ថែមទៀតផង។

ក្រឡេកមកមើលស្ថានភាពជារួមវិញ យើងឃើញថា យើងមានចំនេះដឹង ដើមទុន ទីផ្សារបន្លែ ហើយក៏មានបច្ចេកទេសផងដែរ។ អ្វីដែលនៅខ្វះខាតនោះគឺការផ្សព្វផ្សាយអំពីតម្រូវការបន្លែច្បាស់លាស់ដល់កសិករ។

ដូច្នេះ យើងសន្និដានបានថា នៅពេលដែលតម្រូវការទីផ្សារបន្លែត្រូវបានផ្សព្វផ្សាយច្បាស់លាស់ និងទូលំទូលាយហើយនោះ កសិករកម្ពុជានឹងអាចបង្កើនសមត្ថភាពក្នុងការផលិតបន្លែផ្គត់ផ្គង់តម្រូវការក្នុងស្រុកបានគ្រប់គ្រាន់ជំនួសបន្លែនាំចូលបានភ្លាមៗ។ ចំណែកឯ ចំនួនកសិករដាំដុះបន្លែក៏នឹងមានការកើនឡើងផងដែរ ដោយសារកសិករបានមើលឃើញពីទីផ្សារបន្លែដែលកំពុងមាន បច្ចេកទេសដែលគួរឱ្យជឿជាក់ ភាពងាយស្រួលក្នុងការស្វែងរកព័ត៌មានអំពីតម្រូវការទីផ្សារ មានការផ្សព្វផ្សាយពីសក្តានុពលដាំដុះតាមតំបន់នីមួយៗធំទូលំទូលាយ ការយកចិត្តទុកដាក់និងការជួយសម្រួលផ្នែកទុននិងប្រភពទឹកពីសំណាក់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងអង្គការនានា ដែលធ្វើឱ្យកសិករមានការរំពឹងទុកខ្ពស់ពីលទ្ធផលដែលនឹងទទួលបានមកពីការដាំដុះបន្លែនេះ។ ការរំពឹងទុកនេះហើយ ដែលជាកត្តាលើកទឹកចិត្តពីខាងក្នុងឱ្យចំនួនកសិករដាំដុះបន្លែមានចំនួនកាន់តែច្រើន ដូចការដាំដុះបន្លែនៅក្នុងឃុំគោកគង់លិច ដែលកាលពីដំបូងឡើយកសិករដាំបន្លែមានតែ៥ ទៅ៦គ្រួសារប៉ុណ្ណោះ ប៉ុន្តែក្រោយពេលមើលឃើញពីភាពជោគជ័យក្នុងការដាំបន្លែរបស់កសិករដទៃរួចមក ចំនួនកសិករដាំបន្លែនៅក្នុងឃុំនេះមានការកើនឡើងរហូតដល់៩១គ្រួសារឯនោះនាពេលបច្ចុប្បន្ន។

## ២. អនុសាសន៍

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងវិភាគបកស្រាយខាងលើ នាងខ្ញុំសូមធ្វើការសំណូមពរនូវចំណុចមួយចំនួនដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងកសិកម្ម ក៏ដូចជាអង្គភាពនានាដែលពាក់ព័ន្ធក្នុងការជម្រុញវិស័យកសិកម្ម ដូចខាងក្រោម៖

- ធ្វើការផ្សព្វផ្សាយពីប្រភេទបន្លែដែលកំពុងមានតម្រូវការ និងបរិមាណបន្លែដែលត្រូវការនៅលើទីផ្សារឱ្យបានច្បាស់លាស់។
- ធ្វើការកំណត់ និងផ្សព្វផ្សាយពីប្រភេទបន្លែដែលអាចដាំដុះបាន និងដាំដុះមិនបាននៅតាមតំបន់ ក៏ដូចជាខេត្តនីមួយៗ ដើម្បីឱ្យកសិករមានជម្រើសក្នុងការដាំដុះ និងសហការគ្នាក្នុងការផ្គត់ផ្គង់។
- កំណត់ប្រភេទបន្លែដែលមិនអាចដាំដុះបាននៅក្នុងស្រុក ហើយអនុញ្ញាតឱ្យនាំចូលតែប្រភេទបន្លែដែលមិនអាចដាំដុះបាន ដើម្បីជៀសវាងការនាំចូលប្រភេទបន្លែដែលអាចដាំដុះបានក្នុងស្រុក ដែលធ្វើឱ្យបាត់បង់ទីផ្សារបន្លែរបស់អ្នកផលិតក្នុងស្រុក។

នាងខ្ញុំជឿជាក់ថា ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការពិចារណាអនុវត្តតាមសំណូមពររបស់នាងខ្ញុំខាងលើនេះ សមត្ថភាពផលិតបន្លែរបស់កសិករនៅក្នុងស្រុក និងចំនួនកសិករដាំដុះបន្លែក្នុងស្រុកនឹងមានការកើនឡើង។

# ឯកសារយោង


១. Latham P.G., (2012), Work Motivation: History, Theory, Research, and Practice. Los Angeles: Sage.

២. Pinder, C. C. (1998). Work motivation in organizational behavior. Upper Saddle River NJ: Practice Hall.

៣. John A., Feather N., (1974), A Theory of Achievement Motivation (6 ed.), Krieger Pub Co.

៤. McClelland C.D., (1953), The Achievement Motive. New York: Appleton-Century-Crofts.

៥. Oliver L. R., (1974). Expectancy Theory Predictions of Salesmen's Performance. Journal of Marketing Research 11(3), 243-253.

៦. DK illustrated Oxford dictionary. (2003). London: DK Pub.

៧. ម៉ម ចរិយារុធ និងងួន ហេង, "សេដ្ឋកិច្ចនយោបាយ", ២០១៦, បោះពុម្ពលើកទី៥, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៨. ទឹម សាវ៉ាន់, "ការវាយតំលៃលើសួនបន្លែ", សារណាបញ្ចប់ការសិក្សាឆ្នាំ១៩៩៥, សាកលវិទ្យាល័យភូមិន្ទកសិកម្ម

៩. "គោលការណ៍ណែនាំសម្រាប់អ្នកសម្របសម្រួលស្តីពីផលិតកម្មដំណាំសរីរាង្គ", ២០១២,ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១០. បណ្ឌិត ប្រិន រ៉ូវែល និងតាត់ អេងឡាយ, "ដំណាំបន្លែនៅកម្ពុជា", ១៩៩២, បោះពុម្ពលើកទី១, នាយកដ្ឋានក្សេត្រសាស្ត្រនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១១. «របាយការណ៍តម្រូវការបន្លែនិងការផ្គត់ផ្គង់បន្លែនៅកម្ពុជា», គម្រោងជម្រុញផលិតកម្មស្មៀង, ២០១៩, រៀបចំដោយមជ្ឈមណ្ឌលសិក្សាគោលនយោបាយ(CPS)

១២. «សៀវភៅណែនាំស្តីពីការដាំបន្លែសុវត្ថិភាព», គម្រោងបន្លែ ផ្លែឈើ កម្ពុជា (CHAIN), ២០១៨, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១៣. «ផ្នែកទី៣ ការដាំដំណាំបន្លែសរីរាង្គ», ឯកសារការអប់រំបំណិនជីវិតស្តីពីកសិកម្ម, ឆ្នាំ២០១៣, បោះពុម្ពលើកទី១, បោះពុម្ពផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា

១៤. របាយការណ៍ស្ថានភាពប្រែប្រួលចំនួនប្រជារាស្ត្រប្រចាំខែមិថុនា ឆ្នាំ២០២០, សាលាស្រុកកញ្ជៀច

១៥. របាយការណ៍ស្ថានភាពប្រែប្រួលចំនួនប្រជារាស្ត្រប្រចាំខែមិថុនា ឆ្នាំ២០២០, សាលាឃុំគោកគង់លិច
១៦. បច្ចេកទេសក្រោយពេលប្រមូលផលដំណាំបន្លែ, ឆ្នាំ២០១៩, បោះពុម្ពលើកទី១, រៀបចំដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មសហការជាមួយនាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំនៃអគ្គនាយកដ្ឋានកសិកម្ម
១៧. ឯកសារយោងដែលបានដកស្រង់ពីប្រព័ន្ធអ៊ីនធើណែត

khmerkhasikor. (2017). ប្រភេទនៃការលើកទឹកចិត្ត. Khmer Agriculture. Retrieved September 1, 2020, from https://khmerkhasikor.blogspot.com/2017/03/blog-post.html

សីលធម៌. (2018). និយមន័យទីផ្សារ. KhSearch | ចែករំលែកចំណេះដឹង. Retrieved July 8, 2020, from https://www.khsearch.com/qna/11470

SarithKhem. (2018, May 16). និយមន័យទីផ្សារ. khemsaritheducation. https://khemsaritheducation.wordpress.com/2018/05/16/ចូរឲ្យនិយមន័យទីផ្សារ/

Oxford Dictionaries. (n.d.). Vegetable. Oxford Learner's Dictionaries. Retrieved July 10, 2020, from https://www.oxfordlearnersdictionaries.com/definition/english/vegetable?q=vegetable

ប៊ិន ប៊ុណ្ណា. (2020). កម្ពុជាមានបន្លែប៉ុន្មានប្រភេទ? Sabay News. Retrieved July 11, 2020, from https://news.sabay.com.kh/article/1194327

APAMAT. (2019, July 4). តើអ្វីគឺជាការវិភាគ SWOT ? Retrieved July 11, 2020, from https://apamat.com/2019/07/03/តើអ្វីគឺជាការវិភាគ-swot/

## ឧបសម្ព័ន្ធទី១

## បរិមាណតម្រូវការបន្លែតាមប្រភពផ្គត់ផ្គង់នីមួយៗនៅរាជធានីខេត្តទាំង៩

| ល.រ | ឈ្មោះខេត្ត | មកពីក្នុងខេត្ត | | មកពីខេត្តផ្សេងៗ | | មកពីប្រទេសវៀតណាម | | មកពីប្រទេសថៃ | | មកពីប្រទេសចិន | | មិនដឹងប្រភព | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ (គ.ក) | ភាគរយ | បរិមាណ (គ.ក) | ភាគរយ | បរិមាណ (គ.ក) | ភាគរយ | បរិមាណ (គ.ក) | ភាគរយ | បរិមាណ (គ.ក) | ភាគរយ | បរិមាណ (គ.ក) | ភាគរយ | បរិមាណ (គ.ក) |
| 1 | បាត់ដំបង | 123 | 55% | 13 | 6% | 8 | 3% | 60 | 27% | 18 | 8% | 1 | 0% | 223 |
| 2 | ត្បូងឃ្មុំ | 42 | 40% | 28 | 27% | 26 | 25% | 1 | 1% | 8 | 7% | 0 | 0% | 105 |
| 3 | សៀមរាប | 19 | 32% | 8 | 14% | 11 | 18% | 13 | 22% | 8 | 14% | 0 | 0% | 60 |
| 4 | កំពង់ចាម | 11 | 36% | 5 | 17% | 11 | 38% | 0 | 0% | 3 | 9% | 0 | 0% | 29 |
| 5 | កណ្ដាល | 10 | 40% | 2 | 7% | 12 | 49% | 0 | 0% | 1 | 4% | 0 | 0% | 24 |
| 6 | កំពង់ធំ | 4 | 10% | 11 | 27% | 8 | 19% | 7 | 17% | 10 | 26% | 0 | 0% | 40 |
| 7 | ពោធិ៍សាត់ | 3 | 23% | 2 | 18% | 5 | 44% | 1 | 8% | 1 | 6% | 0 | 0% | 11 |
| 8 | ព្រៃវែង | 2 | 8% | 6 | 36% | 8 | 45% | 0 | 0% | 2 | 11% | 0 | 0% | 18 |
| 9 | ភ្នំពេញ | 0 | 0% | 217 | 40% | 175 | 32% | 21 | 4% | 135 | 25% | 0 | 0% | 547 |
| | សរុប | 212 | 20% | 292 | 28% | 264 | 25% | 103 | 10% | 185 | 18% | 1 | 0% | 1058 |

ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជាខែធ្នូ ឆ្នាំ២០១៩

# ឧបសម្ព័ន្ធទី២

# បរិមាណតម្រូវការបន្លែតាមប្រភេទ និងប្រភពផ្គត់ផ្គង់នីមួយៗនៅរាជធានី ខេត្តទាំង៩ក្នុងមួយថ្ងៃ

| ល.រ | ប្រភេទបន្លែ | ផលិតក្នុងខេត្ត | | នាំចូលពីខេត្តដទៃ | | នាំចូលពីវៀតណាម | | នាំចូលពីថៃ | | នាំចូលពីចិន | | មិនដឹងប្រភព | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ |
| 1 | ស្ពៃក្តោប | 11,890 | 12% | 10,780 | 11% | 27,425 | 29% | 15,970 | 17% | 29,030 | 30% | 170 | 0% | 95,265 | 9.0% |
| 2 | ត្រសក់ | 36,380 | 42% | 29,405 | 34% | 20,620 | 24% | 300 | 0% | - | 0% | - | 0% | 86,705 | 8.2% |
| 3 | ខ្ទឹមស | - | 0% | - | 0% | 3,885 | 7% | - | 0% | 55,255 | 93% | - | 0% | 59,140 | 5.6% |
| 4 | ដំឡូងជ្វា | 150 | 0% | 16,880 | 35% | 7,890 | 16% | 22,980 | 48% | 200 | 0% | 5 | 0% | 48,105 | 4.5% |
| 5 | ល្ពៅ | 15,901 | 34% | 23,710 | 51% | 4,480 | 10% | 2,270 | 5% | - | 0% | 10 | 0% | 46,371 | 4.4% |
| 6 | ខ្ទឹមបារាំង | - | 0% | - | 0% | 23,711 | 54% | 1,010 | 2% | 19,571 | 44% | - | 0% | 44,292 | 4.2% |
| 7 | ការ៉ុត | - | 0% | - | 0% | 7,835 | 18% | 9,060 | 20% | 27,395 | 62% | - | 0% | 44,290 | 4.2% |
| 8 | ល្ហុងខ្ចី | 14,185 | 33% | 27,190 | 62% | 1,770 | 4% | 400 | 1% | - | 0% | 20 | 0% | 43,565 | 4.1% |
| 9 | ក្រូចឆ្មារ | 1,635 | 4% | 1,555 | 4% | 36,750 | 89% | 1,100 | 3% | 210 | 1% | - | 0% | 41,250 | 3.9% |
| 10 | ឆៃថាវ | 10,695 | 27% | 8,748 | 22% | 19,010 | 49% | 30 | 0% | 690 | 2% | - | 0% | 39,173 | 3.7% |
| 11 | សាលាដ | 1,990 | 6% | 30,532 | 87% | 505 | 1% | 1,945 | 6% | 180 | 1% | - | 0% | 35,152 | 3.3% |
| 12 | ស្ពៃបូកគោ | - | 0% | - | 0% | 3,622 | 12% | 1,745 | 6% | 25,540 | 83% | - | 0% | 30,907 | 2.9% |
| 13 | ត្រឡាច | 16,143 | 53% | 8,290 | 27% | 6,240 | 20% | - | 0% | - | 0% | - | 0% | 30,673 | 2.9% |
| 14 | ស្ពៃចង្កឹះ | 4,489 | 15% | 20,080 | 66% | 220 | 1% | 5,700 | 19% | 20 | 0% | - | 0% | 30,509 | 2.9% |
| 15 | ត្រប់ស្រួយ | 13,475 | 49% | 12,630 | 46% | 1,313 | 5% | 200 | 1% | - | 0% | - | 0% | 27,618 | 2.6% |
| 16 | ប៉េងប៉ោះ | 1,605 | 6% | 1,575 | 6% | 20,810 | 78% | 2,790 | 10% | 50 | 0% | - | 0% | 26,830 | 2.5% |
| 17 | ស្ពៃក្រញ៉ាញ់ | 4,034 | 16% | 18,205 | 72% | 1,400 | 6% | 1,545 | 6% | - | 0% | - | 0% | 25,184 | 2.4% |
| 18 | ត្រប់វែង | 10,305 | 43% | 4,915 | 20% | 7,760 | 32% | 1,000 | 4% | 200 | 1% | - | 0% | 24,180 | 2.3% |
| 19 | ស្ពៃប្លក់ចយ | 2,779 | 13% | 11,055 | 50% | 2,880 | 13% | 3,980 | 18% | 1,235 | 6% | 5 | 0% | 21,934 | 2.1% |
| 20 | ត្រាវ | 20 | 0% | 1,815 | 8% | 8,185 | 38% | 10,365 | 48% | 1,170 | 5% | 15 | 0% | 21,570 | 2.0% |
| 21 | ខាត់ណាដើម | 2,700 | 14% | 15,195 | 78% | 1,030 | 5% | 150 | 1% | 325 | 2% | - | 0% | 19,400 | 1.8% |
| 22 | ខ្ញី | 290 | 2% | 1,115 | 6% | 10,235 | 55% | 6,120 | 33% | 980 | 5% | 25 | 0% | 18,765 | 1.8% |
| 23 | ម្ទេសដៃនាង | 4,050 | 23% | 2,772 | 16% | 10,023 | 58% | 400 | 2% | 120 | 1% | 10 | 0% | 17,375 | 1.6% |
| 24 | ខ្ទឹមក្រហម | - | 0% | - | 0% | 2,766 | 18% | 500 | 3% | 11,309 | 73% | 930 | 6% | 15,505 | 1.5% |
| 25 | ដំឡូងបារាំង | - | 0% | 30 | 0% | 9,644 | 62% | 310 | 2% | 5,498 | 36% | - | 0% | 15,482 | 1.5% |
| 26 | ម្រះ | 5,670 | 37% | 3,370 | 22% | 3,950 | 26% | 2,200 | 14% | - | 0% | - | 0% | 15,190 | 1.4% |
| 27 | សណ្តែកគួរ | 9,213 | 61% | 5,575 | 37% | 360 | 2% | - | 0% | - | 0% | - | 0% | 15,148 | 1.4% |
| 28 | ស្ពៃជ្រក់ | 8,000 | 68% | 1,550 | 13% | - | 0% | 2,300 | 19% | - | 0% | - | 0% | 11,850 | 1.1% |

| ល.រ | ប្រភេទបន្លែ | ផលិតក្នុងខេត្ត | | នាំចូលពីខេត្តដទៃ | | នាំចូលពីវៀតណាម | | នាំចូលពីថៃ | | នាំចូលពីចិន | | មិនដឹងប្រភព | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ | បរិមាណសរុប (គ.ក) | ភាគរយ |
| 29 | ម្ទេសហាវ៉ៃ | 605 | 5% | 3,999 | 34% | 5,150 | 44% | 1,105 | 9% | 815 | 7% | - | 0% | 11,674 | 1.1% |
| 30 | ស្ពៃខៀវ | 4,073 | 37% | 6,965 | 63% | 50 | 0% | - | 0% | - | 0% | - | 0% | 11,088 | 1.0% |
| 31 | ខាត់ណាផ្កា | - | 0% | 1,065 | 11% | 1,160 | 12% | 1,990 | 21% | 5,293 | 56% | - | 0% | 9,508 | 0.9% |
| 32 | បន្លែផ្សេងៗ | 2,296 | 25% | 3,280 | 36% | 769 | 8% | 2,785 | 30% | 15 | 0% | - | 0% | 9,145 | 0.9% |
| 33 | ខ្ទឹមស្លឹក | 4,833 | 53% | 4,177 | 46% | 50 | 1% | - | 0% | - | 0% | - | 0% | 9,060 | 0.9% |
| 34 | រំដេង | 5,790 | 68% | 2,680 | 31% | 80 | 1% | - | 0% | - | 0% | 10 | 0% | 8,560 | 0.8% |
| 35 | ត្រសក់ស្រូវ | 5,470 | 72% | 1,130 | 15% | 1,000 | 13% | 40 | 1% | - | 0% | - | 0% | 7,640 | 0.7% |
| 36 | ផ្សិត | 491 | 8% | 65 | 1% | 5,159 | 88% | 100 | 2% | 63 | 1% | - | 0% | 5,878 | 0.6% |
| 37 | ត្រកួនចិន | 2,585 | 50% | 2,620 | 50% | - | 0% | - | 0% | - | 0% | - | 0% | 5,205 | 0.5% |
| 38 | ននោងមូល | 2,530 | 52% | 1,270 | 26% | 490 | 10% | 560 | 12% | - | 0% | - | 0% | 4,850 | 0.5% |
| 39 | ពពាយជ្រុង | 1,225 | 30% | 1,410 | 35% | 1,120 | 28% | 300 | 7% | - | 0% | 10 | 0% | 4,065 | 0.4% |
| 40 | ស្មៀត | 2,523 | 67% | 1,225 | 33% | 15 | 0% | - | 0% | - | 0% | - | 0% | 3,763 | 0.4% |
| 41 | ពោតបារាំង | 378 | 13% | 625 | 22% | 1,697 | 60% | 100 | 4% | - | 0% | 5 | 0% | 2,805 | 0.3% |
| 42 | ស្លឹកគ្រៃ | 685 | 32% | 1,195 | 56% | 260 | 12% | - | 0% | - | 0% | - | 0% | 2,140 | 0.2% |
| 43 | ននោងជ្រុង | 820 | 39% | 940 | 45% | 320 | 15% | - | 0% | - | 0% | - | 0% | 2,080 | 0.2% |
| 44 | ស្មៀតពោត | 485 | 24% | 60 | 3% | 82 | 4% | 1,415 | 69% | - | 0% | - | 0% | 2,042 | 0.2% |
| 45 | ឃ្លោក | 660 | 34% | 490 | 25% | 800 | 41% | - | 0% | - | 0% | - | 0% | 1,950 | 0.2% |
| 46 | ម្ទេសអាចម៍សត្វ | 351 | 25% | 970 | 69% | 79 | 6% | - | 0% | - | 0% | - | 0% | 1,400 | 0.1% |
| 47 | សណ្ដែកបារាំង | 210 | 16% | 20 | 2% | 1,043 | 82% | - | 0% | 3 | 0% | - | 0% | 1,276 | 0.1% |
| 48 | ស្ពៃឆាយស៊ីម | 580 | 56% | 50 | 5% | - | 0% | 200 | 19% | 200 | 19% | - | 0% | 1,030 | 0.1% |
| 49 | ស្លឹកខ្ទឹម | 87 | 9% | 900 | 91% | - | 0% | - | 0% | - | 0% | - | 0% | 987 | 0.1% |
| **សរុប** | | **212,276** | **20%** | **292,108** | **28%** | **263,643** | **25%** | **102,965** | **10%** | **185,367** | **18%** | **1,215** | **0%** | **1,057,574** | **100.0%** |

ប្រភព៖ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជាខែធ្នូ ឆ្នាំ២០១៩

# ឧបសម្ព័ន្ធទី៣

## តម្លៃបន្លែតាមប្រភពផ្គត់ផ្គង់នីមួយៗនៅរាជធានីខេត្តទាំង៩ (រៀល/គ.ក)

| ល.រ | ប្រភេទបន្លែ | ផលិតក្នុងខេត្ត | នាំចូលពីខេត្តដទៃ | នាំចូលពីវៀតណាម | នាំចូលពីថៃ | នាំចូលពីចិន | មិនដឹងប្រភព | តម្លៃមធ្យមបន្លែក្នុងស្រុក | តម្លៃមធ្យមបន្លែនាំចូល | មធ្យម |
|---|---|---|---|---|---|---|---|---|---|---|
| 1 | ត្រសក់ | 1,887 | 1,856 | 1,686 | 1,500 | | | 1,871 | 1,593 | 1,732 |
| 2 | ម្រះ | 2,862 | 2,766 | 2,514 | 2,725 | | | 2,814 | 2,620 | 2,717 |
| 3 | ប៉េងប៉ោះ | 2,565 | 2,418 | 2,611 | 2,905 | 3,100 | | 2,491 | 2,872 | 2,720 |
| 4 | ត្រប់វែង | 1,693 | 1,657 | 1,580 | 1,500 | 3,000 | | 1,675 | 2,027 | 1,886 |
| 5 | ត្រប់ស្រួយ | 1,402 | 1,130 | 1,614 | 1,200 | | | 1,266 | 1,407 | 1,337 |
| 6 | ត្រឡាច | 1,126 | 1,165 | 1,548 | | | | 1,146 | 1,548 | 1,280 |
| 7 | ល្ពៅ | 1,160 | 1,217 | 1,428 | 838 | | 1,500 | 1,188 | 1,133 | 1,228 |
| 8 | ននោងមូល | 1,280 | 1,451 | 1,513 | 1,746 | | | 1,366 | 1,630 | 1,498 |
| 9 | ននោងជ្រុង | 1,250 | 1,729 | 1,600 | | | | 1,490 | 1,600 | 1,526 |
| 10 | ឃ្លោក | 1,145 | 1,267 | 1,683 | | | | 1,206 | 1,683 | 1,365 |
| 11 | សណ្តែកកួរ | 2,452 | 2,249 | 3,458 | | | | 2,351 | 3,458 | 2,720 |
| 12 | សណ្តែកបារាំង | 2,825 | 4,250 | 3,736 | | | | 3,538 | 3,736 | 3,604 |
| 13 | ពោតបារាំង | 2,813 | 2,935 | 2,632 | 3,200 | | 3,500 | 2,874 | 2,916 | 3,016 |
| 14 | ម្ទេសដៃនាង | 4,991 | 5,537 | 5,412 | 5,150 | 5,250 | 6,000 | 5,264 | 5,271 | 5,390 |
| 15 | ម្ទេសអាចមន៍សត្វ | 6,329 | 4,217 | 6,833 | | | | 5,273 | 6,833 | 5,793 |
| 16 | ម្ទេសហាវ៉ៃ | 3,397 | 4,108 | 4,372 | 5,005 | 4,483 | | 3,753 | 4,620 | 4,273 |
| 17 | ពពាយជ្រុង | 4,135 | 3,651 | 3,503 | 4,750 | | 6,000 | 3,893 | 4,126 | 4,408 |
| 18 | ល្ហុងខ្ចី | 522 | 613 | 595 | 600 | | 800 | 567 | 598 | 626 |
| 19 | ស្ពៃក្តោប | 2,454 | 2,289 | 1,531 | 1,724 | 1,702 | 2,000 | 2,372 | 1,652 | 1,950 |
| 20 | ស្ពៃបូកគោ | 6,000 | 5,000 | 2,235 | 1,985 | 1,939 | | 5,500 | 2,053 | 3,432 |
| 21 | ខាត់ណាដើម | 4,066 | 4,260 | 4,349 | 10,000 | 5,144 | | 4,163 | 6,498 | 5,564 |
| 22 | ខាត់ណាផ្កា | | 4,567 | 5,146 | 4,357 | 4,186 | | 4,567 | 4,563 | 4,564 |
| 23 | ស្ពៃប្លក់ចយ | 2,836 | 3,276 | 2,946 | 2,879 | 3,440 | 4,000 | 3,056 | 3,088 | 3,229 |
| 24 | ស្ពៃចង្កឹះ | 2,501 | 2,443 | 2,629 | 2,570 | 2,300 | | 2,472 | 2,499 | 2,489 |
| 25 | ស្ពៃឆាយស៊ឹម | 2,275 | 7,500 | | 2,000 | 8,750 | | 4,888 | 5,375 | 5,131 |
| 26 | ស្ពៃក្រញ៉ាញ់ | 3,567 | 4,223 | 3,088 | 2,657 | | | 3,895 | 2,872 | 3,384 |
| 27 | ស្ពៃខៀវ | 2,536 | 3,210 | 3,125 | | | | 2,873 | 3,125 | 2,957 |
| 28 | សាលាដ | 3,639 | 3,709 | 3,510 | 4,460 | 6,000 | | 3,674 | 4,657 | 4,264 |
| 29 | ត្រកួនចិន | 2,112 | 1,590 | | | | | 1,851 | | 1,851 |

| ល.រ | ប្រភេទបន្លែ | ផលិតក្នុងខេត្ត | នាំចូលពីខេត្តដទៃ | នាំចូលពីវៀតណាម | នាំចូលពីថៃ | នាំចូលពីចិន | មិនដឹងប្រភព | តម្លៃមធ្យមបន្លែក្នុងស្រុក | តម្លៃមធ្យមបន្លែនាំចូល | មធ្យម |
|---|---|---|---|---|---|---|---|---|---|---|
| 30 | ខ្ទឹមស្លឹក | 4,694 | 4,427 | 4,850 | | | | 4,560 | 4,850 | 4,657 |
| 31 | ស្លឹកថ្មី | 3,800 | | 6,320 | | | | 3,800 | 6,320 | 5,060 |
| 32 | ផែថាវ | 1,659 | 1,612 | 1,906 | 1,500 | 1,760 | | 1,635 | 1,722 | 1,687 |
| 33 | ការ៉ុត | | | 1,598 | 1,445 | 1,553 | | | 1,532 | 1,532 |
| 34 | ខ្ទឹ | 3,032 | 3,150 | 2,756 | 3,347 | 3,350 | 3,000 | 3,091 | 3,151 | 3,106 |
| 35 | ដំឡូងបារាំង | | 2,650 | 2,258 | 2,300 | 2,152 | | 2,650 | 2,237 | 2,340 |
| 36 | ខ្ទឹមបារាំង | | | 1,883 | 1,900 | 1,812 | | | 1,865 | 1,865 |
| 37 | ខ្ទឹមស | | | 4,061 | | 3,779 | | | 3,920 | 3,920 |
| 38 | ខ្ទឹមក្រហម | | | 4,557 | 4,500 | 4,558 | 4,525 | | 4,538 | 4,535 |
| 39 | ត្រាវ | 6,000 | 3,162 | 3,597 | 4,292 | 3,958 | 3,850 | 4,581 | 3,949 | 4,143 |
| 40 | ដំឡូងជ្វា | 1,250 | 1,432 | 1,451 | 1,262 | 1,200 | 1,500 | 1,341 | 1,304 | 1,349 |
| 41 | វំដេង | 1,377 | 1,544 | 1,600 | | | 2,000 | 1,461 | 1,600 | 1,630 |
| 42 | រមៀត | 2,340 | 2,248 | 2,000 | | | | 2,294 | 2,000 | 2,196 |
| 43 | ស្លឹកគ្រៃ | 1,276 | 1,225 | 800 | | | | 1,250 | 800 | 1,100 |
| 44 | ជ្បៀត | 5,567 | 6,625 | 7,533 | 6,800 | 15,500 | | 6,096 | 9,944 | 8,405 |
| 45 | ក្រូចឆ្មារ | 2,973 | 2,196 | 1,974 | 1,500 | 1,700 | | 2,584 | 1,725 | 2,069 |
| 46 | គ្រសក់ស្រូវ | 1,425 | 1,588 | 2,100 | 1,500 | | | 1,506 | 1,800 | 1,653 |
| 47 | ស្មៀតពោត | 1,725 | 1,700 | 3,667 | 3,442 | | | 1,713 | 3,554 | 2,633 |
| 48 | ស្ពៃជ្រក់ | 1,200 | 2,183 | | 1,100 | | | 1,692 | 1,100 | 1,494 |
| 49 | បន្លែផ្សេងៗ | 2,690 | 1,839 | 5,830 | 1,971 | 6,000 | | 2,265 | 4,600 | 3,666 |
| 50 | **មធ្យមសរុប** | **2,717** | **2,815** | **2,992** | **2,875** | **4,026** | **3,223** | **2,797** | **3,095** | **2,959** |

ប្រភពៈ របាយការណ៍តម្រូវការបន្លែ និងការផ្គត់ផ្គង់បន្លែនៅកម្ពុជាខែធ្នូ ឆ្នាំ២០១៩

# ឧបសម្ព័ន្ធទី៤
# តំបន់សិក្សាស្រាវជ្រាវ

រូបទី១៖ ផែនទីភូមិសាស្ត្រស្រុកកញ្ជ្រៀច



រូបភាពទី២៖ របាយការណ៍ស្ថានភាពប្រែប្រួលចំនួនប្រជាសាស្ត្រនៃស្រុកកញ្ជ្រៀចខែមិថុនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តព្រៃវែង
ស្រុក កញ្ជ្រៀច
ការិយាល័យផែនការ និងគាំទ្រឃុំ
លេខ ០០៥/២០

របាយការណ៍ស្ថានភាពប្រែប្រួលចំនួនប្រជាសាស្ត្រ
ប្រចាំខែ មិថុនា ឆ្នាំ ២០២០

| ល.រ | ឈ្មោះអង្គភាព | ចំនួនគ្រួសារនិងមនុស្សនៅចុងខែមុន | | | ស្ថានភាពប្រែប្រួលដែលកើតឡើងក្នុងខែនេះ | | | | | | | | | | ចំនួនគ្រួសារនិងមនុស្សនៅចុងខែនេះ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើត | | ស្លាប់ | | ផ្លាស់ចេញ | | | ផ្លាស់ចូល | | | | | |
| | | ចំនួនគ្រួសារ | សរុបចំនួនមនុស្ស | ស្រី | សរុប | ស្រី | សរុប | ស្រី | គ្រួសារ | សរុប | ស្រី | គ្រួសារ | សរុប | ស្រី | ចំនួនគ្រួសារ | សរុបចំនួនមនុស្ស | ស្រី |
| ក | ខ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 |
| 1 | ចុងអំពិល | 2,587 | 10,703 | 5,407 | 9 | 4 | 6 | 2 | - | - | - | - | - | - | 2,587 | 10,706 | 5,409 |
| 2 | កញ្ជ្រៀច | 1,785 | 7,366 | 3,906 | 13 | 5 | - | - | 1 | 3 | 3 | - | - | - | 1,784 | 7,376 | 3,908 |
| 3 | ក្ដឿងរាយ | 3,277 | 13,781 | 7,180 | 36 | 16 | 5 | 2 | 3 | 11 | 4 | - | 7 | 2 | 3,274 | 13,808 | 7,192 |
| 4 | គោកគង់កើត | 1,576 | 6,356 | 3,295 | - | - | - | - | - | - | - | - | - | - | 1,576 | 6,356 | 3,295 |
| 5 | គោកគង់លិច | 1,730 | 7,276 | 3,895 | 4 | 2 | 4 | 2 | - | - | - | - | - | - | 1,730 | 7,276 | 3,895 |
| 6 | ព្រាល | 3,147 | 12,093 | 6,300 | 31 | 17 | 7 | 5 | - | - | - | - | - | - | 3,147 | 12,117 | 6,312 |
| 7 | ថ្មពូន | 2,322 | 9,503 | 5,000 | 16 | 10 | 2 | - | - | - | - | - | - | - | 2,322 | 9,517 | 5,010 |
| 8 | ត្នោត | 1,426 | 6,520 | 3,440 | 33 | 20 | 14 | 9 | 12 | 46 | 18 | 12 | 59 | 28 | 1,426 | 6,552 | 3,461 |
| | សរុប | 17,850 | 73,598 | 38,423 | 142 | 74 | 38 | 20 | 16 | 60 | 25 | 12 | 66 | 30 | 17,846 | 73,708 | 38,482 |

បញ្ជាក់
ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២០
អភិបាល នៃគណៈអភិបាលស្រុក
ឈឿន ឌី

បញ្ជាក់
ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២០
ប្រធានការិយាល័យផែនការស្ថិតិស្រុក

ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២០
អ្នកធ្វើការងារ

រូបភាពទី៣៖ របាយការណ៍ស្ថានភាពប្រែប្រួលចំនួនប្រជាសាស្ត្រនៃឃុំគោកគង់លិចខែមិថុនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុក កញ្ជៀច

ឃុំ គោកគង់លិច

លេខ: ៣១៨/២០មក

**របាយការណ៍ស្ថានភាពប្រែប្រួលចំនួនប្រជាពលរដ្ឋ**

**ប្រចាំខែ មិថុនា ឆ្នាំ ២០២០**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ និងមនុស្សនៅ | | | ស្ថានភាពប្រែប្រួលដែលកើតឡើង | | | | | | | | | | ចំនួនគ្រួសារ និងមនុស្សនៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើត | | ស្លាប់ | | ផ្លាស់ចេញ | | | ផ្លាស់ចូល | | | | | |
| | | ចំនួនគ្រួសារ | សរុបមនុស្ស | ស្រី | សរុប | ស្រី | សរុប | ស្រី | ចំនួន | សរុប | ស្រី | ចំនួន | សរុប | ស្រី | ចំនួនគ្រួសារ | សរុបមនុស្ស | ស្រី |
| 1 | អ្នកតាជ័យ | 217 | 877 | 455 | 1 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 217 | 877 | 456 |
| 2 | ដំណាក់ស្លួល | 79 | 325 | 171 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 79 | 326 | 171 |
| 3 | ត្រពាំងឬស្សី | 96 | 443 | 231 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 96 | 442 | 230 |
| 4 | ត្រពាំងប្រស្រែលិច | 28 | 119 | 56 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 28 | 119 | 56 |
| 5 | ត្រពាំងប្រស្រែកើត | 41 | 180 | 96 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 41 | 181 | 96 |
| 6 | ត្រពាំងគីរ | 37 | 176 | 85 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 37 | 176 | 85 |
| 7 | ព្រៃចក | 69 | 311 | 161 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 69 | 311 | 161 |
| 8 | ខ្ទមណោរ | 40 | 156 | 79 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 40 | 156 | 79 |
| 9 | ស្វាយចេក | 90 | 401 | 210 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 90 | 400 | 209 |
| 10 | គោកគង់កើត | 254 | 1083 | 598 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 254 | 1082 | 598 |
| 11 | គោកគង់លិច | 94 | 387 | 231 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 94 | 387 | 231 |
| 12 | គោកគង់កណ្តាល | 116 | 490 | 265 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 116 | 490 | 265 |
| 13 | គោកគង់ត្បូង | 76 | 282 | 162 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 76 | 282 | 162 |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 14 | ស្វាយរុន | 187 | 620 | 331 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 187 | 620 | 331 |
| 15 | ខូលពពេល | 166 | 789 | 432 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 166 | 790 | 433 |
| 16 | កោះទ្រេត | 104 | 457 | 237 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 104 | 457 | 237 |
| 17 | ស្វាយទោស | 36 | 179 | 94 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 36 | 179 | 94 |
| សរុប | | 1730 | 7276 | 3894 | 4 | 2 | 4 | 2 | 0 | 0 | 0 | 0 | 0 | 0 | 1730 | 7276 | 3894 |

ថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២០
អ្នកធ្វើតារាង

ថ្ងៃព្រហស្បតិ៍៦រោច ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
គោកគង់លិច. ថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២០
**មេឃុំ**

# ឧបសម្ព័ន្ធទី៥
# កម្រងរូបភាព

រងបណ្តុះបន្លែដែលបានលើករួច



កូនបន្លែ និងការគ្របសំណាញ់



ការថែទាំ និងគ្របសំណាញ់នៅពេលដាំដុះ



បន្លែដែលជិតប្រមូលផល



ការវេចខ្ចប់បន្លែក្រោយប្រមូលផល



ការដាំបន្លែវិលជុំក្នុងចម្ការតែមួយ



ប្រភពទឹក អណ្តូង

